**កម្មវិធីអប់ពិសេស**

**...ផ្តល់ជាសេវាកម្ម មិនមែនជាទីកន្លែង**

# ការជូនដំណឹងស្តីពី នីតិវិធីគាំពារសុវត្ថិភាពអប់រំពិសេសសម្រាប់សិស្ស និងក្រុមគ្រួសាររបស់គេ

តម្រូវការក្រោមផ្នែក ខ នៃច្បាប់ស្តីពីការអប់រំសម្រាប់ជនពិការ បទបញ្ញត្តិសហព័ន្ធ និងកម្មវិធីអប់រំពិសេសគ្រប់គ្រងដោយរដ្ឋ

**កែតម្រូវឡើងវិញនៅ ខែសីហា  ឆ្នាំ2009**

***រ៉េនឌី អាយ .ដន***

ស្នងការរដ្ឋទទួលបន្ទុក

**លើវិស័យអប់រំសាធារណៈ**

# ការជូនដំណឹងស្តីពីនីតិវិធីគាំពារសុវត្ថិភាពអប់រំពិសេសសម្រាប់សិស្ស និង ក្រុមគ្រួសាររបស់គេ

**Special Education**
ការិយាល័យគ្រប់គ្រងវិស័យអប់រំសាធារណៈ

**Dr. Douglas H. Gill**
នាយក **Special Education**

---

Randy I. Dorn
អ្នកត្រួតពិនិត្យការអប់រំសាធារណៈ

Ken Kanikeberg
ប្រធានបុគ្គលិក

Bob Harmon
ជំនួយការត្រួតពិនិត្យ
Special Programs and Federal Accountability

---

**ត្រួតពិនិត្យឡើងវិញ ខែសីហា ឆ្នាំ2009**

**ការិយាល័យត្រួតពិនិត្យវិស័យអប់រំសាធារណៈ**

Old Capitol Building
P.O. Box 47200
Olympia, WA 98504-7200

**សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងមាតិកានៃឯកសារនេះ សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈ**

Special Education, OSPI
**អ៊ីម៉ែល:** speced@k12.wa.us ឬ

ទូរស័ព្ទ ៖ (360) 725-6075

ឯកសារនេះមាននៅលើគេហទំព័រ ៖
http://www.k12.wa.us/SpecialEd/publications.aspx
សូមមើលឯកសារដែលមានលេខដូចខាងក្រោមដើម្បីទទួលបានព័ត៌មានឆាប់រហ័ស:

09-0025

ឯកសារនេះគឺមានក្នុងទម្រង់ផ្សេងទៀតនៅពេលមានការស្នើសុំ។

សូមទាក់ទងមកកាន់មជ្ឈមណ្ឌលធនធាន តាមរយៈលេខទូរស័ព្ទ (888) 595-3276, TTY (360) 664-3631 ។

ការិយាល័យគ្រប់គ្រងវិស័យអប់រំសាធារណៈ ធ្វើការប្ដេជ្ញាចំពោះការផ្ដល់ឱកាសស្មើគ្នានៅគ្រប់កម្មវិធី សកម្មភាព និងឱកាសការងារ និងគោរពយ៉ាងហ្មត់ចត់ចំពោះច្បាប់សហព័ន្ធ និងច្បាប់រដ្ឋ ដែលហាមឃាត់នូវការរើសអើងទៅលើជាតិសាសន៍ កុលសម្ព័ន្ធ សញ្ជាតិដើម ភេទ ឥរិយាបថផ្លូវភេទ សាសនា ស្ថានភាពយោធា អាយុ ឬពិការភាព។

**ព័ត៌មានទូទៅ** **1**
សេចក្ដីផ្ដើម 1
តើការជូនដំណឹងនេះធ្វើឡើងសម្រាប់នរណា? 1
ការផ្ដល់ការអប់រំជាសាធារណៈដែលមានលក្ខណៈសមស្របដោយឥតគិតថ្លៃ (FAPE) 1
សម្រាប់ព័ត៌មានបន្ថែម 1
សេចក្ដីជូនដំណឹងស្ដីពីនីតិវិធីគាំពា **2**
ការជូនដំណឹងជាលាយលក្ខណ៍ អក្សរជាមុន **2**
ភាសាកំណើត **3**
សារអេឡិចត្រូនិច **4**
ការព្រមព្រៀងរបស់មាតាបិតា-និយមន័យ **4**
ការយល់ព្រមរបស់ឪពុកម្ដាយ ៖ លក្ខខណ្ឌ **4**
ការយល់ព្រមសម្រាប់ការវាយតម្លៃជាលើកដំបូង 4
វិធានពិសេសសម្រាប់ការវាយតម្លៃជាលើកដំបូងទៅលើកុមារស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ 5
ការព្រមព្រៀងរបស់ឪពុកម្ដាយសម្រាប់សេវាដំបូង និងការលុបចោលការព្រមព្រៀងសម្រាប់សេវាបន្ត 5
ការព្រមព្រៀងរបស់មាតាបិតាលើការវាយតម្លៃសាជាថ្មី 6
ឯកសារនៃកិច្ចខិតខំប្រឹងប្រែងដែលមានហេតុផលដើម្បីទទួលបានការព្រមព្រៀងពីមាតាបិតា 7
ព័ត៌មានស្ដីពីការព្រមព្រៀងផ្សេងទៀត 7
ការវាយតម្លៃសេវាអប់រំឯករាជ្យ **8**
និយមន័យ 8
សិទ្ធិមាតាបិតាទៅចំពោះការវាយតម្លៃដែលបង់ដោយថវិកាចំណាយសាធារណៈ 8
ការវាយតម្លៃដែលផ្ដើមឡើងដោយមាតាបិតា 8
សំណើសុំការវាយតម្លៃដោយចៅក្រមច្បាប់រដ្ឋបាល (ALJ) 9
លក្ខណៈវិនិច្ឆ័យសាលា 9
ការចូលរួមពីមាតាបិតា **9**
កិច្ចព្រមព្រៀងរវាងអ្នក និងសាលាទាក់ទងទៅនឹងកិច្ចប្រជុំ **IEP** និងការវាយតម្លៃឡើងវិញ **9**
កិច្ចព្រមព្រៀងនៃកិច្ចប្រជុំ IEP 9
កិច្ចព្រមព្រៀងលើការវាយតម្លៃឡើងវិញ 10
ការដកចេញពីកិច្ចព្រមព្រៀង 10
ការផ្ទេរសិទ្ធិមាតាបិតានៅក្នុងពេលបំពេញវ័យ **10**
ព័ត៌មានសម្ងាត់ **11**
ព័ត៌មានសម្រាប់បុគ្គល **11**

សិទ្ធិក្នុងការទទួលបាន **12**
បញ្ជីនៃការចូលទៅប្រើប្រាស់ 13
របាយការណ៍ទៅលើក្មេងច្រើនជាងម្នាក់ 13
បញ្ជីរាយពីប្រភេទ និងទីតាំងព័ត៌មាន 13
ថ្លៃឈ្នួល 13
ការកែសម្រួលរបាយការណ៍ទៅតាមសំណើមាតាបិតា **13**
ឱកាសទៅចំពោះសវនាការ និងលទ្ធផលនៃសវនាការ 13
សេចក្ដីព្រមព្រៀងទៅចំពោះព័ត៌មានដែលអាចសម្គាល់ពីអត្តសញ្ញាណបុគ្គល **14**
ការគាំពារសម្រាប់ព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបុគ្គល **14**
ការកំទេច ដកហូត និងការរក្សាទុកព័ត៌មាន **15**
នីតិវិធីនៃការដោះស្រាយជម្លោះសេវារអប់រំពិសេស **15**
**ការសម្របសម្រួល** **15**
ទូទៅ 15
ភាពមិនលំអៀងនៃការសម្របសម្រួល 16
ភាពខុសគ្នារវាងការស៊ើបអង្កេតទៅលើសវនាការក្រោមច្បាប់រដ្ឋ និងបណ្ដឹងរដ្ឋប្បវេណីទៅលើសេវារអប់រំពិសេស **16**
នីតិវិធីបណ្ដឹងរដ្ឋប្បវេណី **17**
ការដាក់ពាក្យបណ្ដឹង 17
ការស៊ើបអង្កេតទៅលើពាក្យបណ្ដឹង 18
ការស៊ើបអង្កេត ការពន្យាពេល និងសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ 18
ដំណោះស្រាយទៅចំពោះពាក្យបណ្ដឹង 18
ពាក្យបណ្ដឹងរដ្ឋប្បវេណី និងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋទៅលើសេវារអប់រំពិសេស 18
**នីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ** **19**
សេចក្ដីទូទៅ 19
ការដាក់ពាក្យបណ្ដឹង 19
សេចក្ដីជូនដំណឹងពេលមានសវនាការស្ដីពីសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ 20
ភាគីគ្រប់គ្រាន់នៃសំណើសុំឲ្យមានសវនាការ 20
ការកែប្រែទៅលើសំណើសវនាការ 20
សហាគមន៍ស្រុកឆ្លើយតបទៅនឹងសំណើសវនការត្រឹមត្រូវតាមច្បាប់រដ្ឋ 20
ទំនួលខុសត្រូវរបស់ភាគីម្ខាងទៀតទៅនឹងសំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ 21
ទម្រង់បែបបទគំរូ **21**
ការផ្លាស់ប្ដូរសិស្សនៅពេលសវនាការដោះស្រាយជម្លោះត្រូវបានពន្យា **21**
ដំណើរការដោះស្រាយបញ្ហា **22**
កិច្ចប្រជុំដោះស្រាយបញ្ហា 22

រយៈពេលនៃការដោះស្រាយជម្លោះ 23
ការកែតម្រូវទៅលើរយៈពេល 30 ថ្ងៃ នៃការដោះស្រាយបញ្ហា 23
កិច្ចព្រមព្រៀងលើដំណោះស្រាយជាលាយលក្ខណ៍អក្សរ 24
រយៈពេលពិនិត្យលើកិច្ចព្រមព្រៀង 24
**សវនាការដោះស្រាយជម្លោះឥតលំអៀង 24**
ល័ក្ខខណ្ឌទូទៅ 24

ចៅក្រមច្បាប់រដ្ឋបាល (ALJ) 24
បញ្ហាពិភាក្សានៅក្នុងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ 25
រយៈពេលសម្រាប់ដាក្យពាក្យបណ្តឹង 25
ករណីលើកលែងនៃរយៈពេលដាក់ពាក្យបណ្តឹង 25
**សិទ្ធិក្នុងសវនាការ 25**
លក្ខខណ្ឌទូទៅ 25
ការបង្ហាញពត៌មានបន្ថែម 26
សិទ្ធិឪពុកម្តាយនៅក្នុងសនាការសវនាការ 26
រយៈពេល និងភាពងាយស្រួលក្នុងសវនាការ **26**
**សេចក្តីសម្រេចនៃសវនាការ 26**
សេចក្តីសម្រេចរបស់ ALJ 26
ខសន្យាលើកទឹកចិត្ត 27
បណ្តឹងដោយឡែកសម្រាប់សវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ 27
លទ្ធផល និងការសម្រេចចិត្តទៅកាន់ក្រុមប្រឹក្សា និង សាធារណៈជនទូទៅ 27
ទីបញ្ចប់នៃសេចក្តីសម្រេច **27**
**ការដាក់បណ្តឹងរដ្ឋប្បវេណី រួមទាំងរយៈពេលក្នុងការដាក់បណ្តឹង 27**
លក្ខខណ្ឌទូទៅ 27
កាលកំណត់ពេលវេលា 28
និតិវិធីបន្ថែម 28
វិធានៃការស្តាបនា 28
**ថ្លៃជួលមេធាវី 28**
លក្ខខណ្ឌទូទៅ 28
ការផ្តល់សំណងនៃការជួលមេធាវី 29
**និតិវិធីខាងវិន័យសម្រាប់សិស្សមានសិទ្ធិទទួលបានការអប់រំពិសេស 30**
**វិន័យលើការព្យួរកាសិក្សា និងការបណ្តេញចេញពីសាលា សម្រាប់សិស្សទាំងអស់ 30**
**សិទ្ធិអំណាចនៃបុគ្គលិកក្នុងសាលា 30**
ការកំណត់តាមករណីនីមួយ 30
លក្ខខណ្ឌទូទៅ 31
អំណាចបន្ថែម 31
ការផ្តល់សេវា 31
ការផ្លាស់ប្តូរថ្នាក់រៀនដោយសាការពិនត្យដកចេញ **32**
ការផ្តល់ការជូនដំណឹង 32

ការកំណត់ពីការពិត 32
ការកំណត់ដែលថាឥរិយាបថគឺជាមូលហេតុនៃពិការភាពរបស់សិស្ស 33
កាលៈទេសៈពិសេស 33

និយមន័យ 34

**ការកំណត់ទីតាំង** **34**

**សវនាការដោះស្រាយវិវាទសម្រាប់ការដាក់ពិន័យ** **34**

អំណាចរបស់ចៅក្រមច្បាប់រដ្ឋបាល (ALJ) 35

ការដាក់ថ្នាក់ឲ្យចូលរៀនក្នុងអំឡុងពេលនៃសវនាការដោះស្រាយជម្លោះបន្ទាន់ **35**

ការការពារសម្រាប់សិស្សដែលមិនទាន់មានសិទ្ធិទទួលបានការអប់រំពិសេស និង សេវាពាក់ព័ន្ធផ្សេងទៀត **36**

លក្ខខណ្ឌទូទៅ 36

ចំណេះដឹងជាមូលដ្ឋានស្តីពីវិន័យ 36

ករណីលើកលែង 36

លក្ខខណ្ឌ ដែលយកមកអនុវត្ត  បើសិនមិនមានចំណេះដឹងជាមូលដ្ឋាន 36

ការផ្ទេរបញ្ជូន និង ការចាត់វិធានការដោយមន្ត្រីអនុវត្តនៃច្បាប់ និង មន្ត្រីសមត្ថកិច្ចតុលាការ **37**

ការបញ្ជូនរបាយការណ៍ 37

លក្ខខណ្ឌសម្រាប់ការប្តូរថ្នាក់រៀនជាសឯកតោភាគីដែលសម្រេចឡើងដោយឪពុកម្តាយរបស់សិស្សទៅក្នុងសាលាឯកជនដែលរ៉ាប់រងការចំណាយដោយរដ្ឋ **37**

ការបង់ប្រាក់សងវិញសម្រាប់ការប្តូរថ្នាក់អប់រំមកសាលាឯកជន 37

ដែនកំណត់លើការបង់ប្រាក់សងវិញ 38

ធនធាន **38**

# ព័ត៌មានទូទៅ

## សេចក្តីផ្តើម

ច្បាប់ស្តីពីការអប់រំសម្រាប់ជនពិការ (IDEA)ឆ្នាំ2004 គឺជាច្បាប់សហព័ន្ធ ដែលធានាផ្តល់ការអប់រំ សាធារណៈដែលសមស្របដោយឥតគិតថ្លៃទៅចំពោះសិស្សពិការដែលត្រូវបានបញ្ជូនមក ឬដែលបានកំណត់ថាមានសិទ្ធិគ្រប់គ្រាន់ក្នុងការទទួលបានសេវាអប់រំសាធារណៈពិសេសនេះ។ IDEA តម្រូវឲ្យសាលាផ្តល់ការជូនដំណឹងដល់ឪពុកម្តាយរបស់សិស្សដែលមានសិទ្ធិទទួល ឬបញ្ជូនមកសេវាអប់រំពិសេស នូវដំណឹងដែលមានការពិពណ៌នាពេញលេញពីសិទ្ធិដែលពួកគេមាននៅក្រោម IDEA របស់សហរដ្ឋអាមេរិក នាយកដ្ឋាននីតិកម្មអប់រំ និងវិធាន OSPI ដែលគ្រប់គ្រងទៅលើការផ្តល់សេវារអប់រំពិសេស (ជំពូកច្បាប់ 392-172 ក ក្រមរដ្ឋបាលវ៉ាស៊ីងតុន (WAC) )។ ឯកសានេះអនុលោមទៅតាមគំរូនៃការជូនដំណឹងពីនីតិវិធីគាំពារ។

## តើការជូនដំណឹងនេះធ្វើឡើងសម្រាប់នរណា?

សេចក្តីជូនដំណឹងទាំងនេះគឺរៀបចំឡើងសម្រាប់មាតាបិតាអាណាព្យាបាល និងសិស្សពេញវ័យ។ វាជាឯកសាសម្រាប់អ្នកឬ "មាតាបិតា " និង "កូនរបស់អ្នក " ហើយក៏សម្រាប់អាណាព្យាបាល និងសិស្សពេញវ័យផងដែរ ។ ព័ត៌មាននៅក្នុងសេចក្តីជូនដំណឹងនេះក៏សម្រាប់ "សាលាក្នុងក្រុង" ឬ" ក្រុង" ដោយរួមបញ្ចូលភ្នាក់ងារសាធារណៈផ្សេងទៀត ព្រមទាំងក្រុងដែលផ្តល់សេវាអប់រំ (ESDs) បើសិនជាស្ថាប័នទាំងនេះផ្តល់សេវាអប់រំពិសេសដល់កូនរបស់អ្នក។ សាលាក្រុង (School District) ដែលផ្តល់សេវាអប់រំពិសេសដល់កូនរបស់អ្នក គឺតម្រូវដោយច្បាប់ IDEA ឲ្យផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍ អក្សរអំពីនីតិវិធីគាំពាររបស់អ្នក និងផ្តល់ធនធានផ្សេង ដើម្បីជួយអ្នកឲ្យយល់ដឹងពីសេវានេះ។

## ការផ្តល់ការអប់រំជាសាធារណៈ ដែលមានលក្ខណៈសមស្របដោយឥតគិតថ្លៃ (FAPE)

ក្រោមច្បាប់ IDEA ការផ្តល់ការអប់រំជាសាធារណៈ ដែលសមស្របដោយឥតបង់ថ្លៃ (FAPE) នេះមានន័យថា សេវាអប់រំពិសេស និងសេវាចាំបាច់ដែលពាក់ព័ន្ធ ផ្សេងទៀតដើម្បី ឲ្យកូនរបស់អ្នក ទទួលអត្ថប្រយោជន៍ ពីការសិក្សារបស់ពួកគេ ។ ក្នុងករណីដែលកូនរបស់អ្នកមានសិទ្ធិពេញលេញ ពួកគេអាចទទួលសេវាអប់រំពិសេសពីអាយុ 3ឆ្នាំ រហូតដល៏អាយុ 21ឆ្នាំ។ កូនរបស់ អ្នកនឹងមិនអាចនៅក្នុងសេវាកម្មអប់រំពិសេសទៀតនោះទេ បើសិនជាការសម្រេចនិងការវាយតម្លៃកំនត់ឃើញថាមិនមានសិទ្ធិទទួលសេវាកម្មពិសេសនេះបន្តទៅទៀត ឬនៅពេលពេលដែលពួកគេ បញ្ចប់ការសិក្សាដោយមានវិញ្ញាបនប័ត្រវិទ្យាល័យត្រឹមត្រូវមុនពេលពួកគេមានអាយុ 21ឆ្នាំ។ បើសិនជាកូនរបស់អ្នក មានអាយុ ២១ឆ្នាំ ក្រោយ ថ្ងៃ ទី31 ខែសីហា ពួកគេនៅតែមានសិទ្ធិទទួលសេវានេះរហូតដល់ចុងឆ្នាំសិក្សានោះ។ លោកអ្នកអាចដកយកនូវការព្រមព្រៀងមិនឲ្យកូនអ្នក ទទួលសេវាអប់រំពិសេស ឬសេវាពាក់ព័ន្ធ ដទៃផ្សេងទៀតបាន។ ចំពោះសិស្សដែលជាប់ឃុំនៅមណ្ឌលកែប្រែដែលមានសិទ្ធិទទួលសេវាអប់រំពិសេសនេះ មានសិទ្ធិនៅក្នុងសេវា FAPE រហូតដល់ពួកគេមានអាយុ 18ឆ្នាំ។ FAPE នឹងធ្វើការតាមដានលើសកម្មភាពរបស់កូនអ្នក ដូចមានរៀបរាប់ក្នុងកម្មវិធីអប់រំបុគ្គល (IEP)។

## សម្រាប់ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែមស្តីពីសេវាអប់រំពិសេស និងនីតិវិធីគាំពារ សូមទាក់ទងនាយកគ្រប់គ្រងសាលាក្នុងតំបន់ ឬនាយកកម្មវិធីអប់រំពិសេស មជ្ឈមណ្ឌលបណ្តុះបណ្តាលមាតាបិតា និងផ្តល់ព័ត៌មានរបស់រដ្ឋ កម្មវិធីភាពជាដៃគូសម្រាប់សកម្មភាពផ្តល់សិទ្ធិអំណាច (Washington Pave)

ឬ តាមរយៈ  OSPI ។ OSPI នៅតែប្រើគេហទំព័រសេវាអប់រំពិសេសដែលមានគេហទំព័រ  [WWW.k12.wa.us/specialed](http://WWW.k12.wa.us/specialed) ។ OSPI មានប្រធានគ្រប់គ្រងកម្មវិធី  និងមន្ត្រី ស៊ើបអង្កេតខ្ញុំតសម្រាប់សេវាអប់រំពិសេសដើម្បីជួយលោកអ្នកជាមួយសំនួរផ្សេង អំពីកម្មវិធីសិក្សាពិសេសសម្រាប់កូនរបស់អ្នក។ លោកអ្នកអាចទំនាក់ទំនងមកកាន់ OSPI សេវាអប់រំពិសេសតាមរយៈលេខទូរស័ព្ទ  (360) 725-6075 TTY (360)586-0126 ឬ តាមរយៈអ៊ីម៉ែល  speced@k12.wa.us.

## សេចក្តីជូនដំណឹងស្តីពីនីតិវិធីគាំពា

**<u>34 CFR § 300.504; WAC 392-172A-05015</u>**

**អ្នកមានសិទ្ធទទួលបានការជូនដំណឹងនេះមួយឆ្នាំមួយដង និងនៅពេលជាក់លាក់ផ្សេងទៀត។**

សេចក្តីជូនដំណឹងនេះនឹងត្រូវប្រគល់ជូនអ្នក (1) មួយដងក្នុងមួយឆ្នាំសិក្សា និង  (2) នៅពេលមានការបញ្ជូនមកជាលើកដំបូង ឬនៅពេលមានការស្នើសឲ្យធ្វើការវាយតម្លៃ (3) នៅពេលទទួលបានពាក្យបណ្តឹងសម្រាប់សេវាអប់រំពិសេសដល់ពលរដ្ឋជាលើកទីមួយ នៅក្នុងឆ្នាំសិក្សាមួយឆ្នាំ (4) នៅពេលទទួលបានសំណើនីតិវិធីសវនាការដំបូងក្នុងមួយឆ្នាំសិក្សា (5) នៅពេលមានការសម្រេចចាត់វិធានការដាក់ពិន័យដែលធ្វើឲ្យមានការផ្លាស់ប្តូរទីកន្លែង និង (6) នៅពេលមានការស្នើសុំពីលោកអ្នក ។

សេចក្តីជូនដំណឹងពីនីតិវិធីគាំពារនេះ  មានការពិពណ៌នាពេញលេញស្តីពីនីតិវិធីគាំពារដែលពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរ  ទីតាំងកូនរបស់អ្នកជាឯកតោភាគីទៅសាលាឯកជន នៅក្រោមការចំណាយរបស់រដ្ឋ និងក្រោមនីតិវិធីបណ្តឹងសេវាអប់រំ ពិសេសសម្រាប់ពល់រដ្ឋកិច្ចព្រមព្រៀង ដែលមានផ្តល់ព័ត៌មាន នីតិវិធីគាំពារដែលមាននៅក្នុងអនុផ្នែក ង  នផ្នែក ខ បញ្ញត្តិ IDEA និងច្បាប់ស្តីពីការលាក់ការព័ត៌មាន សម្ងាត់ ដែលមាននៅក្នុងអនុផ្នែក ច  ន ផ្នែក ខ បញ្ញត្តិ IDEA ។ ក្រុងទាំងអស់ត្រូវជ្រើសរើសក្នុងការប្រើប្រាស់ព័ត៌មាននេះឬបង្កើតព័ត៌មាននីតិគាំពារដោយខ្លួនឯង និងសម្រាប់ជូនដល់មាតាបិតាសិស្ស។

## <u>ការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន</u>

**<u>34 CFR §300.503; WAC 392-172A-05010</u>**

**អ្នកមានសិទ្ធិទទួលព័ត៌មានជាលក្ខណ៍អក្សរ  ដែលពិព័ណ៌នាអំពីសាលាក្នុងក្រុងរបស់អ្នកឬអំពីអ្វីដែលសាលាមិនធ្វើដែលប៉ះពាល់ដល់តម្រូវការកូនរបស់អ្នកក្នុងការទទួលសេវាអប់រំពិសេស។**

សាលាក្នុងក្រុងត្រូវផ្តល់ព័ត៌មានដល់អ្នកជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្តសំខាន់ដែលប៉ះពាល់ដល់កម្មវិធីអប់រំពិសេសសម្រាប់កូនរបស់អ្នក ។ ទាំងនេះត្រូវបានហៅថា ការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ហើយវាជាឯកសាដែលឆ្លុះបញ្ចាំងពីការសម្រេចចិត្ត  ដែលបានធ្វើឡើងនៅក្ន ងកិច្ចប្រជុំ ឬដោយសាលាក្រុងដើម្បីឆ្លើយតបទៅនឹងសំណើររបស់អ្នក។ សាលាក្រុងត្រូវជូនដំណឹងជាលាយលក្ខណ៍ដលអ្នកជាមុនបន្ទាប់ពីមានការសម្រេចចិត្តប៉ុន្តែ មុនពេលយកការសម្រេចទាំងនោះមកអនុវត្ត ។ នេះគឺជាការសម្រេចចិត្ត ដែលទាក់ទងទៅនឹងរាល់សំណើរនិងការបដិសេធក្នុងការចាប់ផ្តើម ឬផ្លាស់ប្តូរអត្តសញ្ញាណ ការវាយតម្លៃការផ្លាស់ប្តូរទីតាំង ឬការផ្តល់ FAPE ដល់កូនរបស់អ្នក។ សេចក្តីជូនដំណឹងជាមុនជាលាយលក្ខណ៍អក្សររួមមាន :

- អ្វីដែលសាលាក្រុងកំពុងឆ្លើយតប ឬបដិសេធមិនធ្វើ
- សេចក្តីពិព័ណ៌នាពីមូលហេតុដែលសាលាក្រុងធ្វើការឆ្លើយតប ឬបដិសេធក្នុងការចាត់វិធានការ

- ការពិពណ៌នាពីជម្រើសផ្សេងទៀតដែលពិចារណាដោយក្រុម IEP និងមូលហេតុក្នុងការបដិសេធជម្រើសទាំងនោះ
- ការពិពណ៌នាពីនីតិវិធីនៃការវាយតម្លៃ ការប៉ាន់ប្រមាណ ការកត់ត្រា ឬការរាយការណ៍ ប្រើជាមូលដ្ឋាននៃសកម្មភាពនោះ
- ការពិពណ៌នាពីកត្តាដែលពាក់ព័ន្ធផ្សេងទៀតទៅនឹងសកម្មភាព
- ការពិពណ៌នាពីនីតិវិធីនៃការវាយតម្លៃដែលសាលាក្រុងមានដើម្បីចាប់ផ្តើមការវាយតម្លៃដំបូង និងការវាយតម្លៃសាជាថ្មីផ្សេងទៀត
- សេចក្តីថ្លែងការដែលមាតាបិតាទទួលការការពារដោយនីតិវិធីគាំពារដែលបានចែងនៅក្នុងកូនសៀវភៅនេះ
- របៀបដែលអ្នកអាចទទួលបានកូនសៀវភៅស្តីពីសេចក្តីជូនដំណឹងពីនីតិវិធីគាំពារ បើសិនជាមិនមានអ្នកណាផ្តល់ជូនអ្នក និង
- ប្រភពផ្សេងសម្រាប់អ្នកធ្វើការទាក់ទងដើម្បីទទួលជំនួយក្នុងការយល់ដឹងពីនីតិវិធីគាំពារទាំងនេះ។

ស្ថានភាពនៃពេលវេលាដែលអ្នកនឹងទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនគឺ :

- កូនរបស់អ្នកត្រូវបានបញ្ជូនទៅក្នុងកម្មវិធី ដោយការសង្ស័យពីពិការភាព និងតម្រូវការសក្តានុពលសម្រាប់ការអប់រំពិសេស។
- សាលាក្រុងចង់ធ្វើការវាយតម្លៃឬវាយតម្លៃសាជាថ្មីទៅលើកូនរបស់អ្នកឬសាលាក្រុងបដិសេធមិនធ្វើការវាយតម្លៃឬវាយ (សាជាថ្មី) ទៅលើកូនរបស់អ្នក ។
- IEP ឬការផ្លាស់ប្តូរទីកន្លែងរបស់កូនអ្នកមានការផ្លាស់ប្តូរ ។
- អ្នកស្នើសុំឲ្យមានការផ្លាស់ប្តូរ និងសាលាក្រុងបដិសេធមិនធ្វើការផ្លាស់ប្តូរ។
- អ្នកជូនដំណឹងដល់សាលាក្រុងជាលាយលក្ខណ៍អក្សរថាអ្នកដកការព្រមព្រៀងមិនឲ្យកូនរបស់អ្នកទទួលសេវាអប់រំពិសេស។

ការផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរជាមុនគឺនឹងផ្តល់ជូនដោយប្រើភាសាកំណើតរបស់អ្នក ឬការប្រាស្រ័យទាក់ទងផ្សេងទៀតដែលអ្នកប្រើប្រាស់ ដូចជាភាសាសញ្ញា (ភាសាមនុស្សគ) ជាដើម លើកលែងតែវាបង្ហាញយ៉ាងច្បាស់ថាមិនអាចធ្វើដូច្នោះបាន។

បើសិនជាភាសាកំណើតរបស់អ្នក ឬមធ្យោបាយផ្សេងទៀតនៃការប្រាស្រ័យទាក់ទងមិនមែនជាភាសាសរសេរ សាលាក្រុងត្រូវចាត់វិធានការដើម្បីធានាថា (1) សេចក្តីជូនដំណឹងគឺត្រូវបានបកប្រែដោយផ្ទាល់មាត់ ឬដោយមធ្យោបាយផ្សេងទៀតដោយប្រើភាសាបស់អ្នក ឬមធ្យោបាយនៃការប្រាស្រ័យទាក់ទងផ្សេងទៀត (2) អ្នកយល់ពីការព្រមព្រៀងនៅក្នុងសេចក្តីជូនដំណឹង (3) មានភស្តុតាងជាលាយលក្ខណ៍អក្សរដែលថាតម្រូវការទាំងអស់នេះគឺត្រូវបានបំពេញតាមយ៉ាងត្រឹមត្រូវ ។

<u>ភាសាកំណើត</u>

34 CFR §300.29; WAC 392-172A-01120

*ភាសាកំណើត* នៅពេលប្រើប្រាស់ជាមួយបុគ្គលដែលកម្រិតយល់ដឹងនៃភាសាអង់គ្លេសរបស់គេគឺមានដែនកំណត់នោះមានន័យដូចខាងក្រោម

1. ភាសាដែលប្រើជាទូទៅដោយបុគ្គលនោះ ឬសម្រាប់កូនក្មេង គឺជាភាសាដែលប្រើដោយមាតាបិតាក្មេងនោះ ។
2. សម្រាប់ទំនាក់ទំនងជាមួយក្មេង (រួមទាំងការវាយតម្លៃក្មេង) ភាសាដែលជាទូទៅប្រើនៅផ្ទះរបស់ក្មេង ឬបរិយាកាសសិក្សារបស់ក្មេង។

សម្រាប់បុគ្គលថ្លង់ ឬគ ឬសម្រាប់បុគ្គលដែលមិនមានភាសាសរសេរ មធ្យោបាយនៃការប្រាស្រ័យទាក់ទងគឺតាមរបៀបដែលបុគ្គលនោះ ប្រើប្រាស់ប្រចាំថ្ងៃ (ដូចជាភាសាសញ្ញា ភាសាមនុស្ស ខ្វាក់ឬការប្រាស្រ័យទាក់ទងដោយប្រើពាក្យសម្តី )។

**សាអេឡិចត្រូនិច**

**34 CFR §300.505; WAC 392-172A-05020**

ប្រសិនបើក្រុងរបស់អ្នកផ្តល់ជម្រើសដល់ឪពុកម្តាយក្នុងការទទួលឯកសាតាមរយៈអ៊ីម៉ែល លោកអ្នកអាចជ្រើសរើសទទួលសាអ៊ីម៉ែលដូចខាងក្រោម :

1. ការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន
2. សេចក្តីជូនដំណឹងស្តីពីនីតិវិធីគាំពារ និង
3. សេចក្តីជូនដំណឹងដែលទាក់ទងទៅនឹងសំណើសវនាការ

## ការព្រមព្រៀងរបស់មាតាបិតា-និយមន័យ

**34 CFR §300.9; WAC 392-172A-01040**

**សាលាក្រុងត្រូវតែទទួលការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីអ្នកជាមុន មុននឹងធ្វើការវាយតម្លៃលើកូនរបស់អ្នក ។ សាលាក្រុងត្រូវទទួលការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីអ្នកជាមុនផងដែរ មុននឹងផ្តល់សេវាអប់រំពិសេសជាលើកដំបូងដល់កូនរបស់អ្នក ។ មានករណីលើកលែងមួយចំនួនដែលត្រូវអនុវត្តដើម្បីទទួលបានការព្រមព្រៀងពីអ្នកសម្រាប់ធ្វើការវាយតម្លៃ ។**

*ការព្រមព្រៀង* មានន័យថា :

1. លោកអ្នកទទួលបានការជូនដំណឹងយ៉ាងពេញលេញជាភាសាកំណើតរបស់អ្នក ឬតាមវិធីប្រាស្រ័យទាក់ទងផ្សេងទៀត ដូចជាភាសា ជាសញ្ញា ភាសាមនុស្សខ្វាក់ ឬតាមការទំនាក់ទំនងផ្ទាល់មាត់ លើគ្រប់ព័ត៌មានទាំងអស់ដែលទាក់ទងទៅនឹងសកម្មភាពដែលលោកអ្នកផ្តល់ការព្រមព្រៀង។
2. លោកអ្នកព្រមព្រៀង និងទទួលស្គាល់ជាលាយលក្ខណ៍ អក្សរចំពោះសកម្មភាពទាំងនោះ ហើយការព្រមព្រៀងនោះពិព័ណ៌នាពីសកម្មភាព និងរាយនូវរបាយការណ៍ (បើសិនជាមាន) ដែលនឹងជូន និងប្រគល់ជូន ហើយ
3. លោកអ្នកយល់ដឹងថាការ ព្រមព្រៀងគឺធ្វើឡើងដោយស្ម័គ្រចិត្ត ហើយលោកអ្នកអាចលុប (ដក) ការព្រមព្រៀងរបស់លោកអ្នកចេញបានគ្រប់ពេលវេលា។

ទោះជាយ៉ាងនេះក្តី ការដកចេញនៃការព្រមព្រៀងរបស់លោកអ្នកនឹងមិនកែប្រែដល់សកម្មភាពដែលបានចាប់ផ្តើមបន្ទាប់ពីលោកអ្នកបានផ្តល់ការព្រមព្រៀង និងមុនពេលលោកអ្នកដកវាចេញឡើយ ។ នេះមានន័យថា ប្រសិនបើលោកអ្នកបាន ព្រមព្រៀងឲ្យកូនលោកអ្នកទទួលសេវាអប់រំពិសេស ហើយក្រោយមកបដិសេធវិញដោយមិនអនុញ្ញាតឲ្យសាលាស្តូលឌីសស្រ្ទិកផ្តល់សេវាអប់រំពិសេសដល់កូនរបស់លោកអ្នក នោះសាលាស្គូលឌីសស្រ្ទិកនឹងមិនតម្រូវដោយច្បាប់ណាមួយឲ្យធ្វើការកែប្រែលើកំណត់ត្រាអប់រំរបស់កូនលោកអ្នកដើម្បីដកនូវឯកសាយោងណាមួយចំពោះការទទួលនៃសេវាអប់រំពិសេសរបស់កូនលោកអ្នកឡើយ ។

## ការយល់ព្រមរបស់ឪពុកម្តាយ—លក្ខខណ្ឌ

**34 CFR §300.300; WAC 392-172A-03000**

## ការយល់ព្រមសម្រាប់ការវាយតម្លៃជាលើកដំបូង

សាលាស្តូលឌីសស្រ្ទីករបស់លោកអ្នក មិនអាចធ្វើការវាយតម្លៃជាលើកដំបូងទៅលើកូនរបស់លោកអ្នកដើម្បីកំណត់ពីសិទ្ធិទទួលបានសេវាអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងទៀតនោះឡើយ ដរាបណាសាលាមិនទាន់បានផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរជាមុន ដល់លោកអ្នកដែលពិពណ៌នាពីសកម្មភាពវាយតម្លៃដែលបានស្នើឡើង និងទទួលបានការព្រមព្រៀងពីអ្នកនោះ។

ការព្រមព្រៀងរបស់លោកអ្នកសម្រាប់ការវាយតម្លៃជាលើកដំបូង មិនមែនមានន័យថា លោកអ្នកផ្តល់ការព្រមព្រៀងឲ្យសាលាស្តូលឌីសស្រ្ទីកចាប់ផ្តើមផ្តល់សេវាអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងទៀតដល់កូនរបស់លោកអ្នកនោះទេ។ សាលាត្រូវទទួលការព្រមព្រៀងពីលោកអ្នកជាមុនដើម្បីឲ្យសាលាផ្តល់សេវាអប់រំពិសេស និងសេវាពាក់ព័ន្ធ ផ្សេងទៀតដល់កូនរបស់អ្នក។

ប្រសិនបើកូនលោកអ្នកចុះឈ្មោះចូលរៀននៅសាលារដ្ឋ ឬកំពុងស្វែងរកការចុះឈ្មោះកូននៅក្នុងសាលារដ្ឋ ហើយលោកអ្នកបានបដិសេធក្នុងការព្រមព្រៀង ឬលោកអ្នកខកខានមិនបានឆ្លើយតបនឹងសំណូមពរដើម្បីផ្តល់ការព្រមព្រៀងសម្រាប់ការវាយតម្លៃជាលើកដំបូង នោះសាលាឌីសស្រ្ទីករបស់លោកអ្នក អាចព្យាយាមក្នុងការទទួលបានការព្រមព្រៀងពីអ្នក ប៉ុន្តែ មិនមែនជាការតម្រូវដោយច្បាប់ ដោយការប្រើប្រាស់មធ្យោបាយសម្របសម្រួល ឬតាមនីតិវិធីសវនាការ ដូចបានរៀបរាប់នៅផ្នែកខាងក្រោយក្នុងសេចក្តីជូនដំណឹងនេះ។ សាលាឌីសស្រ្ទីក របស់លោកអ្នកនឹងមិនបំពានករណីកិច្ចរបស់ខ្លួនក្នុងការស្វែងរក កំណត់អត្តសញ្ញាណ និងវាយតម្លៃកូនរបស់លោកអ្នកនោះទេ បើសាលាជ្រើសរើសមិនបន្តការវាយតម្លៃកូនលោកអ្នកនៅក្នុងកាលៈទេសៈនេះ។

## វិធានពិសេសសម្រាប់ការវាយតម្លៃជាលើកដំបូងទៅលើកុមារស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ

បើសិនជាកូនលោកអ្នកជាកូនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ហើយមិនបានរស់នៅជាមួយអ្នក នោះ ស្តូលឌីសស្រ្ទីកមិនចាំបាច់ ត្រូវការការព្រមព្រៀងពីលោកអ្នកសម្រាប់ការវាយតម្លៃលើកដំបូងដើម្បីកំណត់សិទ្ធិអាចទទួលបានការអប់រំពិសេសនោះឡើយ បើសិនជា :

1. សាលាមិនអាចរកអ្នកឃើញ ទោះបីជាសាលាព្យាករណ៍យ៉ាងណាក៏ដោយ។
2. សិទ្ធិជាឪពុកម្តាយរបស់អ្នក ត្រូវបានកាត់ផ្តាច់ដោយផ្អែកតាមច្បាប់រដ្ឋ **ឬ**
3. តុលាការបានផ្ទេរសិទ្ធិស្តីពីការសម្រេចចិត្ត លើផ្នែកអប់រំ និងការព្រមព្រៀងចំពោះការវាយតម្លៃទៅឲ្យបុគ្គលដទៃដែលមិនមែនអ្នក។

*កុមារដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ* ដូចដែលបានប្រើនៅក្នុង IDEA មានន័យថា ជាកុមារដែលជា :

1. កូនចិញ្ចឹមដែលមិនរស់នៅជាមួយឪពុកម្តាយចិញ្ចឹម
2. កុមារស្ថិតនៅក្រោមការគ្របគ្រងរបស់រដ្ឋ ក្រោមច្បាប់រដ្ឋវ៉ាស៊ីនតុន ឬ
3. កុមារស្ថិតនៅក្រោមការគ្រប់គ្រង នៃនាយកដ្ឋានសេវាសុខភាព សង្គម និងរដ្ឋបាលគ្រប់គ្រងកុមារ។

*កុមារដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ* មិនរាប់បញ្ចូលកូនចិញ្ចឹម ដែលមានឪពុកម្តាយចិញ្ចឹមនោះទេ។

## ការព្រមព្រៀងរបស់ឪពុកម្តាយសម្រាប់សេវាដំបូង និងការលុបចោលការព្រមព្រៀងសម្រាប់សេវាបន្ត

សាលាឌីស្រ្ទីករបស់លោកអ្នកត្រូវតែទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នក ឬត្រូវតែខិតខំព្យាយាមដ៏សមហេតុសមផលដើម្បីទទួលបានការយល់ព្រមពីអ្នក មុននឹងធ្វើការផ្តល់សេវាអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងទៀតទៅដល់កូនរបស់អ្នកសម្រាប់រយៈពេលលើកដំបូង។

ប្រសិនបើលោកអ្នកមិនធ្វើការឆ្លើយតបទៅនឹងសំណូមពរក្នុងការផ្តល់ការយល់ព្រមសម្រាប់កូនរបស់លោកអ្នកដើម្បីទទួលសេវាអប់រំពិសេស ឬសេវាពាក់ព័ន្ធ ផ្សេងទៀតសម្រាប់រយៈពេលលើកដំបូង ឬប្រសិនបើលោកអ្នកបដិសេធមិនផ្តល់ការព្រមព្រៀងទេ នោះសាលាស្គូលឌីស្ត្រីរបស់លោកអ្នកនឹងមិនប្រើនីតិវិធីសមស្របដើម្បីព្យាយាមទទួលការព្រមព្រៀងរបស់អ្នក ឬប្រើនីតិវិធីសវនាការដើម្បីទទួលសេចក្តីសម្រេចពីចៅក្រមរដ្ឋបាល ដើម្បីផ្តល់សេវាអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងទៀតដល់កូនលោកអ្នកនោះឡើយ។

ប្រសិនបើលោកអ្នកបដិសេធ ឬមិនឆ្លើយតបទៅនឹងសំណូមពរដើម្បីផ្តល់ការព្រមព្រៀងឲ្យកូនរបស់អ្នកទទួលសេវាអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងទៀតសម្រាប់រយៈពេលដំបូងទេនោះ ស្គូលឌីស្ទ្រីក នឹងមិនផ្តល់សេវាអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងដល់កូនលោកអ្នកនោះទេ ។ ក្នុងស្ថានភាពនេះ សាលាស្គូលឌីស្ទ្រីករបស់លោកអ្នក :

1. មិនបានប្រព្រឹត្តិល្មើសទៅនឹងលក្ខខណ្ឌ ក្នុងការផ្តល់សេវាអប់រំសាធារណៈដែលសមរម្យ (FAPE) សម្រាប់កូនលោកអ្នក ដោយសារតែការខកខានក្នុងការផ្តល់សេវាទាំងនោះឲ្យកូនលោកអ្នកនោះឡើយ **ហើយ**
2. នឹងមិនមានការតម្រូវដោយច្បាប់ឲ្យមានកិច្ចប្រជុំ IEP ឬបង្កើត IEP សម្រាប់កូនរបស់អ្នកទទួលបានសេវាអប់រំពិសេស និងសេវាពាក់ព័ន្ធ ផ្សេងទៀតដោយសារតែការស្នើសុំការព្រមព្រៀងពីអ្នកនោះដែរ។

## នៅពេលដែលលោកអ្នកផ្តល់កិច្ចព្រមព្រៀងឲ្យកូនលោកអ្នកទទួលសេវាអប់រំពិសេស និងសេវាពាក់ព័ន្ធ ផ្សេងទៀតហើយនោះ ហើយនៅពេល ដែលសាលាចាប់ផ្តើមផ្តល់សេវាអប់រំពិសេសដល់កូនរបស់លោកអ្នក នោះកូនលោកអ្នកនឹងនៅតែទទួលបានសេវានោះរហូតទាល់តែ

1. ពួកគេបានទទួលការវាយតម្លៃឡើងវិញ ហើយរកឃើញថាមិនមានសិទ្ធិទទួលសេវាអប់រំពិសេសបន្តទៀត
2. ពួកគេបញ្ចប់ការសិក្សាដោយមានសញ្ញាប័ត្រវិទ្យាល័យត្រឹមត្រូវ
3. ពួកគេមានអាយុ២១ឆ្នាំ (ឬ បើសិនជាកូនរបស់លោកអ្នកមានអាយុ២១ឆ្នាំបន្ទាប់ពី ថ្ងៃ ទី៣១ខែសីហា នោះពួកគេនៅតែមានសិទ្ធិទទួលបាន សេវានោះរហូតដល់ចុងឆ្នាំសិក្សា ) **ឬ**
4. លោកអ្នកដកកិច្ចព្រមព្រៀងពីសាលាមិនឲ្យកូនលោកអ្នកបន្តទទួលសេវាអប់រំពិសេសបន្តទៀត ។

បើសិនជាអ្នកដកកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរសម្រាប់ការបន្តផ្តល់សេវាអប់រំពិសេស បន្ទាប់ពីសាលាចាប់ផ្តើមផ្តល់សេវាអប់រំពិសេសនោះ សាលានឹងផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍ អក្សរជាមុន អំពីពេលវេលាសមរម្យដែលនឹងត្រូវបញ្ចប់ការផ្តល់សេវាអប់រំពិសេសដល់កូនរបស់អ្នក។ ការជូនដំណឹងជាលក្ខណ៍អក្សរជាមុនរួមមាន កាលបរិច្ឆេទដែលសាលានឹងបញ្ចប់ការផ្តល់សេវាអប់រំពិសេសដល់កូនរបស់ អ្នក ហើយនឹងជំរាបអ្នកថា សាលា

1. មិនបានប្រព្រឹត្តិល្មើសទៅនឹងលក្ខខណ្ឌ ក្នុងការផ្តល់សេវាអប់រំសាធារណៈ ដែលសមរម្យ (FAPE) សម្រាប់កូនលោកអ្នក ដោយសារតែ ការខកខានក្នុងការផ្តល់សេវាទាំងនោះ ឲ្យកូនលោកអ្នកនោះឡើយ ហើយ

2. នឹងមិនមានការតម្រូវដោយច្បាប់ឲ្យមានកិច្ចប្រជុំ IEP ឬបង្កើត IEP សម្រាប់កូនរបស់អ្នកទទួលបានសេវាអប់រំពិសេស និងសេវាពាក់ព័ន្ធ ផ្សេងទៀតដោយសារតែការស្នើសុំការព្រមព្រៀងពីអ្នកនោះដែរ។

សាលានឹងមិនប្រើសវនាការដើម្បីបដិសេធទៅចំពោះការផ្តល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់អ្នក ឬប្រើប្រាស់អ្នកសម្របសម្រួល ដើម្បីទទួលបានការព្រមព្រៀងបន្តផ្តល់សេវាអប់រំពិសេសដល់កូនរបស់លោកអ្នកនោះទេ ។ បន្ទាប់ពីសាលាបញ្ចប់ការផ្តល់សេវាអប់រំពិសេសដល់កូនរបស់លោកអ្នកហើយនោះកូនរបស់អ្នកនឹងមិនចាត់ចូលក្នុងសិស្សដែលមានសិទ្ធិទទួលសេវាអប់រំពិសេសនោះទៀតទេ ហើយនឹងត្រូវស្ថិតក្រោមលក្ខខណ្ឌសិក្សាដូចគ្នាទៅនឹងសិស្សទាំងអស់នៅក្នុងសាលា ។ លោកអ្នក ឬបុគ្គលផ្សេងទៀតដែលស្គាល់កូនរបស់អ្នក រួមបញ្ចូលទាំងសាលាអាចបញ្ជូនកូនអ្នកសម្រាប់ការវាយតម្លៃដំបូងនៅពេលអនាគត។

## ការព្រមព្រៀងរបស់មាតាបិតាលើការវាយតម្លៃសាជាថ្មី

បើសិនជាមានការធ្វើតេស្ត សាជាថ្មី ដែលនឹងត្រូវធ្វើឡើងជាផ្នែកមួយនៃការវាយតម្លៃសាជាថ្មីទៅលើកូនរបស់អ្នក សាលាក្រុងរបស់អ្នកត្រូវទទួលការព្រមព្រៀងពីអ្នកជាបឋម មុននឹងធ្វើការវាយតម្លៃសាជាថ្មីទៅលើកូនរបស់អ្នក លើកលែងតែសាលាក្រុងអាចបង ្ហាញថា

1. វាត្រូវការមូលហេតុច្រើនដើម្បីទទួលបានការយល់ព្រមពីអ្នកសម្រាប់ការវាយតម្លៃឡើងវិញទៅលើកូនរបស់អ្នក **និង**
2. អ្នកមិនធ្វើការឆ្លើយតប

បើសិនជាអ្នកបដិសេធមិនព្រមព្រៀងទៅចំពោះការធ្វើតេស្ត ថ្មីដែលជាផ្នែកមួយនៃការវាយតម្លៃសាជាថ្មីទៅលើកូនរបស់អ្នកនោះទេ សាលាក្រុងអាច ប៉ុន្តែ មិនមែនជាការចាំបាច់បន្ត ការវាយតម្លៃសាជាថ្មីលើកូនរបស់អ្នកដោយប្រើប្រាស់នីតិវិធីនៃការបញ្ចុះបញ្ចូលដើម្បីទទួលបានការព្រមព្រៀងពីអ្នក ឬប្រើប្រាស់វិធានសវនាការដើម្បីបដិសេធទៅលើការមិនព្រមព្រៀងរបស់អ្នកទៅចំពោះការវាយតម្លៃឡើងវិញលើកូនរបស់អ្នក។ ក្នុងករណីនៃការវាយតម្លៃដំបូង សាលាក្រុងនឹងមិនរំលោភកាតព្វកិច្ចរបស់ខ្លួននៅក្រោម Part B នៃច្បាប់ IDEA នោះឡើយ បើសិនជាសាលា បដិសេធមិនធ្វើការវាយតម្លៃឡើងវិញដោយប្រើអ្នកសម្របសម្រួល ឬ វធានសវនាការនោះ។

## ឯកសារនៃកិច្ចខិតខំប្រឹងប្រែងដែលមានហេតុផលដើម្បីទទួលបានការព្រមព្រៀងពីមាតាបិតា

សាលារបស់អ្នកត្រូវមាន ឯកសានៃកិច្ចខិតខំប្រឹងប្រែងសមហេតុផលដើម្បីទទួលបានការព្រមព្រៀងពីអ្នក សម្រាប់ការវាយតម្លៃជាលើកដំបូង ដើម្បីផ្តល់សេវាអប់រំពិសេស និងសេវាពាក់ព័ន្ធដទៃទៀតជាលើកទីមួយ ដើម្បីធ្វើការវាយតម្លៃឡើងវិញដែលពាក់ព័ន្ធទៅនឹងការធ្វើតេស្ត ថ្មី និង ដើម្បីដឹងពីទីតាំងអាណាព្យាបាលសម្រាប់ការវាយតម្លៃជាលើកដំបូង ។ ឯកសានោះ ត្រូវមានរបាយការណបញ្ជាក់ពីគោលបំណងរបស់សាលាក្រុង នៅក្នុងករណីដូចខាងក្រោម :

1. របាយការណ៍នៃការហៅទូរស័ព្ទ ដែលហៅមក ឬដែលព្យាយាមហៅ និងលទ្ធផលនៃការហៅទាំងនោះ
2. ច្បាប់ចម្លង នៃសំបុត្រដែលបានផ្ញើទៅអ្នក និងចម្លើយឆ្លើយតបដែលទទួលបាន **និង**
3. របាយការណ៍ លំអិត នៃការចុះទៅដល់ផ្ទះ ឬកន្លែងធ្វើការរបស់អ្នក និងលទ្ធផលដែលទទួលបានពីការចុះទៅនោះ ។

## ព័ត៌មានស្តីពីការព្រមព្រៀងផ្សេងទៀត

ការព្រមព្រៀងរបស់អ្នកគឺមិនចាំបាច់នោះទេ នៅពេលដែលសាលាក្រុងអាច :

1. ពិនិត្យទិន្នន័យដែលមានស្រាប់ ជាផ្នែកមួយនៃការវាយតម្លៃ ឬការវាយតម្លៃឡើងវិញលើកូនរបស់អ្នក **ឬ**
2. ធ្វើតេស្ត ឬធ្វើការវាយតម្លៃផ្សេងទៀតទៅលើកូនរបស់អ្នក ដែលសកម្មភាពទាំងនោះត្រូវបានធ្វើឡើងទៅចំពោះកុមារទាំងអស់ផ្សេងទៀត លើកលែងតែមុនការធ្វើតេស្ត ឬការវាយតម្លៃគឺតម្រូវឲ្យមានការព្រមព្រៀងពីមាតាបិតាសិស្សទាំងអស់សិន។

សាលាក្រុងរបស់អ្នក អាចមិនប្រើការបដិសេធមិនយល់ព្រមរបស់អ្នកទៅចំពោះសេវា ឬសកម្មភាពជាក់លាក់មួយ ដើម្បីបដិសេធអ្នក ឬកូនរបស់អ្នកទៅចំពោះសេវារអត្ថប្រយោជន៍ ឬសកម្មភាពផ្សេងទៀតនោះឡើយ។

បើសិនជាអ្នកបានចុះឈ្មោះកូនរបស់អ្នកនៅសាលាឯកជនដោយការចំណាយផ្ទាល់ខ្លួន ឬបើសិនជាអ្នកបង្រៀនកូននៅផ្ទះហើយអ្នកមិនផ្តល់ការព្រមព្រៀងសម្រាប់កូនរបស់អ្នកឲ្យវាយតម្លៃជាលើកដំបូង ឬវាយតម្លៃឡើងវិញ ឬអ្នកខកខានមិនឆ្លើយតបទៅនឹងសំណូមពរនៃកិច្ចព្រមព្រៀងពីអ្នកនោះទេ សាលាក្រុងអាចមិនប្រើវិធានសម្របសម្រួលដើម្បីទទួលកិច្ចព្រមព្រៀង ឬ ប្រើវិធានសវនាការដើម្បីប្រឆាំងនឹងការបដិសេធ របស់អ្នកនោះឡើយ។

សាលាក្រុងក៏មិនមានការតម្រូវដោយច្បាប់ឲ្យពិចារណាទៅលើសិទ្ធិចំពោះកូនរបស់អ្នកទៅចំពោះការទទួលបានសេវាសមធម៌នៅសាលា ឯកជនដែល សេវាទាំងនោះគឺមានសម្រាប់មាតាបិតា ដែលដាក់កូននៅសាលាឯកជន មានសិទ្ធិទទួលសេវារអប់រំពិសេសនោះដែរ។

## ការវាយតម្លៃសេវារអប់រំឯករាជ្យ

## 34 CFR §300.502; WAC 392-172A-05005

**បើសិនជាអ្នកមិនយល់ព្រមជាមួយនឹងការវាយតម្លៃដែលធ្វើឡើងដោយសាលាក្រុងនោះទេ អ្នកមានសិទ្ធិឲ្យបុគ្គលដែលមិនធ្វើការឲ្យសាលាក្រុងវាយតម្លៃទៅលើកូនរបស់អ្នកបាន ។ ក្នុងករណីមួយចំនួន សាលាមានកាតព្វកិច្ចបង់ថ្លៃសម្រាប់ការវាយតម្លៃសេវារអប់រំឯករាជ្យ (IEE) នោះ។**

អ្នកមានសិទ្ធិទទួលបានការវាយតម្លៃសេវារអប់រំឯករាជ្យ (IEE) ទៅលើកូនរបស់អ្នក បើសិនជាអ្នកមិនយល់ព្រមជាមួយនឹងការវាយតម្លៃដែលបានធ្វើឡើងដោយសាលាក្រុងរបស់អ្នក។ បើសិនជាអ្នកស្នើឲ្យមាន IEE សាលាត្រូវផ្តល់ឲ្យអ្នកនូវព័ត៌មានអំពីទីកន្លែងដែលអ្នកនឹងទទួលបាន IEE និងលក្ខណៈវិនិច្ឆ័យរបស់សាលាដែលត្រូវអនុវត្តទៅចំពោះ IEE ទាំងនោះ។

## និយមន័យ

*ការវាយតម្លៃសេវាអប់រំឯករាជ្យ* (IEE) មានន័យថា ជាការវាយតម្លៃដែលធ្វើឡើងដោយអ្នកត្រួតពិនិត្យមានលក្ខណសម្បត្តិត្រូវ ដែលមិនបម្រើការងារនៅក្នុងសាលាដែលទទួលខុសត្រូវសម្រាប់កូនរបស់អ្នក។

*ការចំណាយសាធារណៈ:* មានន័យថាសាលាក្រុងជាអ្នកបង់លើសេវាវាយតម្លៃទាំងអស់ឬធានាថាការវាយតម្លៃនោះធ្វើឡើងដោយមិនតម្រូវឲ្យអ្នកចំណាយអ្វីនោះឡើយ។

## សិទ្ធិមាតាបិតាទៅចំពោះការវាយតម្លៃដែលបង្ហាញដោយថវិកាចំណាយសាធារណៈ:

អ្នកមានសិទ្ធិទទួលបាន IEE ទៅចំពោះកូនរបស់ដោយការចំណាយនោះ បានមកពីការចំណាយសាធារណៈ បើសិនជាអ្នកមិនយល់ព្រមជាមួយនឹងការវាយតម្លៃដែលធ្វើឡើងដោយសាលាក្រុង ដែលការធ្វើយ៉ាងនោះ ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌ ដូចខាងក្រោម :

1. បើសិនជាអ្នកស្នើឲ្យមាន IEE ទៅលើកូនរបស់អ្នកដោយប្រើថវិកាចំណាយសាធារណៈ សាលារបស់អ្នកត្រូវ នៅក្នុងរយៈពេល ១៥ ថ្ងៃ ក្នុងអំឡុងពេលនៃការស្នើសុំអនុវត្ត : (ក) រៀបចំ ឯកសារវិធានសវនាការស្នើសុំឲ្យបង្ហាញថា ការវាយតម្លៃរបស់ខ្លួនទៅលើកូនរបស់អ្នកគឺត្រឹមត្រូវ ឬថាការវាយតម្លៃទៅលើកូនអ្នកដែលអ្នកទទួលបានគឺមិនត្រូវតាមលក្ខណៈ វិនិច្ឆ័យសាលាក្រុង **ឬ** (ខ) យល់ព្រមផ្តល់ IEE ដោយប្រើថវិកាចំណាយសាធារណៈ ។
2. បើសិនជាសាលាស្នើសុំវិធានសវនាការ និងការសម្រេចជាស្ថាពរដែលបញ្ជាក់ថា ការវាយតម្លៃរបស់ខ្លួនមានភាពត្រឹមត្រូវ អ្នកនៅតែមានសិទ្ធិទទួលបាន IEE ប៉ុន្តែមិនប្រើថវិកាចំណាយសាធារណៈនោះឡើយ ។
3. បើសិនជាអ្នកស្នើសុំ IEE ទៅចំពោះកូនរបស់អ្នក សាលាអាចសាកសួរពីមូលហេតុដែលអ្នកបដិសេធចំពោះការវាយតម្លៃដែលធ្វើឡើងដោយសាលា ។ ទោះជាយ៉ាងនេះក្តី សាលារបស់អ្នកអាចមិនតម្រូវឲ្យមានការពិពណ៌នា និងមិនពន្យាពេលដោយគ្មានហេតុផលក្នុងការផ្តល់ IEE ទៅចំពោះកូនរបស់អ្នកដោយប្រើថវិកាចំណាយសាធារណៈ ឬរៀបចំឯកសាស្នើសុំវិធានសវនាការ ដើម្បីការពារទៅលើការវាយតម្លៃរបស់ខ្លួនទៅចំពោះកូនរបស់អ្នកនោះដែរ។

អ្នកមានសិទ្ធិទទួល IEE ម្តងទៅលើកូនរបស់អ្នកដោយការចំណាយថវិកាសាធារណៈ នៅពេលដែលសាលាវាយតម្លៃទៅលើកូនរបស់អ្នកដែលអ្នកមិនយល់ស្រប។

## <u>ការវាយតម្លៃដែលផ្តើមឡើងដោយមាតាបិតា</u>

បើសិនជាអ្នកទទួលបាន IEE ទៅលើកូនរបស់អ្នកដោយការចំណាយថវិកាសាធារណៈ ឬអ្នកផ្តល់ IEE ទៅចំពោះកូនរបស់អ្នកដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួន

1. សាលារបស់អ្នក ត្រូវពិចារណាពីលទ្ធផលនៃ IEE លើការសម្រេចណាមួយទាក់ទងទៅនឹងការផ្តល់ FAPE ទៅចំពោះកូនរបស់អ្នក បើសិនជាវាត្រូវតាមលក្ខណៈវិនិច្ឆ័យរបស់សាលាសម្រាប់ IEEs <u>**និង**</u>
2. អ្នក ឬសាលារបស់អ្នកអាចផ្តល់ IEE ជាភស្តុតាងនៅក្នុងវិធានសវនាការទាក់ទងទៅនឹងកូនរបស់អ្នក។

## <u>សំណើសុំការវាយតម្លៃដោយចៅក្រមច្បាប់រដ្ឋបាល (ALJ)</u>

បើសិនជា ALJ ស្នើសុំ IEE សម្រាប់កូនរបស់អ្នកជាផ្នែកមួយនៃវិធានសវនាការ ការចំណាយលើការវាយតម្លៃគឺជាថវិកាចំណាយសាធារណៈ ។

## <u>លក្ខណៈវិនិច្ឆ័យសាលា</u>

បើសិនជា IEE គឺជាថវិកាចំណាយសាធារណៈ ការវាយតម្លៃគឺ ត្រូវស្ថិតក្រោមលក្ខណៈវិនិច្ឆ័យ ដែលរួមមាន ទីតាំងនៃការវាយតម្លៃ និងលក្ខណៈសម្បត្តិ នៃអ្នកត្រួតពិនិត្យ គឺត្រូវដូចគ្នាទៅនឹងលក្ខណៈវិនិច្ឆ័យ ដែលសាលាប្រើប្រាស់នៅពេលធ្វើការវាយតម្លៃជាលើកដំបូង (ដរាបណាលក្ខណៈវិនិច្ឆ័យទាំងនោះស្របគ្នាទៅនឹងសិទ្ធិរបស់អ្នកទៅនឹង IEE )។

ក្រៅពីការពិពណ៌នាខាងលើ សាលានឹងមិនដាក់លក្ខខណ្ឌ ឬពេលកំណត់ដែលទាក់ទងទៅនឹងការទទួល IEE ដោយថវិកាចំណាយសាធារណៈនោះឡើយ។

## ការចូលរួមពីមាតាបិតា

**34 CFR §§300.322 និង 300.501; WAC 392-172A-03100 និង 05000**

**អ្នកមានសិទ្ធិក្នុងការអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំ ដែលទាក់ទងទៅនឹងតម្រូវការសេវាអប់រំពិសេសចំពោះកូនរបស់អ្នក ។**

អ្នកនឹងទទួលបានការសចូលរួមនៅក្នុងកិច្ចប្រជុំអំពីសេវាអប់រំពិសេសដែលកូនរបស់អ្នកត្រូវការ ។ កិច្ចការនេះ រួមបញ្ចូលទាំងសិទ្ធិចូលរួមពិភាក្សាលើ ព័តិមានស្តីពីការបញ្ជូនកូនរបស់អ្នក នឹងតម្រូវការរបស់គេក្នុងការវាយតម្លៃ សិទ្ធិរបស់អ្នកក្នុងការទទួលបានសេវាអប់រំពិសេស ការបង្កើត ឬការកែប្រែ IEP កូនរបស់អ្នក និងការសម្រេចធ្វើការផ្លាស់ប្តូរ ។

ទោះជាយ៉ាងនេះក្តី សាលាអាចពិភាក្សាពីបញ្ហាដែលប៉ះពាល់ដល់កម្មវិធីសិក្សាជាមួយកូនរបស់អ្នក ដោយមិនមានអ្នកចូលរួម។ ការពិភាក្សានោះរួមមាន ការរៀបចំសម្រាប់កិច្ចប្រជុំ IEP ដែលត្រូវធ្វើឡើងសំរាប់គម្រោងមេរៀន និងការសម្របសម្រួលទៅលើសេវាដែលផ្តល់ជូន។ ប៉ុន្តែ គេនឹងឯញ្ជើញអ្នកឲ្យចូលរួមនៅក្នុងកិច្ចប្រជុំដែលនឹងធ្វើការសម្រេចចិត្តទៅលើរបស់អ្នក។

## កិច្ចព្រមព្រៀងរវាងអ្នក និងសាលាទាក់ទងទៅនឹងកិច្ចប្រជុំ IEP និងការវាយតម្លៃឡើងវិញ

**34 CFR §§300.303, 300.321, 300.328; WAC 392-172A-03015, 03095 និង 03105**

## កិច្ចព្រមព្រៀងនៃកិច្ចប្រជុំ IEP

អ្នក និងសាលារបស់អ្នកអាចព្រមព្រៀងបដិសេធពិធីតិវិធីបទដ្ឋានមួយចំនួនទាក់ទងទៅនឹងការបង្កើត IEP សម្រាប់កូនរបស់អ្នក។ អ្នកនិងសាលារបស់អ្នកអាចព្រមព្រៀង :

1. ធ្វើការផ្លាស់ប្តូរទៅលើ IEP សំរាប់កូនរបស់អ្នក ដោយមិនចាំបាច់មានកិច្ចប្រជុំបន្ទាប់ពីអ្នក និងសាលាបានបង្កើត IEP ប្រចាំឆ្នាំរួចហើយ។ ការផ្លាស់ប្តូរទាំងនេះអាចធ្វើឡើងដោយការបង្កើតឯកសាជាលាយលក្ខណ៍អក្សរដើម្បីផ្លាស់ប្តូរ ឬកែប្រែ IEP សម្រាប់កូនរបស់អ្នក ដោយមិនចាំបាច់ធ្វើសេចក្តីព្រៀងទាំងស្រុងឡើងវិញនោះទេ <u>នៅពេលមានការស្នើសុំពីអ្នក</u> សាលាត្រូវធ្វើសេចក្តីព្រៀងឡើងវិញ និងផ្តល់ឲ្យអ្នកនូវច្បាប់ដែលបានធ្វើការផ្លាស់ប្តូរពី IEP សម្រាប់កូន របស់អ្នកដោយមានបញ្ចូលនូវការផ្លាស់ប្តូរមកជាមួយ។ បើសិនជាមានការផ្លាស់ប្តូរទៅចំពោះ IEP សម្រាប់កូនរបស់អ្នក សាលាត្រូវធានាឲ្យបានថា សមាជិកក្រុម IEP សម្រាប់កូនរបស់អ្នកម្នាក់បានទទួលដំណឹងពីការផ្លាស់ប្តូរនេះ។
2. ការមិនចូលរួមពីសមាជិកក្រុម IEP នៅក្នុងកិច្ចប្រជុំ IEP ទាំងស្រុង ឬដោយផ្នែកក្នុងករណី
   (a) អ្នក និងសាលា ព្រមព្រៀងជាលាយលក្ខណ៍អក្សរថាមិនចាំបាច់មានការចូលរួមពីសមាជិកក្រុម IEP ដោយសាមិនមានការពិភាក្សា ឬការផ្លាស់ប្តូរទៅលើកម្មវិធីសិក្សា និងសេវាពាក់ព័ន្ធ ផ្នែកជំនាញរបស់សមាជិកនៅក្នុងកិច្ចប្រជុំ **ឬ**
   (b) អ្នក និងសាលា **យល់ព្រម** ទៅវិញទៅមកជាលាយលក្ខណ៍អក្សរចំពោះមូលហេតុរបស់សមាជិកក្រុម IEP ក្នុងការមិនចូលរួមនៅពេលមានការពិភាក្សាពាក់ព័ន្ធ នឹងការផ្លាស់ប្តូរ ឬការពិភាក្សាពីកម្មវិធីសិក្សា ឬសេវាពាក់ព័ន្ធជំនាញរបស់សមាជិកក្រុម។ នៅក្រោមកាលៈទេសៈ បែបនេះ សមាជិក IEP ដែលមិនបានចូលរួម ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នក និង ក្រុម IEP នូវធាតុបញ្ចូលដើម្បីបង្កើត IEP មិននឹងមានកិច្ចប្រជុំ។
3. ប្រើប្រាស់មធ្យោបាយផ្សេងទៀតសម្រាប់ការចូលរួមនៅក្នុងក្រុម IEP និងកិច្ចប្រជុំផ្លាស់ប្តូរដូចជា ការប្រជុំដោយមើលរូបសម្លេងតាមវីដេអូ (Video Conference) និងកិច្ចប្រជុំតាមទូរស័ព្ទ (Conference calls)។

## កិច្ចព្រមព្រៀងលើការវាយតម្លៃឡើងវិញ

អ្នកនឹងសាលាអ្នកអាចព្រមព្រៀង :

1. ដកចេញនូវតម្រូវការក្នុងការវាយតម្លៃឡើងវិញយ៉ាងហោចណាស់ រៀងរាល់បីឆ្នាំម្តង ពីព្រោះអ្នក និងសាលាគិតថាវាជាការចាំបាច់។
2. វាយតម្លៃទៅលើកូនអ្នកច្រើនជាងម្តងក្នុងមួយឆ្នាំ ។

## ការដកចេញពីកិច្ចព្រមព្រៀង

ការដកកិច្ចព្រមព្រៀងគឺមិនមានការផ្លាស់ប្តូរ (មិនទាំមកវិញ) នូវសកម្មភាពដែលបានកើតឡើងនៅពេលបានធ្វើកិច្ចព្រមព្រៀងនោះឡើយ។ សំណើក្នុងការដកកិច្ចព្រមព្រៀងពីកិច្ចព្រមព្រៀងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

## ការផ្ទេរសិទ្ធិមាតាបិតានៅក្នុងពេលធំពេញវ័យ

**34 CFR §300.520; WAC 392-172A-05135**

នៅពេលកូនអ្នកដល់អាយុ18ឆ្នាំ ពួកគេត្រូវបានចាត់ទុកថាដល់អាយុពេញវ័យហើយ។ នេះរួមបញ្ចូលទាំងកូនសិស្សដែលស្ថិតក្នុងមន្ទីរកែប្រែ និងមន្ទីរឃុំឃាំង។" អាយុពេញវ័យ" មានន័យថា កូនរបស់អ្នកគឺត្រូវប្រព្រឹត្តិចំពោះច្បាប់ ដូចជាមនុស្សពេញវ័យ ហើយសិទ្ធិទាំងអស់នៅក្រោម IDEA ដែលផ្ទេរពីអ្នកទៅកូនអ្នក។ មានករណីមួយចំនួននៅក្នុងច្បាប់រដ្ឋដែលកូនរបស់អ្នក ត្រូវប្រព្រឹត្តិចំពោះដូចពួកគេជាមនុស្សពេញវ័យដែរ ទោះជាពួកគេមិនទាន់មានអាយុ 18ឆ្នាំ ក៏ដោយ ។ ឧទាហរណ៍ របស់វារួមមាន ដីការតុលាការឲ្យមានអត្តាធិនភាព និង រៀបការ។

បើសិនជាកូនរបស់អ្នក ត្រូវបានកំណត់ឃើញថាមិនអាចធ្វើការសម្រេចចិត្តផ្នែកអប់រំ នោះសិទ្ធិទាំងអស់នៅក្រោម IDEA នឹងមិនត្រូវផ្ទេរទៅចំពោះកូនអ្នកនោះទេ ។ ក្នុងករណីនេះ អាណាព្យាបាលផ្លូវច្បាប់ ឬអ្នកតំណាង ត្រូវធ្វើការសម្រេចចិត្តផ្នែកអប់រំ ។

រយៈពេលមួយឆ្នាំមុនពេលដែលកូនរបស់អ្នកឈានដល់អាយុ 18ឆ្នាំ IEP ត្រូវបញ្ចូលសេចក្តីថ្លែងការ ដែលសិទ្ធិទាំងអស់នៅក្រោម IDEA នឹងផ្ទេរទៅពួកគេនៅពេលគេមានអាយុ 18ឆ្នាំ ។ នៅពេលកូនរបស់អ្នកដល់អាយុពេញវ័យ សេចក្តីជូនដំណឹងពីការផ្ទេរសិទ្ធិ នេះនឹងមានប្រគល់ជូនអ្នក និងកូនរបស់អ្នក។ ហើយសេចក្តីជូនដំណឹងផ្សេងទៀតដែលតម្រូវនៅក្រោម Part B ក៏នឹងត្រូវផ្តល់ដល់អ្នក និងកូនរបស់អ្នកនោះដែរ។

## ព័ត៌មានសំងាត់

Part B របស់ IDEA ផ្តល់សិទ្ធិឲ្យអ្នកទាក់ទងនឹងរបាយការណ៍ សេវាអប់រំពិសេសសម្រាប់កូនរបស់អ្នក។ សិទ្ធិទាំងនេះគឺបន្ថែមទៅលើសិទ្ធិដែលអ្នកមាននៅក្រោមច្បាប់សិទ្ធិអប់រំគ្រួសា និងសិទ្ធិឯកជន (FERPA) ដែលជាច្បាប់ការពារព័ត៌មានសម្ងាត់ស្តីពីរបាយការណ៍សិក្សាដល់សិស្សទាំងអស់ ។

## និយមន័យ

**34 CFR §300.611; WAC 392-172A-05180**

ដូចប្រើប្រាស់នៅក្រោមចំណងជើង **ពត៌មានសម្ងាត់** :

- *ការបំផ្លាញចោល* មានន័យថាការបំផ្លាញចោលលក្ខណៈ រូបវ័ន្ត ឬការដក អត្តសញ្ញាណបុគ្គលពីព័ត៌មានដើម្បីឲ្យព័ត៌មាននោះជាព័ត៌មានដែលអាចសម្គាល់បុគ្គលបាន ។
- *របាយការណ៍អប់រំ* មានន័យថា ប្រភេទរបាយការណ៍ ដែលមាននៅក្រោមនិយមន័យនៃ " របាយការណ៍អប់រំ " នៅក្នុង 34 CFR Part 99 (បញ្ញត្តិអនុវត្តចំពោះច្បាប់សិទ្ធិអប់រំ គ្រួសា និងសិទ្ធិឯកជន លេខ 1974, 20 U.S.C. 1232g (FERPA))។
- *ភ្នាក់ងារចូលរួម* មានន័យថា ភ្នាក់ងារ ឬស្ថាប័នទាំងឡាយណាដែលប្រមូល រក្សា ឬប្រើប្រាស់ព័ត៌មានសម្គាល់អត្តសញ្ញាណបុគ្គល ឬដែលព័ត៌មាននោះស្ថិតនៅក្រោម Part B ឬ IDEA។ (ពីព្រោះឯកសារទាំងនេះផ្តោតទៅលើការចូលរួមរបស់អ្នកជាមួយសាលាក្នុងតំបន់របស់អ្នកដែលប្រើពាក្យ "school district" នៅក្នុងផ្នែកនេះ។

## ព័តមានសម្គាល់ពីបុគ្គល

## 34 CFR §300.32; WAC 392-172A-01140

*ព័តមានសម្គាល់ពីអត្តសញ្ញាណបុគ្គល* មានន័យថាព័ត៌មានដែល

(a) ឈ្មោះកូនរបស់អ្នក ឈ្មោះអ្នកដែលជាឪពុកម្តាយ ឬឈ្មោះសមាជិកគ្រួសាផ្សេងទៀត

(b) អាសយដ្ឋានកូនរបស់អ្នក

(c) អត្តសញ្ញាណសម្គាល់បុគ្គល ដូចជាលេខសន្តិសុខសង្គម កូនរបស់អ្នក ឬអត្តលេខកូនសិស្ស **ឬ**

(d) បញ្ជីឥរិយាបថបុគ្គល ឬព័ត៌មានផ្សេងទៀតដែលអាចសម្គាល់អត្តសញ្ញាណកូនរបស់អ្នកដោយមូលហេតុជាក់លាក់ណាមួយ។

## សេចក្តីជូនដំណឹងទៅមាតាបិតា

## 34 CFR §300.612; WAC 392-172A-05185

OSPI ផ្តល់ការជូនដំណឹងទៅតាមបទញ្ញត្តិរបស់ខ្លួន ដើម្បីជូនដំណឹងពេញលេញដល់អ្នកអំពីការលាក់ការសម្ងាត់ទៅ លើព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបុគ្គល ដែលរួមមាន :

1. ការពិព័ណ៌នា នៃការជូនដំណឹងដែលនឹងផ្តល់ជាភាសាកំណើតនៅក្នុងចំណោមក្រុមប្រជាជនជាច្រើនដែលរស់នៅក្នុងក្រុងវ៉ាស៊ីងតោន
2. ការពិព័ណនានៃកុមារដែលគេត្រូវរក្សានូវព័ត៌មានដែលអាចកំណត់អត្តសញ្ញាណ ប្រភេទព័ត៌មានដែលស្វែងរក វិធីសាស្ត្រ ដែលវ៉ាស៊ីងតោន មានគោលបំណងប្រើប្រាស់ដើម្បីប្រមូលព័ត៌មាន (រួមបញ្ចូលទាំងបុគ្គលដែលត្រូវប្រមូលព័ត៌មាន) និងការប្រើប្រាស់ដែលត្រូវធ្វើឡើងទៅលើព័ត៌មាន
3. សេចក្តីសង្ខេបនៃគោលនយោបាយ និងនីតិវិធីដែលសាលាត្រូវអនុវត្តតាមទាក់ទងទៅនឹងការរក្សាទុក ការបង្ហាញទៅភាគីទីពា ការទុកដាក់ និងការកំទេចព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គល **និង**
4. ការពិពណ៌នាពីសិទ្ធិនៃមាតាបិតា និងសិស្សទាំងអស់ទាក់ទងទៅនឹងព័ត៌មាននេះ រួមបញ្ចូលទាំងសិទ្ធិនៅក្រោមសិទ្ធិអប់រំ គ្រួសា និងសិទ្ធិឯកជន (FERPA) និងបទបញ្ញត្តិអនុវត្តិរបស់វានៅក្នុងផ្នែក 34 CFR Part 99 ។

មុនពេលមានសកម្មភាពកំណត់អតត្តសញ្ញាណ ទីតាំង ឬការវាយតម្លៃទូទាំងរដ្ឋ (ដែលគេស្គាល់ថា"ការស្វែងរកក្រុម") គេនឹងផ្តល់សេចក្តីជូនដំណឹង ក្នុងកាសែត ឬជូនដំណឹងតាមរយៈបណ្តាញសាព័ត៌មានផ្សេងទៀត ឬក្នុងសាចរដែលមានលក្ខណៈគ្រប់គ្រាន់ ជូនដំណឹងដល់ឪពុកម្តាយទូទាំងរដ្ឋពីសកម្មភាពដើម្បីកំណត់ទីតាំង កំណត់អត្តសញ្ញាណ និងវាយតម្លៃកុមារដែលត្រូវការសេវាអប់រំពិសេស និងសេវាទាក់ទងផ្សេងទៀត។

## សិទ្ធិក្នុងការទទួលបាន
## 34 CFR §300.613-617; WAC 392-172A-05190–05210

អ្នកមានសិទ្ធិត្រួតពិនិត្យ និងតាមដានលើរបាយការណ៍អប់រំកូនរបស់អ្នកដែលបានប្រមូលរក្សាទុក ឬប្រើប្រាស់ដោយសាលារបស់អ្នកក្រោមច្បាប់ IDEA ក្នុង Part B។ សាលាត្រូវគោរពតាមសំណើរបស់អ្នកក្នុងការត្រួតពិនិត្យ និងតាមដានលើរបាយការណ៍អប់រំកូនរបស់អ្នក ដោយមិនមានការពន្យាពេល និងមុនពេលមានកិច្ចប្រជុំដែលទាក់ទងទៅនឹង IEP ឬវិធានសវនាការមិនលំអៀង (រួមបញ្ចូលទាំងកិច្ចប្រជុំរកដំណោះស្រាយ ឬសវនាការទាក់ទងទៅនឹងការដាក់ពិន័យ) និងនៅក្នុងរណីដែលមិនលើសពី ៤៥ ថ្ងៃ បន្ទាប់ពីអ្នកបានធ្វើសំណើមក។

សិទ្ធិរបស់អ្នកក្នុងការត្រួតពិនិត្យ និងតាមដានរបាយការណ៍អប់រំរួមមាន :

1. សិទ្ធិរបស់អ្នកក្នុងការទទួលបានចម្លើយតបពីសាលាដោយលក្ខណៈសមរម្យ ទៅនឹងសំណើសម្រាប់ការអធិប្បាយ និងការបកស្រាយរបាយការណ៍នានា
2. សិទ្ធិរបស់អ្នកក្នុងការស្នើសុំឲ្យសាលាផ្តល់ជូននូវច្បាប់ចម្លងនៃរបាយការណ៍នានា បើសិនជាអ្នកមិនអាចពិនិត្យ និងតាមដានប្រកបដោយប្រសិទ្ធិភាព លើកលែងតែអ្នកទទួលបានរបាយការណ៍ទាំងនោះ **និង**
3. សិទ្ធិរបស់អ្នកក្នុងការមានអ្នកតំណាងក្នុងការត្រួតពិនិត្យ និងតាមដានរបាយការណ៍នានា។

សាលានឹងសន្មត់ថា អ្នកនឹងមានសិទ្ធិអំណាចក្នុងការពិនិត្យ និងតាមដានរបាយការណ៍ទាក់ទងទៅនឹងកូនរបស់អ្នក លើកលែងតែសាលាទទួលការណែនាំថា អ្នកមិនមានសិទ្ធិអំណាចនៅក្រោមច្បាប់ជាធរណមានរបស់រដ្ឋដែលគ្រប់គ្រងលើបញ្ហាដូចនោះក្នុងនាមជាអាណាព្យាបាលឪពុកម្តាយដែលនៅបែកគ្នា និងដែលលែងលះគ្នា។

## បញ្ជីនៃការចូលទៅប្រើប្រាស់

សាលាក្រុងនីមួយៗត្រូវរក្សាបញ្ជីនៃភាគីមានសិទ្ធិក្នុងការប្រើប្រាស់ព័ត៌មានដែលរក្សាទុកទទួលបាន ឬប្រើប្រាស់ក្រោមច្បាប់ IDEA ក្នុង Part B រួមបញ្ចូលទាំងឈ្មោះភាគី ការបរិច្ឆេទអនុញ្ញាតឲ្យចូលប្រើប្រាស់ និងគោលបំណងដែលបានផ្តល់សិទ្ធិឲ្យភាគីនោះប្រើប្រាស់របាយការណ៍ ។ សាលាគឺមិនមានការតម្រូវដោយច្បាប់ឲ្យរក្សាទុកនូវបញ្ជីចេញចូលសម្រាប់ឪពុកម្តាយ ឬនិយោជិកមានសិទ្ធិនៃសាលានោះឡើយ។

## របាយការណ៍ទៅលើក្មេងច្រើនជាងម្នាក់

បើសិនជារបាយការណ៍ ណាមួយមានព័ត៌មានសិស្សច្រើនជាងម្នាក់ អ្នកមានសិទ្ធិត្រួតពិនិត្យ និងតាមដានទៅលើតែព័ត៌មានដែលទាក់ទងនឹងកូនអ្នកតែប៉ុណ្ណោះ ឬនឹងត្រូវទទួលដំណឹងអំពីព័ត៌មានទាំងនោះ ក្នុងករណីដែលសាលាមិនអាចបង្ហាញព័ត៌មានទៅអ្នកដោយមិនបង្ហាញព័ត៌មានដែលអាចកំណត់អត្តសញ្ញាណរបស់សិស្សដទៃ។

## បញ្ជីរាយពីប្រភេទ និងទីតាំងព័ត៌មាន

បើសិនជាអ្នកស្នើសុំវា សាលាត្រូវផ្តល់ព័ត៌មាននោះទៅអ្នកជាមួយនឹងបញ្ជីនៃប្រភេទ និងទីតាំងនៃរបាយការណ៍ អប់រំដែលបានប្រមូលរក្សាទុក ឬប្រើប្រាស់ដោយសាលា ។

## ថ្លៃឈ្នួល

សាលាអាចគិតថ្លៃទៅចំពោះចំនួនរបាយការណ៍ ដែលផ្ញើជូននៅក្រោមច្បាប់ IDEA ក្នុងផ្នែក Part B បើសិនជាថ្លៃឈ្នួលនោះមិនទប់ស្កាត់សិទ្ធិរបស់អ្នកពីការប្រើសិទ្ធិយ៉ាងមានប្រសិទ្ធិភាពលើការតាមដាន និង ត្រួតពិនិត របាយការណ៍ទាំងនោះទេ ។ សាលាអាចមិនគិតថ្លៃចំពោះការស្វែងរក ឬការយកព័ត៌មានទាំងនោះនៅក្រោមច្បាប់ IDEA នោះទេ ។

## ការកែសម្រួលរបាយការណ៍ទៅតាមសំណើមាតាបិតា
## 34 CFR §300.618 – §300.621; WAC 392-172A-05125

បើសិនបើអ្នកជឿថា ព័ត៌មាននៅក្នុងរបាយការណ៍ អប់រំទាក់ទងទៅនឹងកូនរបស់អ្នកដែលបានប្រមូល ដែលរក្សាទុក ឬប្រើប្រាស់ដោយ IDEA មិនសុក្រិត យល់ខុស ឬល្មើសនឹងឯកជនភាព ឬសិទ្ធិកូនរបស់អ្នកផ្សេងទៀត អ្នកអាចសេឲ្យសាលាផ្លាស់ប្តូរព័ត៌មានទាំងនោះ។
សាលាត្រូវសម្រេចចិត្តពីការផ្លាស់ប្តូរព័ត៌មាន ទៅតាមសំណើរបស់អ្នកក្នុងរយៈពេលមួយដែលសមស្របនៅពេលទទួលសំណើពីអ្នក។

## ឱកាសកាសទៅចំពោះសវនាការ និងលទ្ធផលនៃសវនាការ

បើសិនជាសាលាបដិសេធលើការផ្លាស់ប្តូរព័ត៌មានទៅតាមសំណើរបស់អ្នក សាលាត្រូវជំរាបអ្នកពីការសម្រេចចិត្តនោះ និងផ្តល់ដំបូន្មានដល់អ្នកពីសិទ្ធិរបស់អ្នកទៅចំពោះសវនាការដែលធ្វើឡើងដោយសាលា។

អ្នកមានសិទ្ធិសួរទៅចំពោះសវនាការដើម្បីដេញដោលពីព័ត៌មាននៅក្នុងរបាយការណ៍ អប់រំកូនរបស់អ្នក ដើម្បីធានាថា វាមិនមែនមិនត្រឹម ត្រូវ យល់ខុស ឬក៏ល្មើសច្បាប់ឯកជនភាព ឬសិទ្ធិនៃកូនរបស់អ្នកផ្សេងទៀតនោះឡើយ។ សវនាការដើម្បីតវ៉ាទៅចំពោះព័ត៌មាននៅក្នុងរបាយការណ៍ អប់រំត្រូវអនុវត្ត ទៅតាមវិធានសវនាការសាលក្រមនៅក្រោម FERPA។ នេះមិនមែនជាដំណើរការសវនាការរបស់រដ្ឋស្តីពីការអប់រំពិសេសនោះទេ។

បើសិនជាសាលាសម្រេចថា ព័ត៌មានគឺមិនសុក្រិត យល់ច្រឡំ ឬល្មើសនឹងច្បាប់ឯកជនភាព ឬសិទ្ធិកូនរបស់អ្នកផ្សេងទៀតនោះ សាលាត្រូវផ្លាស់ប្តូរព័ត៌មានទាំងនោះឲ្យបានទាន់ពេលវេលា និងជូនដំណឹងពីការផ្លាស់ប្តូរនោះទៅកាន់អ្នកជាលាយលក្ខណ៍អក្សរ។

បើសិនជាសាលាសម្រេចថាព័ត៌មាននោះមិនមានលក្ខណៈមិនសុក្រិត យល់ច្រឡំ ឬល្មើសទៅនឹងសិទ្ធិឯកជន ឬច្បាប់ផ្សេងទៀតរបស់កូនអ្នកនោះទេ សាលាត្រូវជូនដំណឹងទៅកាន់អ្នកថា អ្នកមានសិទ្ធិធ្វើសេចក្តីថ្លែងការនៅក្នុងរបាយការណ៍អ
ប់រំរបស់កូនអ្នក ដោយផ្តល់មតិយោបល់ទៅលើព័ត៌មាន ឬផ្តល់មូលហេតុដែលអ្នកមិនយល់ស្របជាមួយការសម្រេចចិត្តរបស់សាលា។

បើសិនជាអ្នកជ្រើសរើសដាក់សេចក្តីថ្លែងការនៅក្នុងរបាយការណ៍ កូនរបស់អ្នក សេចក្តីថ្លែងការនោះត្រូវ :

1. រក្សាដោយសាលាជាផ្នែកមួយនៃរបាយការណ៍ កូនរបស់អ្នក ដរាបណារបាយការណ៍ ឬផ្នែកដែលតវ៉ានោះគឺត្រូវបានរក្សាទុក **និង**
2. បើសិនជាសាលាបង្ហាញរបាយការណ៍ កូនរបស់អ្នកឬផ្នែកដែលកំពុងដេញដោលទៅភាគីណាផ្សេងទៀតសេចក្តីថ្លែងការនោះ គឺត្រូវបង្ហាញទៅចំពោះភាគីនោះផងដែរ។

## <u>សេចក្ដីព្រមព្រៀងទៅចំពោះព័ត៌មានដែលអាចសម្គាល់ពីអត្តសញ្ញាណបុគ្គល</u>

**<u>34 CFR §300.622; WAC 392-172A-05225</u>**

ការផ្ដល់ព័ត៌មានដែលអាចសម្គាល់ពីអត្តសញ្ញាណបុគ្គលទៅចំពោះភាគីដទៃគឺត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីអ្នកជាមុនសិន លើកលែងតែការបង្ហាញព័ត៌មានដែលមាននៅក្នុងរបាយការណ៍អប់រំកូនរបស់អ្នកគឺអាចអនុញ្ញាតឲ្យបានដោយមិនមានការយល់ព្រមពីអ្នក នៅក្រោមច្បាប់ FERPA ។ ជាទូទៅ ការព្រមព្រៀងរបស់អ្នក គឺមិនមែនជាការតម្រូវមុនពេលព័ត៌មានដែលអាចកំណត់ពីអត្តសញ្ញាណបុគ្គលត្រូវបានប្រគល់ជូនមន្ត្រីរបស់ភ្នាក់ងារចូលរួមសម្រាប់គោលបំណងនៃកិច្ចប្រជុំដែលជាលក្ខខណ្ឌ មួយនៅក្រោមច្បាប់ IDEA ក្នុង Part B នោះទេ ។ ទោះជាយ៉ាងនេះក្ដី គេត្រូវទទួលការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីអ្នកមុនពេលបញ្ជូនបព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គលទៅមន្ត្រី របស់ភ្នាក់ងារចូលរួមដែលផ្ដល់ ឬបង់ថ្លៃសម្រាប់សេវាអន្តរកាល ។ បន្ថែមលើនេះ បើសិនជាកូនរបស់អ្នកចូលរៀនសាលាឯកជន គេត្រូវទទួលការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីអ្នកជាមុន មុនពេលបញ្ជូនព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបុគ្គលអំពីកូន អ្នកទៅកាន់មន្ត្រីក្នុងក្រុងដែលសាលាឯកជនស្ថិតនៅ និងមន្ត្រីក្នុងក្រុងដែលកូនអ្នករស់នៅ បើសិនជាអ្នកមិនមានគម្រោងចុះឈ្មោះកូនអ្នកនៅក្នុងក្រុងដែលអ្នករស់នៅ។

## <u>ការគាំពារសម្រាប់ព័ត៌មានដែលអាចកំណត់ឯត្តសញ្ញាណបុគ្គល</u>

**<u>34 CFR §300.623; WAC 392-172A-05230</u>**

សាលាក្នុងក្រុងរបស់អ្នកត្រូវការពារព័ត៌មានសម្ងាត់ ដែលអាចកំណត់អត្តសញ្ញាណបុគ្គលនៅក្នុងដំណាក់កាលប្រមូលរក្សាទុក បង្ហាញ និងកំទេចចោល។ មន្ត្រីម្នាក់នៅក្នុងសាលាត្រូវទទួលខុសត្រូវក្នុងការធានាឲ្យបានថា មានការរក្សាការសម្ងាត់ទៅលើព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គលទាំងនោះ ។ បុគ្គលទាំងអស់ដែលប្រមូល ឬប្រើប្រាស់ព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបុគ្គលត្រូវទទួលការបណ្ដុះបណ្ដាល ឬការណែនាំទាក់ទងទៅនឹងការរក្សាការសម្ងាត់នៅក្រោមច្បាប់ IDEA ក្រោម Part B និងក្រោមច្បាប់ FERPA និងនីតិវិធីរដ្ឋវ៉ាស៊ីងតោន ។

សាលាក្នុងក្រុងនីមួយៗត្រូវរក្សាសម្រាប់ការត្រួតពិនិត្យពីសាធារណៈ នូវបញ្ជីថ្មីនៃឈ្មោះ និងមុខតំណែងនៃនិយោជិតទាំងនោះនៅក្នុងភ្នាក់ងារដែលអាចចូលមកប្រើប្រាស់ព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបុគ្គល។

## <u>ការកំទេច ដកហូត និងការរក្សាទុកព័ត៌មាន</u>

**<u>34 CFR §300.624; WAC 392-172A-05235</u>**

សាលាក្នុងក្រុងរបស់អ្នក ត្រូវជំរាបអ្នក នៅពេលដែលព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបុគ្គលដែលបានប្រមូលរក្សា និងប្រើប្រាស់ មិនមែនជាតម្រូវការក្នុងការផ្ដល់សេវាអប់រំដល់កូនរបស់អ្នកទៀតនោះទេ។

នៅពេលគេលែងត្រូវការវាទៀតហើយ គេត្រូវកំទេចព័ត៌មាននោះទៅតាមការស្នើសុំរបស់អ្នក ។ ទោះជាយ៉ាងនេះក្ដី ព័ត៌មានអចិន្ត្រៃយ៍ ស្ដីពីឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ បញ្ជីវគ្គមាន វគ្គមានក្នុងថ្នាក់ ដែលបានរៀនចប់ និងឆ្នាំដែលបានរៀនរបស់កូនអ្នកអាចនឹងត្រូវរក្សាទុកដោយគ្មានពេលកំណត់ ។

ច្បាប់រដ្ឋទាក់ទងនឹងការដកហូតរបាយការណ៍ទុកគឺមាននៅក្នុងច្បាប់ RCW ជំពូក 40.14 ។ នីតិវិធីសម្រាប់រយៈពេលដែលក្រុងត្រូវរក្សារបាយ-ការណ៍ គឺមានបោះពុម្ពនៅក្នុងក្រសួងការបរទេស ក្រុងវ៉ាស៊ីងតោន នាយកដ្ឋានកលានុវត្ត និងការគ្រប់គ្រងរបាយការណ៍ ។

## នីតិវិធីនៃការដោះស្រាយជម្លោះសេវាអប់រំពិសេស

អ្នកគឺជាអ្នកចូលរួមយ៉ាងសំខាន់នៅក្នុងរាល់ទិដ្ឋភាពនៃកម្មវិធីអប់រំពិសេសសម្រាប់កូនរបស់អ្នក ។ ការចូលរួមគឺចាប់ផ្ដើមឡើងនៅពេលមានការបញ្ជូនកូនរបស់អ្នកមកជាលើកដំបូងម្ល៉េះ ។ ផ្នែក OSPI ស្ដីពីសេវាអប់រំពិសេស តែងតែជំរុញទឹកចិត្តមាតាបិតា និងសាលាក្នុងក្រុងឲ្យធ្វើការជាមួយគ្នាដើម្បីព្យាយាមដោះស្រាយភាពខ្វែងគំនិតដែលប៉ះពាល់ដល់កម្មវិធីអប់រំពិសេសសម្រាប់កូនរបស់អ្នក។ នៅពេលដែលអ្នក និងសាលាក្នុងក្រុងរបស់អ្នកមិនអាចដោះស្រាយទៅលើការខ្វែងគំនិត ជំរើសផ្លាស់ប្ដូរការ នៃការដោះស្រាយជម្លោះក៏មានជាច្រើនសម្រាប់អ្នកនោះដែរ ។ ជំរើសនោះ រួមមាន ការសម្របសម្រួល ការដាក់ពាក្យបណ្ដឹង និងវិធានសវនាការក្រោមច្បាប់រដ្ឋ ។

## ការសម្របសម្រួល
## 34 CFR § 300.506; WAC 392-172A-05060–05075

អ្នក (និងសាលាក្នុងក្រុង) អាចស្នើសុំការសម្របសម្រួលដើម្បីដោះស្រាយភាពខ្វែងគំនិតអំពីកម្មវិធីអប់រំពិសេសសម្រាប់កូនរបស់អ្នក ។ អ្នក និងសាលាក្នុងក្រុងក៏អាចបដិសេធមិនចូលរួមការសម្របសម្រួលផងដែរ។

### ទូទៅ

សេវាសម្របសម្រួលគឺមានដោយឥតគិតថ្លៃចំពោះអ្នក និងសាលាក្នុងក្រុងដើម្បីជួយដោះស្រាយបញ្ហាទាក់ទងទៅនឹងអត្តសញ្ញាណ ការវាយតម្លៃ ការផ្លាស់ប្ដូរការអប់រំ និងការផ្ដល់ FAPE ទៅកូនរបស់អ្នក និងនៅពេលដែលមានការស្នើសុំវិធានសវនាការក្រោមច្បាប់រដ្ឋ ។ ការសម្របសម្រួល គឺជាការស្ម័គ្រចិត្ត និងមិនអាចប្រើប្រាស់សម្រាប់បដិសេធ ឬពន្យាពេលទៅលើសិទ្ធិរបស់អ្នកទៅនឹងវិធានសវនាការក្រោមច្បាប់រដ្ឋ ឬបដិសេធ សិទ្ធិណាផ្សេងទៀតដែលបានផ្ដល់ជូននៅក្រោមច្បាប់ IDEA ក្នុង Part B ។
នៅពេលមានកិច្ចព្រមព្រៀងរវាងអ្នកនឹងសាលាក្នុងក្រុងហើយនោះ គឺត្រូវមានការរៀបចំឯកសានៅក្នុងកិច្ចព្រមព្រៀងនៃការសម្របសម្រួលជាលាយលក្ខណ៍អក្សរដែលត្រូវចុះហត្ថលេខាដោយអ្នក និងអ្នកតំណាងរបស់សាលាក្រុងដើម្បីក្លាយជាកិច្ចព្រមព្រៀងផ្លូវច្បាប់ ។ ការពិភាក្សាក្នុងអំឡុងពេលនៃការសម្របសម្រួលគឺត្រូវលាក់ការសម្ងាត់ និងមិនអាចយកមកប្រើប្រាស់ជាភស្តុតាងនៅក្នុងសវនាការក្រោមច្បាប់រដ្ឋ ឬវិធានរដ្ឋ ឬវេណិរបស់តុលាការសហព័ន្ធ ឬតុលាការនៃរដ្ឋវ៉ាស៊ីនតោននោះឡើយ។ សេចក្ដីនេះគឺត្រូវមានចែងជាលាយលក្ខណ៍អក្សរនៅក្នុងកិច្ច ព្រមព្រៀង ។ ទោះជាយ៉ាងនេះក្ដី កិច្ចព្រមព្រៀងស្ដីពីការសម្របសម្រួលនេះគឺអាចប្រើជាភស្តុតាង ។ កិច្ចព្រមព្រៀងស្ដីពីការសម្របសម្រួលគឺជាកាតព្វកិច្ចផ្លូវច្បាប់ និងត្រូវអនុវត្ត នៅក្រោមដែនយុត្តាធិការនៃតុលាការរដ្ឋ ឬនៅសាលាដំបូងរបស់សហរដ្ឋអាមេរិក ។

សាលាក្នុងក្រុងត្រូវបង្កើតនីតិវិធីដែលផ្តល់ជម្រើសដល់មាតាបិតាដែលមិនប្រើប្រាស់ដំណើរការសម្របសម្រួលនូវឱកាសជួប ទៅពេល និងទីតាំងដែលល្អសម្រាប់អ្នក ជាមួយនឹងភាគីដែលមិនទទួលអត្ថប្រយោជន៍ :

1. ដែលស្ថិតក្រោមកិច្ចសន្យាជាមួយស្ថាប័នជម្រើសដោះស្រាយជម្លោះ ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលមាតាបិតា និងមជ្ឈមណ្ឌលព័ត៌មាន ឬមជ្ឈមណ្ឌលសហគមន៍ ធនធានមាតាបិតានៅក្នុងរដ្ឋ <u>និង</u>
2. ដែលនឹងពិព័ណ៌នាពីឯត្ថប្រយោជន៍ និងជំរុញនូវការប្រើប្រាស់ដំណើរការសម្របសម្រួលសម្រាប់អ្នក ។

## <u>ភាពមិនលំអៀង នៃការសម្របសម្រួល</u>

ការសម្របសម្រួលគឺត្រូវធ្វើឡើងដោយបុគ្គលម្នាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនលំអៀង និងបានទទួលការបណ្តុះបណ្តាលក្នុងបច្ចេក-ទេស ប្រសិទ្ធិភាពសម្របសម្រួល ។ បុគ្គលនោះក៏ត្រូវយល់ដឹងពីច្បាប់ និងបញ្ញតិដែលទាក់ទងទៅនឹងការផ្តល់សេវាអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងទៀត។ OSPI ធ្វើកិច្ចសន្យាជាមួយនឹងភ្នាក់ងារខាងក្រៅដើម្បីធ្វើការសម្របសម្រួល ។ ភ្នាក់ងារនោះមានបញ្ជីអ្នកសម្របសម្រួល ។ អ្នកសម្របសម្រួល ត្រូវបានរៀបចំជាលក្ខណៈ ចៃដន្យ ផ្អែកលើមូលដ្ឋានហេតុផល ឬភាពមិនលំអៀងផ្សេងទៀត ។ អ្នកសម្របសម្រួល ( អាចមិនមែនជានិយោជិករបស់ OSPI ភ្នាក់ងារក្នុងក្រុងរដ្ឋ ដែលកំពុងផ្តល់សេវានានា ដោយផ្ទាល់ទៅ ចំពោះកុមារដែលស្ថិតក្រោមដំណើរការសម្របសម្រួល និង(2) មិនមានជម្លោះផលប្រយោជន៍ ជាលក្ខណៈបុគ្គល និងវិជ្ជាជីវៈ ។ ដំណាក់កាលនៃការសម្របសម្រួលគឺត្រូវបារៀបចំក្នុងលក្ខណៈទាន់ពេលវេលានៅទីតាំងដែលល្អប្រសើរសម្រាប់អ្នក និងសាលាក្រុង។

## <u>ភាពខុសគ្នារវាងការស៊ើបអង្កេតទៅលើសវនាការក្រោមច្បាប់រដ្ឋ</u>
## <u>និងបណ្តឹងរដ្ឋប្បវេណីទៅលើសេវាអប់រំពិសេស</u>

**បន្ថែមទៅលើការសម្របសម្រួល អ្នកមានសិទ្ធិប្រើប្រាស់ដំណើរការនៃការដាក់ពាក្យបណ្តឹងថ្នាក់រដ្ឋ ឬសំណើសុំវិធានសវនាការក្រោមច្បាប់រដ្ឋដើម្បីដោះស្រាយភាពខ្វែងគំនិតជាមួយសាលាក្រុង។ Part B នៃច្បាប់ IDEA និងបទញ្ញតិរដ្ឋ និងសហព័ន្ធ មាននីតិវិធីផ្សេងគ្នាសម្រាប់បណ្តឹងរដ្ឋប្បវេណីទៅលើសេវាអប់រំពិសេស និងសម្រាប់វិធានសវនការក្រោមច្បាប់រដ្ឋ ។**

បណ្តឹងរដ្ឋប្បវេណីទៅលើសេវាអប់រំពិសេសគឺអាចដាក់បណ្តឹងជាមួយ OSPI ដោយបុគ្គល ឬអង្គភាពទាំងឡាយណាដែលចោទប្រកាន់ថាសាលាក្នុងក្រុង OSPI សេវាអប់រំក្រុង ឬភ្នាក់ងារសាធារណៈណាផ្សេងទៀតដែលប្រព្រឹត្តិល្មើសចំពោះលក្ខខណ្ឌ Part B វិធានសហព័ន្ធដែលមានក្នុងច្បាប់ 34 CFR Part 300 ឬទបបញ្ញតិរដ្ឋដែលមានក្នុងជំពូក Chapter 392-172A WAC។ បណ្តឹងស៊ីវិលគឺត្រូវស៊ើបអង្កេតដោយ OSPI ដោយផ្អែកទៅលើព័ត៌មាននៃការប្រព្រឹត្តិល្មើសដែលផ្តល់ដោយបុគ្គលដែលដាក់ពាក្យបណ្តឹង និងសាលាក្នុងក្រុង ឬភ្នាក់ងារផ្សេងទៀតដែលឆ្លើយ តបទៅនឹងបណ្តឹង ។ បណ្តឹងស៊ីវិលគឺ ត្រូវធ្វើឡើងក្នុងអំឡុងពេលមួយឆ្នាំនៃការចោទ ប្រកាន់ទៅចំពោះការប្រព្រឹត្តិល្មើស។

ការស្នើសុំសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋអាចធ្វើឡើងដោយអ្នក ឬសាលាសហគមន៍ស្រុកទៅលើបញ្ហាដែលទាក់ទងទៅនឹងការស្នើ ឬការបដិសេធការចាប់ផ្តើម ឬការផ្លាស់ប្តូរអត្តសញ្ញាណ ការវាយតម្លៃ ឬការផ្លាស់ប្តូរការអប់រំសម្រាប់កូនរបស់អ្នក ឬការផ្តល់សេវាអប់រំសាធារណសមរម្យដោយឥតគិតថ្លៃ (FAPE) ទៅកូនរបស់អ្នក។ សវនាការត្រឹមត្រូវតាមច្បាប់រដ្ឋគឺ ត្រូវធ្វើឡើងដោយចៅក្រមច្បាប់រដ្ឋបាល (ALJ) ដែលប្រើប្រាស់មន្ត្រីរដ្ឋបាលសវនាការ ដែលជាងភ្នាក់ងារឯករាជ្យ ។ សវនាការ ត្រឹម ត្រូវតាមច្បាប់រដ្ឋ ជាទូទៅមានការធ្វើសក្ខីកម្ម នៃសាក្សី និងការ

បង្ហាញភស្តុតាង។ សំណើសុំឲ្យមានសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋគឺត្រូវរៀបចំក្នុងរយៈពេល ២ ឆ្នាំ នៃបទល្មើសដែលបាចោទប្រកាន់ (ដោយមានការលើកលែងមួយចំនួនទៅលើការបកស្រាយខុស ឬការរក្សាទុកព័ត៌មាន )។

រយៈពេល និងនីតិវិធីសម្រាប់បណ្តឹងរដ្ឋប្បវេណី និងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋគឺមានពណ៌នាទៅខាងក្រោម។

## នីតិវិធីបណ្តឹងរដ្ឋប្បវេណី

## 34 CFR §§300.151 – 300.153; WAC 392-172A-05025–05045

អ្នកមានសិទ្ធិដាក់ពាក្យបណ្តឹងសេវាអប់រំពិសេសជាមួយ **OSPI** ។ បណ្តឹងរបស់អ្នកត្រូវមានចុះហត្ថលេខា និងមានព័ត៌មានច្បាស់លាស់។ បណ្តឹងរបស់អ្នកត្រូវស្ថិតក្នុងកំឡុងមួយឆ្នាំនៃបទល្មើសដែលបានចោទប្រកាន់ ។

បើសិនជាអ្នក បុគ្គលណាម្នាក់ ឬអង្គការណាមួយជឿថា សាលាសហគមន៍ស្រុក OSPI ឯ ឬអង្គភាពអប់រំណាផ្សេងទៀតដែលគ្រប់គ្រងដោយ IDEA បានប្រព្រឹត្តិល្មើសទៅនឹងច្បាប់ IDEA ក្នុង Part B បទញ្ញតិអនុវត្តទៅលើ Part B ឬច្បាប់រដ្ឋដែលពាក់ព័ន្ធ អ្នកអាចដាក់ពាក្យ បណ្តឹងជាលាយលក្ខណ ទៅការិយាល័យស្នងការរដ្ឋទទួលបន្ទុកការអប់រំសាធារណ (OSPI) សេវាអប់រំពិសេស ប្រអប់សំបុត្រ 47200, Olympia, WA 98504-7200។ អ្នកត្រូវផ្តល់បណ្តឹងមួយច្បាប់ទៅសាលាសហគមន៍ស្រុក ឬភ្នាក់ងារផ្សេងទៀតដែលជាភាគីអ្នកត្រូវប្តឹង។

## ការដាក់ពាក្យបណ្តឹង

ពាក្យបណ្តឹងត្រូវមានចុះហត្ថលេខា និង ត្រូវមានព័ត៌មានដូចខាងក្រោម :

- កំណត់ហេតុដែលសាលាសហគមន៍ស្រុក ឬភ្នាក់ងារផ្សេងទៀតបានប្រព្រឹត្តិល្មើសទៅនឹងលក្ខខណ្ឌ នៃច្បាប់ IDEA ក្នុង Part B បញ្ញតិអនុវត្តទៅលើ Part B ច្បាប់ ឬបទបញ្ញតិរដ្ឋដែលពាក់ព័ន្ធ ឬកំណត់ហេតុដែលថា សាលាសហគមន៍ ស្រុក ឬភ្នាក់ងារផ្សេងទៀតមិនអនុវត្តការសម្របសម្រួល និងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយ
- ឈ្មោះ និងអសយដ្ឋានរបស់សាលាសហគមន៍ស្រុក ឬភ្នាក់ងារផ្សេងទៀត
- ឈ្មោះសិស្ស បើសិនជាពាក្យបណ្តឹងនោះគឺទៅចំពោះសិស្ស និងព័ត៌មានទំនាក់ទំនងបើសិនជាសិស្សនោះមិនមានផ្ទះសម្បែង
- ការពិពណ៌នាអំពីបញ្ហាជាមួយនឹងអំណះអំណាងពិត
- ដំណោះស្រាយលើកឡើងដើម្បីដោះស្រាយបញ្ហាទៅតាមកម្រិតដែលព័ត៌មាននេះត្រូវបានដឹង មានសម្រាប់អ្នកនៅពេលដែលអ្នកដាក់ពាក្យបណ្តឹង និង
- ឈ្មោះអាសយដ្ឋាន និងលេខទូរស័ព្ទរបស់អ្នក។

OSPI បានបង្កើតទម្រង់បែបបទដែលជាជម្រើសមួយដែលអ្នកអាចប្រើដើម្បីដាក់ពាក្យបណ្តឹង។ ទម្រង់នេះគឺមាននៅលើគេហទំព័រសេវាអប់រំពិសេសរបស់ OSPI។

បទល្មើសគឺមិនត្រូវកើតឡើងច្រើនជាងមួយឆ្នាំមុនការទទួលបានពាក្យបណ្តឹងនោះទេ។

## ការស៊ើបអង្កេតទៅលើពាក្យបណ្តឹង

បើសិនជាអ្នកដាក់ពាក្យបណ្តឹងដោយមានចុះហត្ថលេខា និងជាលាយលក្ខណ៍អក្សរ OSPI ត្រូវស៊ើបអង្កេត និងចេញសេចក្តីសម្រេចជាលាយលក្ខណអក្សរ ក្នុងរយៈពេល 60 ថ្ងៃ លើកលែងតែមានដីការឲ្យពន្យាពេល។ ក្នុងរយៈពេល ៦០ ថ្ងៃ OSPI (1) ត្រូវឲ្យសាលាសហគនស្រុកផ្តល់ចម្លើយទៅចំពោះបណ្តឹងរបស់អ្នក (2) ផ្តល់ឱកាសដើម្បីឱ្យដើមបណ្តឹងដាក់ជូនព័ត៌មានបន្ថែមអំពីការចោទប្រកាន់នៅក្នុងពាក្យបណ្តឹង (3) អាចធ្វើការស៊ើបឯង្កេតនៅនឹងកន្លែង បើសិនជា OSPI កំណត់ថាវាជាការចាំបាច់ និង (4) ពិនិត្យលើរាល់ព័ត៌មានពាក់ព័ន្ធ និងធ្វើការសម្រេចដោយ ឯករាជ្យថា តើសាលាសហគមន៍ស្រុក ឬភ្នាក់ងារដទៃទៀត ប្រព្រឹត្តិល្មើសទៅនឹងច្បាប់ IDEA ក្នុង Part B ដែរឬទេ។

## ការស៊ើបអង្កេត ការពន្យាពេល និងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ

រយៈពេលកំណត់ 60 ថ្ងៃ គឺអាចពន្យាទៀតបាន បើសិនជា (1) មានកាលៈទេសៈ លើកលេងផ្សេងទៀតកើតឡើងទាក់ទងទៅនឹងពាក្យបណ្តឹងជាក់លាក់ **ឬ** (2) អ្នក និងសាលាសហគមន៍ស្រុកព្រមព្រៀងដោយស្ម័គ្រចិត្ត ជាលាយលក្ខណ៍អក្សរដើម្បីពន្យាពេលវេលាដើម្បីដោះស្រាយលើពាក្យបណ្តឹងតាមរយៈការសម្របសម្រួល។

សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនឹងត្រូវបញ្ជូនទៅកាន់បុគ្គលដាក់ពាក្យបណ្តឹង និងសាលាសហគមន៍ស្រុក។ សេចក្តីសម្រេចនឹងលើកឡើងពីការចោទប្រកាន់នីមួយ ។ សម្រាប់ការចោទប្រកាន់នីមួយៗ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនឹងចែងពីរបកគំហើញនៃការពិត សេចក្តីសន្និដ្ឋាន មូលហេតុនាំមកនូវសេចក្តីសម្រេច និងវិធានកែតម្រូវដែលសមស្របដែលចាំបាច់សម្រាប់ដោះស្រាយពាក្យបណ្តឹង បើសិនជាបទល្មើសបានកើតឡើង។

## ដំណោះស្រាយទៅចំពោះពាក្យបណ្តឹង

នៅពេលដែល OSPI រកឃើញបទល្មើស ឬកំហុសក្នុងការផ្តល់សេវាដែលសមរម្យតាមរយៈដំណើរការនៃពាក្យបណ្តឹងរបស់ខ្លួន ការសម្រេចដោះស្រាយទៅលើ

1. របៀបដោះស្រាយចំពោះការបដិសេធទៅនឹងសេវាទាំងនោះរួមបញ្ចូលទាំងការផ្តល់ប្រាក់កាសជូនវិញឬសកម្មភាពតែតម្រូវដែលសមស្របផ្សេងទៀតទៅចំពោះតម្រូវការរបស់សិស្ស **និង**
2. ការផ្តល់សេវាអប់រំពិសេសដែលចាំបាច់ នាពេលអនាគតទៅសិស្សទាំងអស់។

## ពាក្យបណ្តឹងរដ្ឋប្បវេណី និងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋទៅលើសេវាអប់រំពិសេស

បើសិនជាពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរដែលបានទទួល ដែលវាក៏ជាប្រធានបទនៃសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ ឬបណ្តឹងដែលមានបញ្ហាជាច្រើន ហើយដែលបញ្ហាមួយ ឬច្រើននៃបញ្ហាទាំងនោះគឺជាផ្នែកនៃសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ OSPI ត្រូវទុកដោយឡែកមិនស៊ើបអង្កេត ផ្នែកផ្សេងនៃបណ្តឹងដែលកំពុងតែដោះស្រាយនៅក្នុងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋរហូតទាល់តែសវនាការនោះត្រូវបានបញ្ចប់ ។ បញ្ហាទាំងឡាយដែលមាននៅក្នុងបណ្តឹងដែលមិនមែនជាផ្នែកមួយនៃសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ គឺត្រូវយកមកដោះស្រាយតាមវេលាកំណត់របស់បណ្តឹង ។

បើសិនជាបញ្ហាមួយបានកើតឡើងនៅក្នុងបណ្តឹងត្រូវបានកាត់សម្រេចម្តងរួចហើយនៅក្នុងសវនការត្រឹមត្រូវតាមច្បាប់រដ្ឋ ទាក់ទងទៅនឹងភាគីដដែល ការសម្រេចរបស់សវនាការគឺជាកាតព្វកិច្ច ហើយ OSPI ត្រូវជូនដំណឹងដល់ដើមបណ្តឹងថា ខ្លួននឹងមិនស៊ើបអង្កេតទៅលើបញ្ហានោះទេ។

OSPI ត្រូវដោះស្រាយចំពោះបណ្តឹងដែលចោទប្រកាន់ថា សាលាសហគមន៍ស្រុកបានខកខានក្នុងការអនុវត្តសេចក្តីសម្រេចរបស់សវនាការ។

## **<u>នីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ</u>**

## **<u>៣៤ ជឈ ៣០០។៥០៧ ៖ ៣០០។៥១៣; វាជ ៣៩២-១៧២។-០៥០៨០៖០៥១២៥</u>**

**អ្នកមានសិទ្ធិស្នើទៅសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ បើសិនជាអ្នក និងសាលាសហគមន៍ស្រុកមិនអាចព្រមព្រៀងអំពីកម្មវិធីអប់រំពិសេសសំរាប់កូនរបស់អ្នក ។ សំណើសុំសវនាការរបស់អ្នក ត្រូវមានព័ត៌មានច្បាស់លាស់ ។ រយៈពេលនៃការបំពេញសំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋគឺរយៈពេលពីរឆ្នាំ (ដោយមានករណីលើកលែងមួយចំនួន )។**

## **<u>សេចក្តីទូទៅ</u>**

អ្នកឬសាលាសហគមន៍ស្រុករបស់អ្នកអាចដាក់សំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋទៅលើបញ្ហាដែលទាក់ទងទៅនឹង ការស្នើសុំ និងការបដិសេធទៅចំពោះការចាប់ផ្តើម ឬការផ្លាស់ប្តូរអត្តសញ្ញាណ ការវាយតម្លៃ ឬការផ្លាស់ប្តូរការអប់រំលើកូនរបស់អ្នក ឬការផ្តល់ FAPE ទៅកូនរបស់អ្នក។ សាលាត្រូវជូនដំណឹងទៅអ្នកអំពីសេវឥតគិតថ្លៃ ឬដែលមានតម្លៃទាប និងសេវាដែលពាក់ព័ន្ធ ដែលមាននៅក្នុងតំបន់ នៅពេលមានការស្នើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ឬនៅពេលផ្សេងទៀត បើសិនអ្នកស្នើសុំព័ត៌មាន។ សម្រាប់នីតិវិធីសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ "អ្នក" រួមបញ្ចូលទាំងមេធាវីរបស់អ្នក បើសិនជាអ្នកមានមេធាវី និង "សហគមន៍ស្រុក " រួមបញ្ចូលទាំងមេធាវីសហគមន៍ បើសិនជាសហគមន៍នោះមានមេធាវីតំណាង ។

## **<u>ការដាក់ពាក្យបណ្តឹង</u>**

ដើម្បីស្នើសុំសវនាការ អ្នក ឬសហគមន៍ស្រុកត្រូវបញ្ជូនសំណើសុំសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋទៅភាគីផ្សេងទៀត ។ សំណើនោះ ត្រូវមានមាតិការាយខាងក្រោម និងត្រូវរក្សាការសម្ងាត់ ។

អ្នក ឬសហគមន៍ស្រុក នៅពេលដែលភាគីណាមួយដាក់ពាក្យស្នើសុំត្រូវផ្តល់សំណើនោះទៅកាន់ផ្នែកសេវាធនធានរដ្ឋបាល OSPI ទៅអាសយដ្ឋានដូចខាងក្រោម :

Office of Superintendent of Public Instruction
Administrative Resource Services
Old Capitol Building
PO Box 47200
Olympia, WA  98504-7200
FAX: 360-753-4201

សំណើសុំសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋត្រូវមាន :

1. ឈ្មោះសិស្ស
2. អសយដ្ឋានទីលំនៅសិស្ស
3. ឈ្មោះសាលារបស់សិស្ស
4. មានព័តិមានទំនាក់ទំនងសិស្ស បើសិនជាសិស្សនោះជាក្មេង ឬយុវជនគ្មានផ្ទះសំបែង
5. ការពិពណ៌នាពីលក្ខណៈនៃបញ្ហា រួមបញ្ចូលទាំងសេចក្តីពិតដែលទាក់ទងនឹងបញ្ហា **និង**
6. ដំណោះស្រាយដែលបានស្នើទៅចំពោះការដោះស្រាយបញ្ហាដែលអ្នកដឹង និងមានសម្រាប់អ្នក ឬសហគមន៍ស្រុកនៅពេលនោះ។

## សេចក្តីជូនដំណឹងពេលមានសវនាការស្តីពីសវនាការត្រឹមត្រូវតាមផ្លូវច្បាប់

អ្នក ឬសហគមន៍ស្រុកអាចនឹងមិនមានសវនាការត្រឹមត្រូវតាមផ្លូវច្បាប់រហូតទាល់តែអ្នក ឬសហគមន៍ស្រុកដាក់សំណើស្នើសុំឲ្យមានសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ ជាមួយនឹងភាគីដទៃទៀត ឬផ្តល់ជូនច្បាប់ចម្លងមួយច្បាប់ស្តីពីសំណើនោះទៅ OSP ដែលរួមបញ្ចូលនូវព័តិមានដែលរៀបរាប់ពីខាងលើ ។

## ភាគីគ្រប់គ្រាន់នៃសំណើសុំឲ្យមានសវនាការ

ដើម្បីឲ្យសំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋដំណើរការទៅមុខ វាត្រូវមានលក្ខណៈ *គ្រប់គ្រាន់* ។ គ្រប់គ្រាន់ មានន័យថា សំណើនោះគឺត្រឹមត្រូវទៅតាមលក្ខខណ្ឌ ដែលមានខាងលើនៅក្រោមចំណងជើងការដាក់ពាក្យបណ្តឹង ។ សវនាការត្រឹមត្រូវតាម ច្បាប់រដ្ឋនឹងមានលក្ខណៈគ្រប់គ្រាន់នៅពេលដែលភាគីដែលទទួលសំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ ផ្តល់ដំណឹងទៅ ALJ និងភាគីដទៃទៀតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល 15 ថ្ងៃ ដែលភាគីទទួលជឿថា សំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋគឺមិនត្រឹមត្រូវ ។

ក្នុងរយៈពេល ៥ ថ្ងៃ នៃ ថ្ងៃ ទទួលសេចក្តីជូនដំណឹងពីភាពមិនគ្រប់គ្រាន់ ALJ ត្រូវសម្រេចចិត្តថាតើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ មានលក្ខណៈត្រឹមត្រូវតាមលក្ខខណ្ឌដែលបានរាយខាងលើនោះដែរឬទេ និងត្រូវជូនដំណឹងដល់អ្នក និងសមាគមន៍ស្រុកជាលាយលក្ខណ៍អក្សរភ្លាម ។

## ការកែប្រែទៅលើសំណើសវនាការ

អ្នក ឬសមហគមន៍ស្រុកអាចផ្លាស់ប្តូរសំណើសវនាការក្នុងករណីដែល :

1. ភាគីម្ខាងទៀតយល់ព្រមទៅនឹងការផ្លាស់ប្តូរជាលាយលក្ខណ៍អក្សរ និងទទួលបានឱកាសដោះស្រាយសំណើសវនាការ តាមរយៈកិច្ចប្រជុំដោះស្រាយបញ្ហាពិពណ៌នាខាងក្រោម **ឬ**
2. មិនយឺតជាង 5 ថ្ងៃ មុនពេលសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋចាប់ផ្តើម មន្ត្រីសវនាការផ្តល់ការអនុញ្ញាតឲ្យមានការផ្លាស់ប្តូរ ។

ក្នុងករណីដែលភាគីស្នើសុំសវនាការធ្វើការផ្លាស់ប្តូរទៅលើសំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋពេលវេលាសំរាប់កិច្ចប្រជុំដោះស្រាយបញ្ហា (រយៈពេល១៥ ថ្ងៃ នៃការទទួលបានសំណើ ) និងរយៈពេលនៃការដោះស្រាយ (30 ថ្ងៃនៃការទទួលសំណើ ) ត្រូវចាប់ផ្តើមសាជាថ្មីនៅកាលបរិច្ឆេទនៃការបំពេញសំណើកែប្រែ ឬកាលបរិច្ឆេទដែល ALJ ផ្តល់សំណើ ។

## <u>សហគមន៍ស្រុកឆ្លើយតបទៅនឹងសំណើសវនការត្រឹមត្រូវតាមច្បាប់រដ្ឋ</u>

ក្នុងករណីដែលសហគមន៍ស្រុកមិនទាន់បានផ្ញើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅកាន់អ្នក ដូចពិពណ៌នានៅក្រោមចំណងជើង *ការផ្ដល់ដំណឹងជាលាយលក្ខណ៍អក្សរជាមុន* ទាក់ទងទៅនឹងប្រធានបទដែលមាននៅក្នុងសំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ សហគមន៍ស្រុក

ត្រូវនៅក្នុងរយៈពេល 10 ថ្ងៃ ទទួលបានសំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ ផ្ញើចម្លើយជូនអ្នកដែលក្នុងនោះរួមមាន :

1. ការពិពណ៌នាពីមូលហេតុដែលសមាគន៍ស្រុកបានស្នើនិងបានបដិសេធក្នុងការចាត់វិធានការដែលបានលើកឡើងនៅក្នុងសំណើសវនការត្រឹមត្រូវតាមច្បាប់រដ្ឋ
2. ការពិពណ៌នាពីជម្រើសផ្សេងទៀតដែលក្រុម IEP របស់កូនអ្នកបានធ្វើការពិចារណា និងពីមូលហេតុនៃការបដិសេធជម្រើសទាំងនោះ
3. ការពិពណ៌នាពីនីតិវិធីនៃការវាយតម្លៃ ការប៉ាន់ប្រមាណបញ្ជី ឬរបាយការណ៍នីមួយៗដែលសហគមន៍ស្រុកបានប្រើប្រាស់ដើម្បីចាត់មូលដ្ឋានសម្រាប់ចាត់វិធានការស្នើសុំ និងវិធានការបដិសេធ <u>**និង**</u>
4. ការពិពណ៌នាពីកត្តាផ្សេងទៀតដែលទាក់ទងទៅនឹងសកម្មភាពស្នើសុំ និងបដិសេធរបស់សហគមន៍ស្រុក ។

សហគមន៍ស្រុកនៅតែពោលអះអាងថា សំណើសវនាការត្រឹមត្រូវតាមផ្លូវច្បាប់របស់អ្នកគឺមិនមានលក្ខណៈគ្រប់គ្រាន់ ទោះជាវាផ្ដល់ឲ្យអ្នកនូវព័ត៌មាននៅក្នុងចំណុច 1-4 ខាងលើក៏ដោយ ។

## <u>ទំនួលខុសត្រូវរបស់ភាគីម្ខាងទៀតទៅនឹងសំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ</u>

លើកលែងតែបានចែងនៅក្នុងអនុចំណងជើងខាងលើនេះ *នីតិវិធីវិន័យសម្រាប់សិស្សដែលមានសិទ្ធិគ្រប់គ្រាន់សម្រាប់សេវាអប់រំពិសេស* ភាគីទទួលសំណើសវនការត្រឹមត្រូវតាមច្បាប់រដ្ឋត្រូវ ក្នុងរយៈពេល 10 ថ្ងៃនៃការទទួលសំណើ ផ្ញើចម្លើយទៅភាគីម្ខាងទៀតដែលបញ្ជាក់ទៅនឹងបញ្ហាដែលមាននៅក្នុងសំណើ។ ភាគីនីមួយ នៅតែអាចពោលអះអាងថា សំណើសវនាការត្រឹមត្រូវតាមផ្លូវច្បាប់គឺមិនមានលក្ខណៈគ្រប់គ្រាន់ ។

## <u>ទម្រង់បែបបទគំរូ</u>

## <u>៣៤ ជណ ៣០០។៥០៩; ាជ ៣៩២-១៧២ា-០៥០៨៥</u>

OSPI បានបង្កើតគំរូសំណើសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋដើម្បីជួយអ្នកក្នុងការបំពេញសំណើសម្រាប់សវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ ។ ទម្រង់នេះគឺមាននៅលើគេហទំព័រ :

http://www.k12.wa.us/ProfPractices/adminresources/forms.aspx **ឬ**
http://www.k12.wa.us/SpecialEd/mediation.aspx.

គំរូនេះមិនមែនជាការតម្រូវឲ្យអ្នកប្រើវានោះទេ ។ ទោះជាយ៉ាងនេះក្ដីសិទ្ធិរបស់អ្នកទៅនឹងសវនាការដោះស្រាយជម្លោះ អាចនឹងត្រូវបដិសេធ ឬពន្យាពេល បើសិនជា សវនាការដោះស្រាយជម្លោះមិនមានព័ត៌មានដែលត្រូវការ។ អ្នកអាចទទួលបានទម្រង់សំណើសវនការការនេះពីនាយកដ្ឋានសេវាអប់រំពិសេសពីសហគមន៍ស្រុករបស់អ្នក ។

## ការផ្លាស់ប្តូរសិស្សនៅពេលសវនាការដោះស្រាយជម្លោះត្រូវបានពន្យា

**<u>៣៤ ផឈ ៣០០។៥១៨; ៃផ ៣៩២-១៧២៎-០៥១២៥</u>**

លើកលែងតែចែងខាងក្រោម ក្រោមចំណងជើង *នីតិវិធីនៅពេលដាក់ពិន័យសិស្សពិការ* នៅពេលដែលសំណើសវនាការដោះស្រាយជម្លោះត្រូវបានបញ្ជូនទៅភាគីដទៃនៅក្នុងកំឡុងពេលនៃដំណើការដោះស្រាយបញ្ហា និងខណៈពេលកំពុងរង់ចាំការសម្រេចពីសវនាការដោះស្រាយជម្លោះមិនលំអៀង ឬនីតិវិធីដំណើរការរបស់តុលាការ ដែលទាក់ទងទៅនឹងបណ្តឹង ឧទ្ធរណ៍លើការសម្រេចរបស់ ALJ កូនរបស់អ្នក ត្រូវស្ថិតនៅក្នុងកន្លែងសិក្សារបស់គេដដែល លើកលែងតែអ្នក និងសហគមន៍ស្រុកព្រមព្រៀងផ្ទុយពីនេះ ។
បើសិនជាសំណើរសវនាការដោះស្រាយវិវាទទាក់ទង ទៅនឹងការដាក់ពាក្យសុំចូលសាលារដ្ឋដំបូង កូនរបស់អ្នកជាមួយនឹងការព្រមព្រៀងរបស់អ្នកគឺត្រូវបញ្ចូលទៅក្នុងកម្មវិធីសាលារដ្ឋធម្មតា រហូតទាល់តែដំណើរការនីតិវិធីដូចនោះចប់សព្វគ្រប់។

បើសិនជាសំណើសុំសវនាការដោះស្រាយទាក់ទងទៅនឹងការស្នើសុំសេវាដំបូងនៅក្រោមច្បាប់ IDEA ក្នុង Part B សម្រាប់កូនរបស់អ្នក ដែលនឹងត្រូវប្តូរពីការផ្តល់សេវាក្រោមច្បាប់ IDEA ក្នុង Part C ទៅ Part B នៃច្បាប់ IDEA និងដែលមិនមានសិទ្ធិទទួលសេវាក្នុង Part C ដោយសារតែកូនរបស់អ្នកមានអាយុ៣ឆ្នាំ សាលាសហគមន៍ស្រុកមិនស្ថិតនៅក្រោមកាតព្វកិច្ចក្នុងការផ្តល់សេវា Part C ដែលកូនអ្នកធ្លាប់បានទទួលទៀតនោះទេ។ បើសិនជាកូនរបស់អ្នកត្រូវបានរកឃើញថាមានសិទ្ធិនៅក្រោម Part B នៃច្បាប់ IDEA ហើយអ្នកផ្តល់កិច្ចព្រមព្រៀងសម្រាប់កូនអ្នកឲ្យទទួលសេវាពិសេស និងសេវាដែលពាក់ព័ន្ធលើកទីមួយក្នុងការពន្យាលទ្ធផលនៃនីតិវិធីដំណើរការសហគមន៍ស្រុកត្រូវផ្តល់សេវាពិសេស និងពាក្យព័ន្ធទាំងនោះ ដែលវាមិនមានស្ថិតក្នុងជម្លោះរវាងអ្នក និងសហគមន៍ស្រុក ។

ក្នុងករណីដែល ALJ សម្រេចថា ការផ្លាស់ប្តូរសេវាគឺជាការត្រឹមត្រូវ និងដែលថាការសម្រេចទាក់ទងនឹងការផ្លាស់ប្តូរសេវាគឺ ត្រូវចាត់ទុកជាកិច្ចព្រមព្រៀងរវាងអ្នក និងសាលាសគមន៍ស្រុកសម្រាប់គោលបំណងនៃការផ្លាស់ប្តូរក្នុងកំឡុងពេលនៃបណ្តឹងឧទ្ធរណ៍ទៅលើការសម្រេចនៃសវនា-ការដោះស្រាយ។

## ដំណើរការដោះស្រាយបញ្ហា

**<u>៣៤ ផឈ ៣០០។៥១០; ៃផ ៣៩២-១៧២៎-០៥០៩០</u>**

| |
|---|
| នៅពេលអ្នកដាក់ពាក្យបណ្តឹងស្នើសុំសវនាការដោះស្រាយជម្លោះ **IDEA** តម្រូវឲ្យអ្នកចូលរួមនៅក្នុងកិច្ចប្រជុំដោះស្រាយជម្លោះមុនពេលសវនាការដោះស្រាយជម្លោះចាប់ផ្តើម ។ |

### <u>កិច្ចប្រជុំដោះស្រាយបញ្ហា</u>

ក្នុងរយៈពេល 15 ថ្ងៃ នៃការទទួលសេចក្តីជូនដំណឹងនៃសំណើសុំសវនាការដោះស្រាយជម្លោះ និងមុនពេលសវនាការដោះស្រាយជម្លោះចាប់ផ្តើម សហគមន៍ស្រុកត្រូវកោះប្រជុំជាមួយអ្នក និងសមាជិក ឬសមាជិកពាក់ព័ន្ធរបស់ក្រុម IEP ដែលមានចំណេះដឹងជាក់លាក់ពីសេចក្តីពិតដែលមាន នៅក្នុងសំណើសវនាការដោះស្រាយជម្លោះរបស់អ្នក ។ កិច្ចប្រជុំ

1. ត្រូវមានអ្នកតំណាងរបស់សហគមន៍ស្រុកដែលមានសិទ្ធិធ្វើការសម្រេចចិត្តក្នុងនាមឲ្យស្រុក **<u>និង</u>**

2. អាចមិនមានមេធាវីរបស់សមាគមន៍ស្រុក លើកលែងតែអ្នកមានមេធាវី ។

គោលបំណងនៃកិច្ចប្រជុំគឺសម្រាប់អ្នកធ្វើការពិភាក្សាអំពីសំណើសុំសវនាការដោះស្រាយជម្លោះ និងសេចក្តីពិតដែលបង្កើតទៅជាមូលដ្ឋាននៃការស្នើសុំ ដើម្បីឲ្យសហគមន៍ស្រុកមានឱកាសដោះស្រាយជម្លោះ។ អ្នក និង ស្រុកជាអ្នកកំណត់សមាជិកដែលពាក់ព័ន្ធរបស់ក្រុម IEP ឲ្យចូលរួមទៅក្នុងកិច្ចប្រជុំដើម្បីដោះស្រាយបញ្ហា។

កិច្ចប្រជុំដោះស្រាយបញ្ហាគឺមិនចាំបាច់នោះទេ ក្នុងករណីដែល :

1. អ្នក និងសហគន៍ស្រុកយល់ព្រមជាលាយលក្ខណ៍អក្សរក្នុងការបោះបង់ចោលកិច្ចប្រជុំ **ឬ**
2. អ្នក និងសហគមន៍ស្រុកព្រមព្រៀងប្រើដំណើរការសម្របសម្រួល ដូចពិពណ៌នាទៅក្នុងដំណាងដើង *ការសម្របសម្រួល* ។

## រយៈពេលនៃការដោះស្រាយជម្លោះ

បើសិនជាសហគមន៍ស្រុកមិនបានដោះស្រាយទៅលើសំណើសុំសវនាការដោះស្រាយជម្លោះដែលអ្នកពេញចិត្តក្នុងរយៈពេល30 ថ្ងៃនៃការទទួលសំណើសុំសវនាការដោះស្រាយជម្លោះនោះទេ សវនាការដោះស្រាយជម្លោះអាចនឹងកើតឡើង។

រយៈពេល45 ថ្ងៃ សម្រាប់ការចេញសេចក្តីសម្រេចចុងក្រោយចាប់ផ្តើមទៅចុងកាលបរិច្ឆេទ30 ថ្ងៃ នៃរយៈពេលដោះស្រាយបញ្ហា ដោយមានករណីលើកលែងសម្រាប់ការកែតម្រូវមួយចំនួនទៅនឹងរយៈពេល 30 ថ្ងៃ នៃការដោះស្រាយបញ្ហា ដូចពិពណ៌នាខាងក្រោម ។

លើកលែងតែអ្នក និងសហគមន៍ស្រុកបានព្រមព្រៀងបោះបង់ចោលដំណើរការដោះស្រាយ ឬប្រើការសម្របសម្រួល ការអាក់;ខានរបស់អ្នកក្នុងការចូលរួមកិច្ចប្រជុំដោះស្រាយបញ្ហានឹងពន្យាពេលសម្រាប់ដំណើរការដោះស្រាយបញ្ហា និងសវនាការដោះស្រាយជម្លោះ រហូតទាល់តែអ្នកចូលរួមក្នុងកិច្ចប្រជុំ ។

បើសិនជា សហគមន៍ស្រុកមិនអាចទទួលបានការចូលរួមពអ្នកនៅក្នុងកិច្ចប្រជុំដោះស្រាយជម្លោះបន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងគួរឲ្យកត់សម្គាល់កន្លងមក និងដោយមានការកត់ត្រាពីកិច្ចខិតខំទាំងនេះផងនោះ សហគមន៍ស្រុកអាចនៅចុងកាលបរិច្ឆេទ 30 ថ្ងៃ នៃរយៈពេលដោះស្រាយបញ្ហាស្នើសុំទៅ ALJ ឲ្យទាត់ចោលសំណើរសុំសវនាការដោះស្រាយជម្លោះរបស់អ្នក។ សាលាសហគមន៍ស្រុកត្រូវរៀបចំកសាពីកិច្ចខិតខំរបស់ខ្លួនដើម្បីរៀបចំឲ្យមានការព្រមព្រៀងទៅលើពេលវេលា និងទីកន្លែង ។ ការរៀបចំឯកសានោះរួមមានកិច្ចខិតខំដូចជា :

1. របាយការណនៃការហៅទូរស័ព្ទ ដែលហៅមក ឬដែលព្យាយាមហៅ និងលទ្ធផលនៃការហៅទាំងនោះ
2. ច្បាប់ចម្លងនៃសំបុត្រដែលបានផ្ញើទៅអ្នក និងចម្លើយឆ្លើយតបដែលទទួលបាន **និង**
3. របាយការណ៍លំអិតនៃការចុះទៅដល់ផ្ទះ ឬកន្លែងធ្វើការរបស់អ្នក និងលទ្ធផលដែលទទួលបានពីការចុះទៅនោះ។

ក្នុងករណីដែលសហគមន៍ស្រុក ខកខានមិនបានរៀបចំកិច្ចប្រជុំដោះស្រាយបញ្ហាក្នុងរយៈពេល15 ថ្ងៃ នៃការទទួលដំណឹងពីសំណើសុំសវនាការដោះស្រាយជម្លោះរបស់អ្នក **ឬ** ខកខានក្នុងការចូលរួមកិច្ចប្រជុំដោះស្រាយបញ្ហា អ្នកអាចស្នើទៅ ALJ អោយចេញដីការចាប់ផ្តើមសវនាការដោះស្រាយជម្លោះ 45 ថ្ងៃ ។

## ការកែតម្រូវទៅលើរយៈពេល 30 ថ្ងៃ នៃការដោះស្រាយបញ្ហា

បើសិនជាអ្នក និងសហគមន៍ស្រុកយល់ព្រមជាលាយលក្ខណ៍អក្សរបោះបង់ចោលកិច្ចប្រជុំដោះស្រាយបញ្ហា នោះរយៈពេល45 ថ្ងៃ នៃសវនាការដោះស្រាយជម្លោះនឹងចាប់ផ្តើមនៅថ្ងៃបន្ទាប់ ។

បន្ទាប់ពីកិច្ចចាប់ការសម្របសម្រួល ឬកិច្ចប្រជុំដោះស្រាយបញ្ហា និងមុនចុងកាលបរិច្ឆេទ ៣០ ថ្ងៃ នៃការដោះស្រាយបញ្ហា បើសិនជាអ្នក និងសហគមន៍ស្រុកព្រមព្រៀងជាលាយលក្ខណ៍អក្សរថាមិនមានកិច្ចព្រមព្រៀងអាចនឹងកើតឡើងនោះទេ នោះរយៈពេល 45 ថ្ងៃ នៃសវនាការដោះស្រាយជម្លោះនឹងចាប់ផ្តើមនៅថ្ងៃបន្ទាប់ ។

ក្នុងករណីដែលអ្នក និងសហគមន៍ស្រុកប្រើប្រាស់ដំណើរការសម្របសម្រួល ទៅចុងកាលបរិច្ឆេទ នៃរយៈពេល 30 ថ្ងៃ នៃការដោះស្រាយជម្លោះភាគីទាំងពីរអាចយល់ព្រមជាលាយលក្ខណ៍អក្សរដើម្បីបន្តការសម្របសម្រួលរហូតមានកិច្ចព្រមព្រៀងកើតឡើង ទោះជាយ៉ាងនេះក្តី បើសិនជាអ្នក ឬសហគមន៍ស្រុកដកខ្លួនចេញពីដំណើរការសម្របសម្រួល នោះរយៈពេល 45ថ្ងៃ នៃសវនាការដោះស្រាយជម្លោះនឹងចាប់ផ្តើមនៅថ្ងៃបន្ទាប់ ។

**កិច្ចព្រមព្រៀងលើដំណោះស្រាយជាលាយលក្ខណ៍អក្សរ**

ប្រសិនបើសាលាសហគមន៍ស្រុកដោះស្រាយទំនាស់នៅក្នុងការប្រជុំដោះស្រាយវិវាទ អ្នក និងសាលាសហគមន៍ស្រុកនោះ ត្រូវចុះកិច្ចព្រមព្រៀងទៅតាមផ្លូវច្បាប់ ដែល :

1. អ្នក និងតំណាងសាលាដែលមានសិទ្ធិចុះហត្ថលេខាដើម្បីចងភ្ជាប់សាលាសហគមន៍ស្រុកក្នុងកិច្ចព្រមព្រៀង **និង**
2. អាចប្រតិបត្តិបាន នៅក្នុងតុលាការជាន់ខ្ពស់នៅក្នុងរដ្ឋវ៉ាស៊ីនតោន នៃយុត្តាធិការដែលមានសមត្ថកិច្ច ឬនៅក្នុងតុលាការសាលាសហគមន៍ស្រុកនៃសហរដ្ឋអាមេរិក។

**រយៈពេលពិនិត្យលើកិច្ចព្រមព្រៀង**

ប្រសិនបើអ្នក និងសាលាសហគមន៍ស្រុកនោះបានចុះកិច្ចព្រមព្រៀង ដែលជាលទ្ធផលនៃការប្រជុំដោះស្រាយវិវាទ ទាំងអ្នក ឬសាលាសហគមន៍ស្រុក នោះ ត្រូវជៀសវាងការចុះហត្ថលេខាដោយភាគីទាំងពីរក្នុងកំឡុងពេល 3 ថ្ងៃ មុននៃថ្ងៃធ្វើការ។

**សវនាការដោះស្រាយជម្លោះឥតលំអៀង**

**<u>៣៤ ជឈ ៣០០។៥១១;ៃផ ៣៩២-១៧២។-០៥០៨០៖០៥០៩៥</u>**

**លក្ខខណ្ឌទូទៅ**

នៅពេលណាដែលគេដាក់បណ្តឹងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ អ្នក និងសាលាសហគមន៍ស្រុកដែលពាក់ព័ន្ធ ក្នុងវិវាទ ត្រូវតែមានឱកាសទទួលបានសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋឥតលំអៀង ។

**<u>ចៅក្រមច្បាប់រដ្ឋបាល (ALJ)</u>**

សវនាការនេះនឹងត្រូវធ្វើឡើងដោយ ALJ ឯករាជ្យ ដែលជួលដោយការិយាល័យសវនាការរដ្ឋបាល (OAH)។

ជាអតិបរិមា ALJ :

1. ត្រូវតែមិនមែនជាជាបុគ្គលិកនៃ OSPI ឬសាលាសហគមន៍ស្រុកដែលធ្វេការពាក់ព័ន្ធការអប់រំ ឬការថែទាំកុមារ ។ ទោះជាយ៉ាងណា បុគ្គល ម្នាក់មិនមែនជាបុគ្គលិក នៃស្ថាប័ននោះតែមួយនោះទេ ដោយសារតែគាត់ត្រូវបានផ្តល់ប្រាក់ខែដោយស្ថាប័ននោះដើម្បីធ្វើការជា ALJ
2. មិនត្រូវមានផលប្រយោជន៍ជាបុគ្គល ឬផលប្រយោជន៍វិជ្ជាជីវៈ ដែលជំទាស់ទៅនឹងគោលបំណង ALJ នៅក្នុងសវនាការនោះទេ
3. ត្រូវតែមានចំណេះដឹង និងការយល់ដឹងច្រើនអំពីបញ្ញាតិ នៃ IDEA និងបទបញ្ញតិថ្នាក់សហព័ន្ធ និងបទបញ្ញាថ្នាក់រដ្ឋ ដែលទាក់ទងទៅនឹងការបកប្រែច្បាប់ នៃ IDEA ដោយតុលាការបញ្ហាថ្នាក់សហព័ន្ធ និងតុលាការថ្នាក់រដ្ឋ **<u>ព្រមទាំង</u>**

4. ត្រូវតែមានចំណេះដឹង និងសមត្ថភាព ធ្វើសវនាការ និងធ្វើការសម្រេចចិត្ត និងសរសេរការសម្រេចចិត្ត ដោយស្របទៅតាមការអនុវត្តន៍តាមផ្លូវច្បាប់ប្រកបដោយស្តង់ដារអនុវត្តច្បាប់ត្រឹមត្រូវ ។

សាលាសហគមន៍ស្រុកនិមួយៗ តម្រូវរក្សាបញ្ជីឈ្មោះអ្នកដែលបានបម្រើការងារជា ALJ ។ បញ្ជីនោះ ត្រូវរួមបញ្ចូលទាំងរបាយការណ៍សមត្ថភាពរបស់ ALJ និមួយៗផងដែរ។

**<u>បញ្ហាពិភាក្សានៅក្នុងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ</u>**

ភាគីដែលដាក់បណ្តឹងឲ្យមានសេវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ មិនអាចលើកជាបញ្ហា ដែលមិនមានបញ្ជាក់នៅក្នុងបណ្តឹងក្នុងសវនាការនោះ លើកលែងតែភាគីម្ខាងទៀតយល់ព្រម។

**<u>រយៈពេលសម្រាប់ដាក់ពាក្យបណ្តឹង</u>**

អ្នក ឬសហគមន៍ស្រុក ត្រូវតែដាក់ពាក្យបណ្តឹងនៅក្នុងរយៈពេល២ឆ្នាំ នៃពេលដែលអ្នក ឬសាល បានដឹង ឬគួរតែបានដឹង អំពីវិវាទដែលត្រូវដោះស្រាយនៅក្នុងបណ្តឹង ។

**<u>ករណីលើកលែងនៃរយៈពេលដាក់ពាក្យបណ្តឹង</u>**

ការដាក់កម្រិតរយៈពេលខាងលើមិនអាចអនុវត្តបាននោះទេ ប្រសិនបើអ្នកមិនអាចរៀបចំពាក្យបណ្តឹងសម្រាប់សវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ ដោយសាមូលហេតុខាងក្រោម :

1. សាលាសហគមន៍ស្រុកមិនបានបង្ហាញយ៉ាងជាក់លាក់ថា ខ្លួនបានដោះស្រាយបញ្ហាដែលអ្នកបានលើកឡើងនៅក្នុងបណ្តឹងសម្រាប់សវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ
2. សាលាកាត់ទុកព័ត៌មានពីអ្នក ដែលវាជាការតម្រូវឲ្យផ្តល់ព័ត៌មានដល់អ្នកនៅក្រោមផ្នែក B នៃ IDEA។

**<u>សិទ្ធិក្នុងសវនាការ</u>**

## <u>៣៤ ជឈរ ៣០០។៥១២; ីៃដ ៣៩២-១៧២។-០៥១០០</u>

**<u>លក្ខខណ្ឌទូទៅ</u>**

អ្នក និងសាលាសហគមន៍ស្រុក ដែលជាភាគីទាំងសងខាង នៃ សវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ (រួមទាំងសវនាការណាមួយដែលទាក់ទងនឹងនិតិវិធីខាងវិន័យ) មានសិទ្ធិ :

1. អមជាមួយ និងផ្តល់យោបល់ដោយ មេធាវី ឬអ្នកដែលមានចំណេះដឹង និងទទួលការបណ្តុះបណ្តាលពិសេសលើបញ្ហាសិស្សពិការ
2. បង្ហាញភស្តុតាង និងប្រឈម ដោយមានការពិនិត្យ ព្រមទាំងតម្រូវឲ្យមានវត្តមានសាក្សី
3. ហាមឃាត់ការលើកភស្តុតាងនៅក្នុងសវនាការ ដែលមិនត្រូវបង្ហាញទៅដល់ភាគីម្ខាងទៀត ក្នុងរយៈពេលយ៉ាងហោចណាស់៥ ថ្ងៃ នៃថ្ងៃ ធ្វើការមុនពេលបើកសវនាការ

4. ទទួលបានកំណត់ត្រាជាសំណេរ ឬជាអេឡិចត្រូនិច (អាស្រ័យតាមជម្រើស) ទៅតាមពាក្យពេជន៍ នៅក្នុងសវនាការ **ព្រមទាំង**
5. ទទួលបានការរកគំហើញការពិត និងលទ្ធផលសម្រេចចិត្តជាសំណេរ ឬជាអេចត្រូនិច(អាស្រ័យតាមជម្រើស)

**ការបង្ហាញព័ត៌មានបន្ថែម**

យ៉ាងហោចណាស់មុន ថ្ងៃ បើកសវនាការ៥ ថ្ងៃ នៃ ថ្ងៃ ធ្វើការអ្នកនិងសាលាសហគមន៍ស្រុកត្រូវបង្ហាញគ្នាទៅវិញទូវរាល់ការវាយតម្លៃ ដែលតម្រូវបានបញ្ចប់ត្រឹមកាលបរិច្ឆេទ និងការផ្តល់អនុសាសន៍ ដោយផ្អែកលើការវាយតម្លៃទាំងនោះ ដែលអ្នក និងសាលារដ្ឋបម្រុងនឹងប្រើទៅក្នុងសវនាការ។

ALJ អាចរារាំងភាគីណាមួយដែលមិនប្រតិបត្តិតាមលក្ខខណ ទាំងនេះ ពីការលើកឡើងការវាយតម្លៃដែលពាក់ព័ន្ធ ឬអនុសាសន ដែលមិនមានការយល់ព្រមពីភាគីម្ខាងទៀតនៅក្នុងសវនាការ។

**សិទ្ធិឪពុកម្តាយនៅក្នុងសនាការសវនាការ**

អ្នកត្រូវបានផ្តល់សិទ្ធិដូចខាងក្រោម

1. បង្ហាញកូនរបស់អ្នក
2. បើកសាវនាការជាសាធារណ **ព្រមទាំង**
3. ទទួលបានកំណត់ត្រាសវនាការ អំពីរបកគំហើញការពិត និងលទ្ធផលសម្រេចចិត្តដោយឥតគិតថ្លៃ

## រយៈពេល និង ភាពងាយស្រួលក្នុងសវនាការ

## ៣៤ ជឈ ៣០០។៥១៥;ៃជ ៣៩២-១៧២-០៥១១០

ដោយមិនយូរជាង 45 ថ្ងៃ បន្ទាប់ពីការផុតកំណត់នៃរយៈពេល 30ថ្ងៃ សម្រាប់ការប្រជុំដំណោះស្រាយវិវាទ **ឬ** មិនយឺតជាង 45 ថ្ងៃ បន្ទាប់ពី ថ្ងៃ ផុតកំណត់ នៃរយៈដោះស្រាយ ដែល ត្រូវបានធ្វើឡើង

1. សេចក្តីសម្រេចចុងក្រោយ ត្រូវធ្វើឡើងនៅក្នុងសវនាការ និង
2. សេចក្តីចំលង នៃសេចក្តីសម្រេចចិត្ត តម្រូវផ្ញើទៅភាគីទាំងសងខាង

ALJ អាចផ្តល់ការអនុញ្ញាតការពន្យាពេលជាក់លាក់នៃពេលក្រោយពីរយៈពេល 45ថ្ងៃ ដែលបានបរិយាយខាងលើ ទៅតាមសំណើរបស់ភាគីណាមួយខាងលើ។

សវនាការនីមួយៗ តម្រូវតែធ្វើឡើងនៅពេល និងកន្លែង ដែលសមស្របត្រឹមត្រូវ សម្រាប់អ្នក និងកូនអ្នក។

## សេចក្តីសម្រេចនៃសវនាការ

## ៣៤ ជឈ ៣០០។៥១៣;ៃជ ៣៩២-១៧២-០៥១០៥

**សេចក្តីសម្រេចរបស់ ALJ**

សេក្តីសម្រេចរបស់ ALJ លើថាតើកូនរបស់អ្នកគួរទទួលបានការអប់រំសាធារណៈត្រឹមត្រូវដោយឥតគិតថ្លៃ (FAPE) ឬយ៉ាងណា ត្រូវផ្អែកលើគោលការណ៍សំខាន់ ។

នៅក្នុងសវនាការដែលឆ្លកពោលអះអាងសាលាសហគមន៍ ស្រុកបានធ្វើការបំពាននិតិវធី ALJ អាចរកឃើញថា កូនរបស់អ្នកមិនបានទទួល FAPE តែក្នុងករណី មាននិតិវិធីមិនគ្រប់គ្រាន់

1. ត្រូវបានជ្រៀតជ្រែកលើសិទ្ធិកូនអ្នកក្នុងការទទួលបាន FAPE
2. មានការជ្រៀតជ្រែកខ្លាំងជាមួយនឹងឱកាស ចូលរួមក្នុងដំណើរការសម្រេចចិត ចំពោះការផ្តល់ FAPE ដល់កូនរបស់អ្នក <u>ឬ</u>
3. ធ្វើឲ្យមានការដកហូតផលប្រយោជន ទទួលបានការអប់រំ

<u>**ខសន្យាលើកទឹកចិត្ត**</u>

បើទោះបីជា ALJ រកមិនឃើញការបំពាន FAPE ក៏ដោយ ALJ ក៏នៅតែអាចបញ្ជាឲ្យសាលាសហគមន៍ស្រុកនោះប្រតិបតិតាមលក្ខខណ ចែង នៅក្នុងផ្នែកនិតិវិធីការការពារ នៃបទបញ្ញាសហព័ន ក្រោម ផ្នែក B នៃ IDEA (34 CFR §§300.500 ដល 300.536) ។

<u>**បណ្តឹងដោយឡែកសម្រាប់សវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ**</u>

អ្នកអាចរៀបចំពាក្យបណ្តឹងសម្រាប់សវនាការត្រឹមត្រូវតាមច្បាប់រដ្ឋដោយឡែកស្តីពីបញ្ហាផ្សេងទៀត ខុសពីបញ្ហាក្នុងពាក្យបណ្តឹងសម្រាប់សវ-នាការ ត្រឹមត្រូវតាមច្បាប់រដ្ឋដែលត្រូវបានរៀបចំរួចជាស្រេចរួមមកហើយ។

<u>**លទ្ធផល និង ការសម្រេចចិត្តទៅកាន់ ក្រុមប្រឹក្សា និង សាធារណជនទូទៅ**</u>

OSPI លុបចោលរាល់ពតិមានដែលអាចកំណត់បានជាបុគ្គល និង

1. ផ្តល់លទ្ធផល និងការសម្រេចចិត្ត នៅក្នុងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ ទៅគណៈកម្មការ ប្រឹក្សាការអប់រំពិសេស (SEAC)<u> និង</u>
2. ធ្វើលទ្ធផល និងការម្រេចចិត្តអាចទទួលបានដល់សាធារណ

<u>**ទីបញ្ចប់នៃសេចក្តីសម្រេច**</u>

<u>**34 CFR§300.514; WAC 392-172A-05115**</u>

**សេចក្តីសម្រេចរបស់សវនាការត្រឹមត្រូវតាមច្បាប់រដ្ឋគឺជាសេចក្តីសម្រេចចុងក្រោយវៀលែងតែអ្នក ឬសាលាសហគមន៍ស្រុកប្តឹងតវ៉ាបន្តលើសេចក្តីសម្រេចនេះ ទៅតុលាការមួយទៀត ដោយរៀបចំពាក្យបណ្តឹងរដ្ឋប្បវេណី។ គេមានពេលជាក់លាក់សម្រាប់ការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី។ តុលាការនេះអាចផ លំជូនវិញនូវថ្លៃឈ្នួលមេធាវី ។**

សេចក្តីសម្រេចធ្វើឡើងក្នុងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ (រួមទាំងសវនាការ ដែលទាក់ទងទៅនឹងនិតិវិធីវិន័យខាងវិន័យ ) គឺជាការសម្រេចចិត្ត ចុងក្រោយវៀលែងតែភាគីណាមួយ (អ្នក ឬសាលា ) ចូលរួមក្នុងសវនាការនេះ ប្តឹងតវ៉ាលើសេចក្តីសម្រេច ដោយការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ដូចដែលពិពណ៌នាខាងក្រោម។

<u>**ការដាក់បណ្តឹងរដ្ឋប្បវេណីរួមទាំងរយៈពេលក្នុងការដាក់បណ្តឹង**</u>

## ៣៤ ជឈ    ៣០០។៥១៦;ីៃជ ៣៩២-១៧២។-០៥១១៥

### លក្ខខណ្ឌទូទៅ

ប្រសិនបើភាគីណាមួយមិនយល់ស្របទៅនឹងលទ្ធផល និងសេចក្តីសម្រេច នៅក្នុងសវនាការត្រឹមត្រូវតាមផ្លូវច្បាប់រដ្ឋ (រួមទាំងសវនាការដែលទាក់ទងនឹងនិតិវិធីខាងវិន័យ ) ភាគីនោះមានសិទ្ធិដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ដោយគោរពទៅតាមបញ្ហានៅក្នុងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ ។ បណ្តឹងត្រូវធ្វើឡើងនៅក្នុងតុលាការថ្នាក់រដ្ឋ នៃយុត្តាធិការដែលមានសមត្ថកិច្ច ( តុលាការថ្នាក់រដ្ឋដែលមាន សិទ្ធិអំណាចបើកសវនាការលើបណ្តឹងប្រភេទនេះ) ឬតុលាការតំបន់មួយនៅក្នុងសហរដ្ឋអាមេរិក ។ តុលាការក្នុងស្រុក នៃសហរដ្ឋអាមេរិកមានសិទ្ធិអំណាចគ្រប់គ្រង លើបណ្តឹងធ្វើឡើងក្រោមផ្នែក B នៃ IDEA ដោយមិនគិតពីទំហំជំលោះ។

### កាលកំណត់ពេលវេលា

ភាគីដែលដាក់ពាក្យបណ្តឹងនឹងមានពេល៩០ ថ្ងៃ នៅកាលបរិច្ឆេទ នៃសេចក្តីសម្រេច របស់ ALJ ដើម្បីធ្វើការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ។

### និតិវិធីបន្ថែម

នៅក្នុងបណ្តឹងរដ្ឋប្បវេណីណាមួយ តុលាការ :

1. ទទួលបានកំណត់ត្រានៃដំណើរការនិតិវិធីរដ្ឋបាល
2. បើកសវនាការបង្ហាញភស្តុតាងបន្ថែម តាមសំណើររបស់អ្នក ឬតាមសំណើររបស់សាលា **ព្រមទាំង**
3. ផ្អែកលើការសម្រេចចិត្តរបស់ខ្លួនលើឧត្តមភាពនៃភស្តុតាង និងសមទានសំណង ដែលតុលាការកំណត់ឲ្យសមស្រប។

### វិធាននៃការស្ថាបនា

គ្មានអ្វីនៅក្នុងផ្នែក B នៃ IDEA ដាក់កម្រិត ដាក់ដែនកំណត់សិទ្ធិ និតិវិធី និងដំណោះស្រាយ មាននៅក្រោមរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ច្បាប់ជនពិការអាមេរិក ឆ្នាំ1990 មាតិកា V នៃច្បាប់នីតិសម្បទា នៃឆ្នាំ1973 (ផ្នែកទី 504 ) ឬច្បាប់សហព័ន្ធការពារសិទ្ធិសិស្សពិការ ។ ទោះជាយ៉ាងនេះក្តីប្រសិនបើអ្នកដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ក្រោមច្បាប់ទាំងនេះ និងអ្នកកំពុងទារសំណង ដែលមាននៅក្រោម ផ្នែក B នៃ IDEA ដោយសា សវនាការត្រឹមត្រូវតាមច្បាប់រដ្ឋដែលពណ៌នាខាងលើ ត្រូវតែបញ្ចេញឲ្យអស់លទ្ធភាព ទៅតាមតម្រូវការប្រសិនបើអ្នកដាក់ពាក្យបណ្តឹង ក្រោមផ្នែក B នៃ IDEA ។ នេះមានន័យថា អ្នកអាចមានដំណោះស្រាយក្រោមច្បាប់ផ្សេងទៀត ដែលត្រូវគ្នាជាមួយនឹងច្បាប់ដែលមាននៅក្រោម IDEA ប៉ុន្តែ ជាទូទៅ ដើម្បីទទួលបានសំណង ក្រោមច្បាប់ទាំងនោះ ជាដំបូងអ្នកប្រើនិតិវិធីសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋដោយឥតលំអៀង ដើម្បីទទួលបានដំណោះស្រាយមានក្រោមច្បាប់ IDEA មុនពេលដាក់បណ្តឹងផ្ទាល់ទៅតុលាការ។

## ថ្ងៃជួលមេធាវី

## ៣៤ ជឈ    ៣០០។៥១៧;ីៃជ ៣៩២-១៧២។-០៥១២០

### លក្ខខណ្ឌទូទៅ

ប្រសិនបើអ្នកមានអធិភាពនៅក្នុងបណ្តឹងរដ្ឋប្បវេណី និងត្រូវបានតំណាងដោយមេធាវី ក្នុងឆន្ទានុសិទ្ធិរបស់ខ្លួន តុលាការអាចផ្តល់សំណងថ្លៃឈ្នួលមេធាវី ដែលសមរម្យសម្រាប់ជាផ្នែកការចំណាយដល់អ្នក ។

នៅក្នុងបណ្តឹង ឬដំណើរការនិតិវិធីរដ្ឋបាល ត្រូវបានធ្វើឡើងក្រោម ផ្នែក B នៃ IDEA ក្នុងឆន្ទានុសិទ្ធិរបស់ខ្លួន តុលាការអាចផ្តល់សំណងថ្លៃឈ្នួល មេធាវីដែលសមរម្យ សម្រាប់ជាផ្នែកការចំណាយដល់សាលាសហគមន៍ស្រុក ឬ OSPI ដែលមានអធិភាព ដើម្បីឲ្យមេធាវីរបស់អ្នកបង់ប្រាក់ (a) ធ្វើការដាក់ពាក្យបណ្តឹង ឬបណ្តឹងតុលាការ ដែលតុលាការរកឃើញថា បណ្តឹងនោះមិនសំខាន់ មិនសមហេតុផល ឬដោយគ្មានមូលដ្ឋាន **ឬ** (b) ត្រូវបានបន្តប្តឹងបន្ទាប់ពីបណ្តឹងត៉វ៉ាដាក់ស្តែងបានក្លាយជាមិនបានការ មិនសមហេតុផល និងគ្មានមូលដ្ឋាន **ឬ**

នៅក្នុងបណ្តឹង ឬដំណើរការនិតិវធីរដ្ឋបាល ធ្វើឡើងក្រោម ផ្នែក B នៃ IDEA តុលាការ ក្នុងឆន្ទានុសិទ្ធិរបស់ខ្លួន តុលាការអាចផ្តល់សំណង ថ្លៃឈ្នួលមេធាវីដែលសមរម្យ សម្រាប់ជាផ្នែកការចំណាយដល់សាលាសហគមន៍ស្រុក ឬ OSPI ដែលមានអធិភាព ដើម្បីឲ្យមេធាវីរបស់អ្នកបង់ប្រាក់ ប្រសិនបើបណ្តឹងសម្រាប់សាវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ឬបណ្តឹងទៅតុលាក្រោយរបស់អ្នក ត្រូវបានបង្ហាញឲ្យឃើញពីគោលបំណងមិន ត្រឹមត្រូវណាមួយ ដូចជា ការប្រមាថ ដែលបង្កឲ្យមានការពន្យាដោយ ឥតប្រយោជន៍ពេលវបៀបនេះ ឬការបង្កើនការចំណាយបណ្តឹងរដ្ឋប្បវេណី ឬបណ្តឹងរដ្ឋបាល ។

ការផ្តល់សំណង នៃតំលៃឈ្នួលមេធាវី

តម្លៃឈ្នួលមេធាវី ត្រូវតែផ្អែកលើអត្តភាពនៅក្នុងសហគមន៍ ដែលក្នុងនោះបណ្តឹងរដ្ឋប្បវេណី ឬបណ្តឹងរដ្ឋបាល កើតឡើងសម្រាប់ ប្រភេទ និង គុណភាពសេវាកម្ម ដែល ត្រូវបានផ្តល់ជូន ។ មិនមានការបន្ថែម ឬគុណទ្វេអាចប្រើក្នុងការគណនាប្រាក់សំណងនោះទេ ។

តម្លៃមេធាវីមិនអាចផ្តល់ជូន និងការចំណាយដែលពាក់ព័ន្ធមិនអាចផ្តល់ជូនវិញឡើយ នៅក្នុងបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងរដ្ឋបាលដែលនៅក្រោម ផ្នែក B នៃ IDEA សម្រាប់សេវាកម្មដែលធ្វើឡើងបន្ទាប់ពីការផ្តល់ជូនជាលាយលក្ខណ៍អក្សរមួយ នៃដំណោះស្រាយចំពោះអ្នកប្រសិនបើ :

a. ការផ្តល់ជូននោះត្រូវបានធ្វើឡើងក្នុងរយៈពេលដែលត្រូវបានបង្គាប់ដោយវិធាន 68 ក្នុង វិធានសហព័ន្ធ នៃនិតិរដ្ឋប្បវេណី ឬ នៅក្នុងករណីនៃសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ ឬនៅការពិនិត្យថ្នាក់រដ្ឋ នៅគ្រប់ពេលដែលមិនយូរជាង 10 ថ្ងៃ មុននឹងរឿងបណ្តឹងរដ្ឋបាលចាប់ផ្តើម ។
b. ការផ្តល់ជូនមិនត្រូវបានទទួលក្នុងរយៈពេល 10 ថ្ងៃ **ព្រមទាំង**
c. តុលាការ និង ALJ រកឃើញថា ទីបញ្ចប់អ្នកទទួលបានសំណង ដែលសំណងនោះអ្នកមិនសូវពេញចិត្តជាងការផ្តល់ជូននៃដំណោះស្រាយ ។

បើទោះបីជាមានការដាក់កម្រិតទាំងនេះក៏ដោយ តុលាការអាចផ្តល់សំណង ថ្លៃឈ្នួលមេធាវី និងតម្លៃចំណាយដែលពាក់ព័ន្ធ ប្រសិនបើអ្នកមានអាធិភាព និងអ្នកត្រូវបានសម្របសម្រួលច្រើន ក្នុងការច្រានចោលផ្តល់ជូនសំណងដំណោះស្រាយ ។

តម្លៃឈ្នួលមេធាវីមិនត្រូវបានផ្តល់ជូន ដោយពាក់ព័ន្ធជាមួយនឹងការប្រជុំ ន ក ម IEP លើកលែងតែការប្រជុំនោះ តម្រូវបានធ្វើឡើងដោយសាតែដំណើរការនិតិវធីរដ្ឋបាល ឬវិធានតុលាការ។

ការប្រជុំដោះស្រាយវិវាទ តម្រូវ ក្រោមនិតិវិធីសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ មិនត្រូវបានចាត់ទុកថាជាការប្រជុំ ដែលកោះហៅ ដោយសាបណ្ដឹងរដ្ឋបាល ឬបណ្ដឹងតុលាការ ព្រមទាំងមិនត្រូវបានចាត់ទុកថាសវនាការនិតិវិធីរដ្ឋបាល ឬវិធានតុលាការសម្រាប់គោលបំណងផ្ដល់ជូនទូវ ថ្លៃឈ្នួលមេធាវីទាំងនេះនោះទេ។

តាមភាពសមស្រប តុលាការអាចកាត់បន្ថយតម្លៃមេធាវី ដែលតម្រូវបានផ្ដល់ជូនក្រោមផ្នែក B នៃ IDEA ប្រសិនបើតុលាការរកឃើញថា :

1. នៅក្នុងកំឡុងពេលដំណើរការបណ្ដឹងរដ្ឋប្បវេណី និងបណ្ដឹងរដ្ឋបាល អ្នក ឬមេធាវីរបស់អ្នក ធ្វើការពន្យាពេលដោយមិនសមហេតុផលនូវដំណោះស្រាយចុងក្រោយនៃវិវាទនោះ
2. ចំនួនតម្លៃសេវាមេធាវី មានអត្រាថ្លៃម៉ោងខ្ពស់មិនសមហេតុផល លើសពីអត្រាក្នុងសហគមន៍ សម្រាប់សេវាស្រដៀងគ្នាដែលត្រូវបានផ្ដល់ជូនដោយមេធាវីដែលមានជំនាញ កេរ្តិ៍ឈ្មោះ និងបទពិសោធន៍ ស្រដៀងច្រើនទៅនឹងជំនាញនេះលើកលែងតែត្រូវបានអនុញ្ញាតឲ្យផ្ដល់ជូន
3. រយៈពេលចំណាយ និងសេវាកម្មផ្នែកច្បាប់ដែលត្រូវបានផ្ដល់ជូនមានរយៈពេលយូរ បើយើងពិចារណាលើលក្ខណៈ វិធានតុលាការ និងនិតិវិធីរដ្ឋបាលនោះ **ឬ**
4. មេធាវីតំណាងអ្នកមិនផ្ដល់ព័ត៌មានក្នុងស្រុកត្រឹមត្រូវនៅក្នុងសេចក្ដីជូនដំណឹងបណ្ដឹងនេះ ដូចដែលបានពិពណ៌នាក្រោម ចំណងជើងថា **បណ្ដឹងសវនាការត្រឹមត្រូវតាមច្បាប់រដ្ឋ** ។

បើទោះជាយ៉ាងនេះក្ដី តុលាការមិនអាចកាត់បន្ថយតម្លៃ ប្រសិនបើតុលាការរកឃើញថា រដ្ឋ ឬ ស្រុក / ក្រុងធ្វើការពន្យាពេលដោយមិនសមហេតុផលនូវដំណោះស្រាយចុងក្រោយនៃវិធានតុលាការ ឬដំណើរការនិតិវិធីរដ្ឋបាល ឬមានការបំពានក្រោមបញ្ញត្តិនិតិវិធីការការពារនៅផ្នែក B នៃ IDEA ។

## <u>និតិវិធីខាងវិន័យសម្រាប់សិស្សមានសិទ្ធិទទួលបានការអប់រំពិសេស</u>

មានការការពារ ដែលត្រូវបានខិតខំប្រឹងប្រែងឡើងសម្រាប់កុមារ នៅពេលដែលគេគោរពវិន័យ ។ ការការពារទាំងនេះ បន្ថែមលើនិតិវិធីខាងវិន័យដែលប្រើសម្រាប់សិស្សទាំងអស់ ។ ការការពារទាំងនេះ ក៏ ប្រើចំពោះសិស្សដែលមិនទាន់ត្រូវបានរកឃើញថាមានសិទ្ធិទទួលបានការអប់រំពិសេស ប្រសិនបើស្រុកគួរតែបានដឹងថាពួកគេមានសិទ្ធិ ។

## <u>វិន័យលើការព្យួរកាសិក្សា និងការបណ្ដេញចេញពីសាលាសម្រាប់សិស្សទាំងអស់</u>

**<u>WAC 392-400</u>**

នៅពេលដែលសាលាសហគមន៍ស្រុក ព្យួរការសិក្សាកូនរបស់អ្នក ឬបណ្ដេញកូនរបស់អ្នកចេញពីសាលា វាត្រូវគោរពតាមច្បាប់រដ្ឋវ៉ាស៊ីនតោន និងបទបញ្ជា ដែលគ្រប់គ្រងវិន័យសិស្សទាំងអស់ ។ បទបញ្ជាវិន័យរដ្ឋវ៉ាស៊ីនតោន មានក្នុងជំពូក 392-400 WAC ។ សាលាសហគមន៍ស្រុកមាន គោលនយោបាយ និងនិតិវិធី ដែលពិពណ៌នាអំពីប្រភេទផ្សេង នៃការប្រព្រឹត្ត កិរិយាមិនត្រឹមត្រូវ និងការដាក់វិន័យលើការប្រព្រឹត្តកិរិយាមិនត្រឹមត្រូវ និងពួកគេត្រូវតែគោរពតាមនិតិវិធី ។ និតិវិធីរបស់សាលាសហគមន៍ស្រុក ក៏ពិពណ៌នាផងដែរអំពីរបៀបអ្នកអាចប្រឈមនឹងការបញ្ចប់របស់វាទៅនឹងវិន័យរបស់កូនអ្នក ។ លើកលែងតែមានភាពអាសន្ន ឬការបំពានដោយអាវុធ សាលាសហគមន៍ស្រុកជាទូទៅមិនអាចព្យួរការសិក្សាឬបណ្ដេញសិស្សណាម្នាក់ចេញពីសាលាឡើយលើកលែងតែពួកគេព្យាយាមតាមរូបភាពផ្សេងទៀតនៃសកម្មភាពត្រឹមត្រូវដែលអាចកែតម្រូវកិរិយាបទសិស្សទាំងនោះ។

នៅក្នុងជំពូក 392-400 WAC *ការព្យួរការសិក្សា* គឺជាការដកចេញពីមុខវិជ្ជាណាមួយ រយៈពេលរៀន ឬកាលវិភាគថ្នាក់ណាមួយ សម្រាប់កំឡុងពេលជាក់លាក់មួយនៃពេលវេលា ។ ដោយឡែក *ការបណ្តេញពីសាលា* គឺដកចេញពីមុខវិជ្ជាណាមួយ រយៈពេលរៀនមួយ ឬកាលវិភាគពេញលេញនៃថ្នាក់រៀន សម្រាប់រយៈពេល **មិនជាក់លាក់ណាមួយ** នៃពេលវេលា ។

អ្នកត្រូវប្រាកដថា អ្នកដឹងអំពីកាលវិភាគពេលវេលាសម្រាប់តវ៉ាការបញ្ចប់របស់សាលាសហគមន៍ក្នុងស្រុក ចំពោះវិន័យក្រោមនិតិវិធីអប់រំទូទៅ និងតាមរយៈ និតិវិធីសវនាការរបស់សាលាសហគមន៍ក្នុងស្រុក។ កាលវិភាគពេលវេលាទាំងនេះ ខុសពីកាលវិភាគពេលវេលាដែលអ្នកមានដើម្បីធ្វើការដាក់បណ្តឹងសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ នៃការអប់រំពិសេសមួយ ដែលអះអាងថា សាលាសហគមន៍ក្នុងស្រុកមិនគោរពតាមនិតិវិធីខាងវិន័យនៃការអប់រំពិសេស ។

## សិទ្ធិអំណាចនៃបុគ្គលិកក្នុងសាលា
## 34 CFR §300.530; WAC 392-172A-05145

### ការកំណត់តាមករណីនីមួយៗ

បុគ្គលិកសាលារៀនអាចពិចារណាលើកាលៈទេសៈប្លែកណាមួយ លើមូលដ្ឋានតាមករណី នៅពេលការសម្រេចចិត្ត ថាតើការផ្លាស់ប្តូរថ្នាក់រៀនដែលធ្វើឡើងស្របទៅតាមលក្ខខណ្ឌ ដែលពាក់ព័ន្ធនឹងវិន័យ គឺសមស្របសម្រាប់កូនរបស់អ្នកដែលបំពានលើច្បាប់ក្រមនៃការប្រព្រឹត្តិរបស់សិស្ស ។

### លក្ខខណ្ឌទូទៅ

បុគ្គលិករបស់សាលា **ដោយមិនលើសពី ១០ ថ្ងៃ ជាប់គ្នា** នឹងនាំកូនរបស់អ្នកពីថ្នាក់រៀនបច្ចុប្បន្នទៅកាន់ទីកន្លែងអប់រំផ្សេងទៀតដែលគេបានជ្រើសរើសបណ្តោះអាសន្ន (ដែលកំណត់ដោយក្រុម IEP សម្រាប់សិស្ស ) កន្លែងផ្សេងទៀត ឬ ត្រូវផ្អាកការសិក្សាតែម្តង នៅពេលក្មេងនោះបំពានលើក្រមនៃការប្រព្រឹត្តិរបស់សិស្ស ដូចដែលគេនឹងដកសិសស៊ីដែលធ្វើខុសដូចគ្នានេះដែលក្មេងទាំងនោះមិនមែនជាជនពិការ។ បុគ្គលិករបស់សាលានឹងផ្លាស់ប្តូរកូនរបស់អ្នកចេញពីសាលាជាថ្មី ដោយមិនឲ្យលើសពីរយៈពេល **10 ថ្ងៃ** ជាប់គ្នានៅឆ្នាំសិក្សាដដែលនោះ ចំពោះសកម្មភាពនៃការប្រព្រឹត្តិខុសឆ្គងផ្សេងទៀតដែលបានធ្វើឡើងដរាបណាការផ្លាស់ប្តូរនោះមិនមានជាការផ្លាស់ប្តូរទីតាំងនៃសេវាសិក្សា (មើលនិយមន័យខាងក្រោមចំពោះ *ការផ្លាស់ប្តូរទីតាំងដោយសាការដាក់ពិន័យ* )។

នៅពេលដែលកូនរបស់អ្នកត្រូវបានដកចេញពីកន្លែងសិក្សាបច្ចុប្បន្នរបស់គេក្នុងរយៈពេលសរុប **10 ថ្ងៃ** ក្នុងឆ្នាំសិក្សាដដែលនោះ សាលាត្រូវផ្តល់សេវានានាដែលត្រូវការទៅតាមកម្រិតដែលត្រូវការនៅ ថ្ងៃណាមួយបន្ទាប់ពី ថ្ងៃដកចេញនោះ នៅក្រោមអនុចំណងជើង **ការផ្តល់សេវា** ។

## អំណាចបន្ថែម

ប្រសិនបើឥរិយាបថដែលបំពានលើក្រមនៃការប្រព្រឹត្តិរបស់សិស្ស មិនពាក់ព័ន្ធ នឹងពិការភាពរបស់កូនអ្នកទេ (មើល *ការកំណត់ពីការពាក់ព័ន្ធ* ខាងក្រោម) ហើយការផ្លាស់ប្តូរថ្នាក់រៀនដែលយោងតាមវិន័យគឺលើសពីរយៈពេល **10 ថ្ងៃ** ជាប់គ្នានោះ បុគ្គលិកសាលានឹងអនុវត្តនីតិវិធីពិន័យចំពោះកូនរបស់អ្នកក្នុងលក្ខណៈ និងរយៈពេលដូចគ្នាដែលគេត្រូវអនុវត្តចំពោះសិស្សដែលមិនមានភាពពិការដែរ លើកលែងតែសាលាត្រូវផ្តល់សេវាចំពោះកូនរបស់អ្នកដូចមានរៀបរាប់ខាងក្រោម *ការផ្តល់សេវា* ។ នៅក្នុងស្ថានភាពនេះ ក្រុម IEP ជាអ្នកកំណត់ទៅលើសេវាអប់រំអន្តរកាល ដែលជាសេវាសម្រាប់ផ្តល់ជូនកូនរបស់អ្នក ។

## ការផ្តល់សេវា

សេវាដែលត្រូវផ្តល់ជូនកូនរបស់អ្នកខណៈពេលដែលសាលាដកគេចេញពីថ្នាក់បច្ចុប្បន្នរបស់គេនោះ គឺជាសេវាអប់រំអន្តរកាល។

សាលាសហគមន៍ស្រុកគឺមិនតម្រូវឲ្យផ្តល់សេវាចំពោះកូនរបស់អ្នកទេ ប្រសិនបើកូនរបស់អ្នកត្រូវបានផ្លាស់ប្តូរពីថ្នាក់រៀនដែលគេកំពុងសិក្សាបច្ចុប្បន្ននោះក្នុងរយៈពេល **10 ថ្ងៃ ឬ តិចជាងនេះ** ក្នុងឆ្នាំសិក្សាដដែលនោះ លើកលែងតែសាលាផ្តល់សេវាបែបនេះទៅកាន់សិស្សដែលមិនមែនជាសិស្សពិការដែលត្រូវបានដកចេញក្នុងស្ថានភាពផ្លាស់ប្តូរស្រដៀងគ្នានេះ ។

ប្រសិនបើកូនរបស់អ្នកត្រូវបានផ្លាស់ពីថ្នាក់រៀនដែលគេកំពុងសិក្សាបច្ចុប្បន្ននោះក្នុងរយៈពេលច្រើនជាង **10 ថ្ងៃនៃការសិក្សា** នោះកូនរបស់អ្នក

1. នៅតែទទួលបានសេវាអប់រំដដែល ការធ្វើដូច្នេះគឺដើម្បីបង្កើតលក្ខណៈងាយស្រួលដល់កូនរបស់អ្នកក្នុងការបន្តការសិក្សាក្នុងកម្មវិធីសិក្សាទូទៅ ទោះបីជាស្ថិតក្នុងទីតាំងផ្សេងក្តី និងដើម្បីឈានដល់ការសម្រេចគោលដៅដែលគេបានកំណត់ក្នុង IEP របស់សិស្សនោះ **និង**
2. ប្រសិនបើឥរិយាបថកូនរបស់អ្នកមិនពាក់ព័ន្ធទៅនឹងពិការភាពរបស់គេទេ នោះកូនរបស់អ្នកនឹងត្រូវទទួលការវាយតម្លៃលើឥរិយាបថទៅតាមមុខងារនីមួយៗ ប្រកបដោយភាពត្រឹមត្រូវ ការផ្តល់សេវាអន្តរាគមន៍ ឥរិយាបថ និងការកែប្រែ ឥរិយាបថ ដែលរៀបចំឡើងដើម្បីដោះស្រាយទៅលើ ឥរិយាប នៃការបំពានដើម្បីកុំឲ្យវាកើតឡើងសាជាថ្មី ។

បន្ទាប់ពីកូនរបស់អ្នកត្រូវបានដកពីថ្នាក់រៀនដែលគេកំពុងសិក្សាបច្ចុប្បន្នក្នុងរយៈពេល **10 ថ្ងៃ នៃការសិក្សា** ក្នុងឆ្នាំសិក្សាដដែល ហើយ **ប្រសិនបើ** ការផ្លាស់ប្តូរបច្ចុប្បន្នគឺក្នុងរយៈពេល **10** ថ្ងៃ នៃការ**សិក្សា** ជាប់គ្នា ឬ តិចជាងនេះ **ហើយ** ប្រសិនបើការដកនោះមិនត្រូវបានចាត់ថាជាការផ្លាស់ប្តូរថ្នាក់រៀន (មើលនិយមន័យខាងក្រោម) **ពេលនោះ** បុគ្គលិករបស់សាលា ដែលទទួលបានការពិគ្រោះយោបល់ជាមួយគ្រូដែលមើលការខុសត្រូវលើកូនអ្នកយ៉ាងហោចណាស់ម្នាក់ នឹងកំណត់ពីទំហំសេវាដែលត្រូវការដើម្បីបង្កលក្ខណៈងាយស្រួលដល់កូនរបស់អ្នកក្នុងការចូលរួមបន្តការសិក្សាក្នុងកម្មវិធីសិក្សាទូទៅ ទោះបីជាគេស្ថិតនៅកន្លែងផ្សេងក្តី និងដើម្បីឈានដល់ការសម្រេចគោលដៅដែលបានកំណត់ក្នុង IEP សម្រាប់កូនរបស់អ្នក។

បើការដកនោះជាការផ្លាស់ប្តូរថ្នាក់រៀន (មើលនិយមន័យខាងក្រោម) ក្រុមការងារ IEP សម្រាប់កូនរបស់អ្នកនឹងកំណត់ការផ្តល់សេវាសមស្របដើម្បីបង្កលក្ខណៈងាយស្រួលដល់កូនរបស់អ្នកក្នុងការចូលរួមក្នុងកម្មវិធីសិក្សាទូទៅ ទោះបីជាគេស្ថិតក្នុងទីតាំងផ្សេងក្តី នឹងដើម្បីឈានដល់ការសម្រេចគោលដៅដែលបានកំណត់ក្នុង IEP សម្រាប់កូនរបស់អ្នក ។

## <u>ការផ្លាស់ប្តូរថ្នាក់រៀនដោយសាការពិន័យដកចេញ</u>

**<u>34 CFR §300.536; WAC 392-172A-05155</u>**

ការដកកូនអ្នកពីថ្នាក់រៀនដែលគេកំពុងសិក្សាគឺជា **ការផ្លាស់ប្តូរសេវាថ្នាក់រៀន** ប្រសិនបើ

1. ការដកនោះលើសពី 10 ថ្ងៃ នៃការសិក្សាជាប់គ្នា **ឬ**
2. កូនរបស់អ្នកត្រូវបានគេដកច្រើនលើកកន្លងមកដែលបង្កើតទៅជាទម្រង់មួយដែល
   a. ការដកច្រើនលើកសរុបទៅលើសពី 10 ថ្ងៃ នៃការសិក្សា ក្នុងឆ្នាំសិក្សានោះ
   b. ឥរិយាបថកូនរបស់អ្នក មានលក្ខណៈ ស្រដៀងគ្នាភាគច្រើនទៅនឹងឥរិយាបថចំពោះការប្រព្រឹត្តិខុសឆ្គងកន្លងមក ដែលនាំឲ្យមានការផ្លាស់ប្តូរច្រើនលើក **និង**

c. មានកត្តាបន្ថែមជាច្រើនទៀតពាក់ព័ន្ធទៅនឹងរយៈពេលនៃការដក ចំនួនដងដែលកូនរបស់អ្នកផ្លាស់ប្តូរ និងការត្រៀមផ្លាស់ប្តូរទៅសេវាផ្សេងទៀត ។

សាលាសហគមន៍ស្រុក នឹងកំណត់ថាតើទម្រង់នៃការដកនេះបង្កើតជាការផ្លាស់ប្តូរសេវា ដោយផ្អែកលើមូលដ្ឋានករណីមួយ ដែរឬទេ ហើយបើសិនជាមួយការសួរដេញដោលពីអ្នក នោះវានឹងទទួលការពិនិត្យឡើងវិញតាមរយៈសវនាការដោះស្រាយវិវាទ និង ដំណើរការនីតិវិធីផ្លូវច្បាប់។

**<u>ការផ្តល់ការជូនដំណឹង</u>**

នៅកាលបរិច្ឆេទដែលសាលាសហគមន៍ស្រុកសម្រេចចិត្តផ្អាកការសិក្សាបណ្តោះអាសន្ន ដែលជាការផ្លាស់ប្តូរសេវាថ្នាក់រៀនសម្រាប់កូនរបស់អ្នកដោយសារតែគេបំពានក្រមសីលធម៌នៃការប្រព្រឹត្តិរបស់សិស្សនោះ សាលាសហគមន៍ស្រុកនឹងជូនដំណឹងដល់អ្នកពីការសម្រេចចិត្ត និងផ្តល់នូវសេចក្តីជូនដំណឹងពីនីតិវិធីគាំពារ។

**<u>ការកំណត់ពីការពិត</u>**

ចំពោះការសម្រេចចិត្តនៃការផ្លាស់ប្តូរសេវាថ្នាក់រៀនក្នុងរយៈពេល **10ថ្ងៃ នៃការសិក្សា** (មើល**ការផ្លាស់ប្តូរសេវាដោយការដាក់ពិន័យដកចេញពីថ្នាក់**) ចំពោះកូនរបស់អ្នកដោយសាការបំពានក្រមសីលធម៌នៃការប្រព្រឹត្តណាមួយនោះសាលាសហគមន៍ស្រុក និង សមាជិកពាក់ព័ន្ធរបស់ ក្រុម IEP ដែលកំណត់ដោយអ្នក និងសាលាសហគមន៍ស្រុក ចាំបាច់ត្រូវពិនិត្យឡើងវិញលើរាល់ព័ត៌មានដែលពាក់ព័ន្ធក្នុងឯកសាកូនរបស់អ្នក រាប់ទាំង IEP របស់គេ ការសង្កេតរបស់គ្រូ និងព័ត៌មានដែលពាក់ព័ន្ធ ដែលផ្តល់ដោយខ្លួនអ្នកផងដែរដើម្បីកំណត់ថា

1. តើការប្រព្រឹត្ត ក្នុងសំនួរដែល ត្រូវបានបង្កឡើងដោយ ឬទាក់ទងផ្ទាល់ និងយ៉ាងច្រើនទៅនឹងពិការភាពកូនរបស់អ្នកដែរឬទេ **ឬ** តើការប្រព្រឹត្ត ខុសសីលធម៌ជាលទ្ធផលផ្ទាល់នៃការខកខានរបស់សាលាសហគមន៍ស្រុកក្នុងការអនុវត្ត IEP កូនរបស់អ្នក ។

ប្រសិនបើសមាជិកដែលមានការពាក់ព័ន្ធរបស់ក្រុម IEP ដែលទទួលបន្ទុកលើកិច្ចការកូនរបស់អ្នក រាប់បញ្ចូលទាំងអ្នកផងដែរកំណត់ថា វាត្រូវទៅនឹងលក្ខខណ្ឌ ណាមួយហើយនោះ គេត្រូវកំណត់ថាការប្រព្រឹត្តនោះគឺជាមូលហេតុនៃពិការភាពនៃកូនរបស់អ្នកឬមួយយ៉ាងណា ។

ប្រសិនបើក្រុមដែលបានរៀបរាប់ខាងលើកំណត់ថាការប្រព្រឹត្ត ដែលបង្កជាបញ្ហានោះជាលទ្ធផលផ្ទាល់នៃការខកខានរបស់សាលាសហគមន៍ស្រុកក្នុងការអនុវត្តន៍ IEP ពេលនោះសាលាសហគមន៍ស្រុកត្រូវចាត់វិធានការជាបន្ទាន់ចំពោះមធ្យោបាយប្រកបដោយជោគជ័យសម្រាប់ភាពខ្វះចន្លោះទាំងនោះ។

**<u>ការកំណត់ដែលថាឥរិយាបថគឺជាមូលហេតុនៃពិការភាពរបស់សិស្ស</u>**

នៅពេលដែលក្រុមនេះ រាប់បញ្ចូលទាំងអ្នកផងដែរបានកំណត់ថា ការប្រព្រឹត្ត ជាមូលហេតុនៃពិការភាពកូនរបស់អ្នកនោះ ក្រុម IEP ត្រូវ :

1. រៀបចំការវាយតម្លៃឥរិយាបថតាមមុខងារ លើកលែងតែសាលាសហគមន៍ស្រុកបានរៀបចំការវាយតម្លៃឥរិយាបថតាមមុខងារ មុនពេលកើតមានឥរិយាបថដែលនាំមកការផ្លាស់ប្តូរសេវាថ្នាក់រៀនកើតឡើងនិងអនុវត្តន៍ ផែនការអន្តរាគមន៍ឥរិយាបថសម្រាប់កូនរបស់អ្នក **ឬ**

2. ពិនិត្យទៅលើផែនការអន្តរាគមន៍ឥរិយាបថ និងកែប្រែវាដូចដែលចាំបាច់ បើសិនជាគេបានបង្កើតផែនការអន្តរាគមន៍ឥរិយាបថហើយនោះ ដើម្បីលើកឡើងពីឥរិយាបថកូនរបស់អ្នក។

លើកលែងតែមានចែងដូចរៀបរាប់ខាងក្រោមក្រោមអនុចំណងជើង **កាលៈទេសៈពិសេស** សាលាសហគមន៍ស្រុកត្រូវបញ្ជូនកូនរបស់អ្នកទៅកាន់សេវាដែលគេបានផ្លាស់មកលើកលែងតែអ្នក និងសាលាសហគមន៍ស្រុកធ្វើការព្រមព្រៀងគ្នាក្នុងការផ្លាស់ប្តូរសេវាថ្នាក់រៀន ដែលជាផ្នែកមួយនៃការកែប្រែចំពោះផែនការអន្តរាគមន៍ឥរិយាបថ។

**<u>កាលៈទេសៈពិសេស</u>**

បុគ្គលិកសាលានឹងផ្លាស់ប្តូរកូនរបស់អ្នកទៅថ្នាក់អប់រំដែលគេជ្រើសរើសបណ្តោះអាសន្ន (កំណត់ដោយក្រុម IEP របស់សិស្ស) ដោយមិនគិតថាការប្រព្រឹត្តិរបស់កូនអ្នកនោះគឺពាក់ព័ន្ធ ឬមិនពាក់ព័ន្ធ ក៏ដោយក្តីទៅនឹងពិការភាពរបស់គេ សម្រាប់រយៈពេល 45 ថ្ងៃ ប្រសិនបើកូនរបស់អ្នក

1. យកអាវុធ (មើលនិយមន័យខាងក្រោម ) ចូលសាលា ឬមានអាវុធនៅសាលា បរិវេណសាលា ឬយកចូលក្នុងកម្មវិធីសាលា ក្រោមយុត្តាធិការរបស់សាលាសហគមន៍ស្រុក
2. ដឹងថាមាន ឬប្រើគ្រឿងញៀនខុសច្បាប់ (មើលនិយមន័យខាងក្រោម ) ឬលក់ ឬ ប្រមូលប្រាក់ដែលបានមកពី ការលក់សាធាតុហាមឃាត់ (មើលនិយមន័យខាងក្រោម ) ពេលកំពុងសិក្សានៅសាលា យកអាវុធចូលក្នុងបរិវេណសាលា ឬយកអាវុធចូលក្នុងកម្មវិធីសាលា ក្រោមយុត្តាធិការរបស់សាលាសហគមន៍ **ឬ**
3. បង្ករបួសស្នាមលើរាងកាយធ្ងន់ធ្ងរ (មើលនិយមន័យខាងក្រោម ) ទៅលើបុគ្គលណាម្នាក់ពេលកំពុងសិក្សាក្នុងបរិវេណសាលា ឬនៅក្នុងកម្មវិធីសាលាក្រោមយុត្តាធិការរបស់សាលានៅតាមសហគមន៍ស្រុក។

**<u>និយមន័យ</u>**

*សាធាតុហាមឃាត់* សម្តៅលើសាធាតុគ្រឿងញៀន ឬសាធាតុផ្សេងទៀត ដែលកំណត់ក្រោមច្បាប់ I, II, III , IV ឬ V ក្នុងផ្នែក 202 (c) នៃច្បាប់ស្តីពីសាធាតុហាមឃាត់ (21 U.S.C 812 (c))។

*គ្រឿងញៀនខុសច្បាប់* មានន័យថាសាធាតុហាមឃាត់ ប៉ុន្តែ មិនរាប់បញ្ចូលសាធាតុហាមឃាត់ដែលមាន ឬប្រើដោយស្របច្បាប់ក្រោមការពិនិត្យនៃបុគ្គលិកសុខាភិបាលវិជ្ជាជីវៈដែលមានអាជ្ញាប័ណ្ណ ឬដែលមាន ឬប្រើដោយស្របច្បាប់ក្រោមអាជ្ញាប័ណ្ណ ក្រោមច្បាប់ ឬ ក្រោមបញ្ញតិផ្សេងទៀតនៃច្បាប់សហព័ន្ធ ។

*ការបង្ករបួសស្នាមធ្ងន់ធ្ងរលើរូបរាងកាយ* មានន័យថាការធ្វើឲ្យរបួសលើរាងកាយដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរដែលអាចឈានដល់ការបាត់បង់ជីវិត ការបង្កការឈឺចាប់លើរាងកាយធ្ងន់ធ្ងរ ការធ្វើឲ្យខូចរូបរាងកាយធ្ងន់ធ្ងរ និងយូរអង្វែង ឬការធ្វើឲ្យបាត់បង់រហូត ឬធ្វើឲ្យពិការដល់មុខងារណាមួយនៃរាងកាយ លើសរីរាង្គយូរអង្វែង ឬលើសមត្ថភាព ។

*អាវុធ* មានន័យថា អាវុធ ឧបករណ៍ ប្រដាប់ប្រដារ សម្ភារៈ ឬសាធាតុ វត្ថុមានចលនា ឬគ្មានចលនា ដែលប្រើសម្រាប់ ឬដែលមានលទ្ធភាពបង្កឲ្យមានការបាត់បង់ជីវិត ឬរបួសលើរាង្គកាយធ្ងន់ធ្ងរ ដែលន័យនេះមិនរាប់បញ្ចូលកូនកាំបិតដែលមានប្រវែងខ្លីជាងពីរ ឬ មួយអ៊ីញកន្លះ។

**<u>បត់ទីតាំង</u>**

**<u>34 CFR§ 300.531; WAC 392-172A-05150</u>**

ក្រុម IEP ត្រូវកំណត់ថ្នាក់រៀនអន្តរកាលសម្រាប់សិស្សដែលផ្អាកការសិក្សា ដែលជាការ **ផ្លាស់ប្តូរសេវាថ្នាក់រៀន** និង ការផ្លាស់ប្តូរក្រោមចំណងជើងថា **អំណាចបន្ថែម** និង **កាលៈទេសៈពិសេស** ខាងលើ ។

## សវនាការដោះស្រាយវិវាទសម្រាប់ការដាក់ពិន័យ
## 34 CFR§ 300.532; WAC 392-172A-05160

អ្នកអាចដាក់សំណើរសុំសវនាការដោះស្រាយវិវាទ បើសិនជាអ្នកមិនយល់ព្រមជាមួយ

1. រាល់ការសម្រេចចិត្តពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរសេវា ក្រោមច្បាប់វិន័យទាំងនេះ **ឬ**
2. ការកំណត់ពីមូលហេតុដែលបានរៀបរាប់ខាលើ។

សាលាសហគមន៍ស្រុកអាចដាក់សំណើសុំឲ្យមានសវនាការដោះស្រាយវិវាទ បើសិនជាសាលាជឿថា ការរក្សាកូនអ្នកនៅក្នុងសេវាអប់រំបច្ចុប្បន្នអាចនាំមកនូវការរបួសស្នាមដល់កូនរបស់អ្នក ឬអ្នកដទៃ ។

មើលផ្នែក ***សវនាការដោះស្រាយវិវាទ*** សម្រាប់ព័ត៌មានបន្ថែមស្តីពីការស្នើសុំឲ្យមានសវនាការដោះស្រាយជម្លោះ។

## អំណាចរបស់ចៅក្រមច្បាប់រដ្ឋបាល (ALJ)

ALJ ត្រូវតែបើកសវនាការដោះស្រាយវិវាទ និងធ្វើសេចក្តីសម្រេច ។ ALJ អាច :

1. ប្រគល់កូនលោកអ្នកឲ្យត្រលប់ទៅកាន់សេវាដើមវិញ ប្រសិនបើ ALJ រកឃើញថា ការដកចេញនោះជាការរំលោភបំពានលើលក្ខខណ្ឌ ***អំណាចរបស់បុគ្គលិកសាលា*** ឬរកឃើញថាអាកប្បកិរិយារបស់កូនលោក អ្នកគឺជាការបង្ហាញឲ្យឃើញពិភាពិការរបស់គេ **ឬ**
2. បញ្ជាឲ្យមានការផ្លាស់ប្តូរទីកន្លែងអប់រំនៃកូនរបស់លោកអ្នកទៅកាន់កន្លែងអប់រំបណ្តោះអាសន្នសមស្របផ្សេងទៀត សម្រាប់រយៈពេលមិនលើសពី ៤៥ ថ្ងៃ នៃ ថ្ងៃ សិក្សា បើសិន ALJ រកឃើញថា ការទុកកូនរបស់លោកអ្នកឲ្យនៅទីនេះនាំឲ្យមានគ្រោះថ្នាក់ដល់កូនអ្នក ឬអ្នកដទៃទៀត។

នីតិវិធីសវនការទាំងនេះអាចធ្វើឡើងសាជាថ្មីបាន ប្រសិនបើសាលាសហគមន៍ស្រុក ជឿថា ការឲ្យកូនរបស់លោកអ្នកទៅកាន់កន្លែងអប់រំដើមវិញនាំឲ្យមានគ្រោះថ្នាក់ដល់កូនរបស់អ្នក ឬអ្នកដទៃ ។

នៅពេលណាដែលលោកអ្នកឬសាលាសហគមន៍ស្រុកផ្ទាល់ធ្វើការសំណូមពរឲ្យមានសវនាការដោះស្រាយវិវាទសំណូមពរនោះត្រូវតែស្របតាមលក្ខខណ្ឌដែលតម្រូវនៅក្នុង ***នីតិវិធីនៃការស្នើសុំសវនាការដោះស្រាយវិវាទ និងសវនាការដោះស្រាយវិវាទ*** លើកលែងតែមានករណីកើតមានដូចខាងក្រោម :

1. សវនាការដោះស្រាយវិវាទមានភាពប្រញាប់ ហើយត្រូវតែកើតឡើងក្នុងរយៈពេល **20** ថ្ងៃ នៃកាលបរិច្ឆេទដែលសវនាការបានសំណូមពរ ។ ALJ ត្រូវតែចេញសេចក្តីសម្រេចក្នុងរយៈពេល **10** ថ្ងៃ បន្ទាប់ពីសវនាការ។

2. ប្រសិនបើអ្នក និងសាលាសហគមន៍ស្រុកមិនយល់ព្រមដាលាយលក្ខណ៍អក្សរដើម្បីចូលប្រជុំ ឬមិនយល់ព្រមប្រើវិធីសម្របសម្រួលគ្នាទេ នោះកិច្ចប្រជុំដំណោះស្រាយ ត្រូវតែធ្វើឡើងក្នុងរយៈពេល ប្រាំពីរ ថ្ងៃ ពេញ ចាប់ពី ថ្ងៃ ទទួលសេចក្តីជូនដំណឹងរបស់សំណូមពរសវនាការដោះស្រាយវិវាទ ។ សវនាការនឹងធ្វើឡើង ប្រសិនបើរឿងរ៉ាវនេះមិនបានដោះស្រាយសមតាមបំណងរបស់គូភាគីទាំងពីរក្នុងរយៈពេល 15 ថ្ងៃពេញ ដោយគិតចាប់តាំងពីថ្ងៃនៃការទទួលបានសំណូមពររបស់សវនាការដោះស្រាយវិវាទ។
3. OSPI បានផ្តល់រយៈពេល ២ថ្ងៃ នៃថ្ងៃធ្វើការងារ សម្រាប់ការបង្កើតភស្តុតាងទៅពេលមានការដាក់ពាក្យស្នើសុំសវនាការដោះស្រាយវិវាទបន្ទាន់ត្រូវបានធ្វើឡើង។

អ្នក ឬសាលាសហគមន៍ស្រុកអាចដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ធ្វើការតវ៉ាលើសេចក្តីសម្រេចនៅក្នុងសវនាការ ដូចគ្នាទៅនឹងការតវ៉ាលើសេចក្តីសម្រេចនៅក្នុងសវនាការផ្នែកដោះស្រាយវិវាទមិនមែនការអប់រំពិសេស ផងដែរ (សូមមើល **ការប្តឹងបន្ត** នៅខាងលើ) ។

## ការដាក់ថ្នាក់ឲ្យចូលរៀនក្នុងអំឡុងពេលនៃសវនាការដោះស្រាយជម្លោះបន្ទាន់
## ៣៤ ជឍ ៣០០។៥៣៣; ៊ជ ៣៩២-១៧២។-០៥១៦៥

នៅពេលអ្នក ឬសាលាសហគមន៍ស្រុកបានដាក់សំណូមពរសុំសវនាការធ្វីការដោះស្រាយដែលទាក់ទងទៅនឹងបញ្ហាខាងវិន័យ កូនលោកអ្នកត្រូវតែ (លុះត្រាតែអ្នក និងសាលាសហគមន៍ស្រុកយល់ព្រម ) ស្ថិតនៅកន្លែងអប់រំបណ្តោះអាសន្នផ្សេងទៀត មុនពេលមន្ត្រីសវនាការចេញសេចក្តីសម្រេច ឬ រហូតទាល់តែផុតរយៈពេលនៃការដកចេញ ដូចមានចែងនៅក្នុង ***អំណាចរបស់បុគ្គលិកសាលា*** ចំពោះករណីណាដែលកើតឡើងមុន។

## ការការពារសម្រាប់សិស្សដែលមិនទាន់មានសិទ្ធិទទួលបានការអប់រំពិសេស និង សេវាពាក់ព័ន្ធ ផ្សេងទៀត
## ៣៤ ជឍ ៣០០។៥៣៤; ៊ជ ៣៩២-១៧២។-០៥១៧០

## លក្ខខណ្ឌទូទៅ

ប្រសិនបើកូនរបស់លោកអ្នកមិនទាន់មានសិទ្ធិទទួលបានសេវាអប់រំពិសេស និង សេវាពាក់ព័ន្ធ ផ្សេងទៀតទេនោះ ហើយរំលោភបំពានលើក្រមសីលធម៌នៃការប្រព្រឹត្តិរបស់សិស្ស អ្នកអាចប្រើប្រាស់ការការពារតាមនីតិវិធីសម្រាប់កូនលោកអ្នក ប្រសិនបើគេរកឃើញថា សាលាសហគមន៍ស្រុកបានដឹងថា កូនលោកអ្នកគួរទទួលការវាយតម្លៃ និង រកឃើញថាមានសិទ្ធិទទួលបានសេវាអប់រំពិសេស មុនពេលមានអាកប្បកិរិយាដែលនាំមកនូវវិធានការផ្នែកវិន័យនេះឡើង។

## ចំណេះដឹងជាមូលដ្ឋានស្តីពីវិន័យ

សាលាសហគមន៍ស្រុកត្រូវដឹងថាកូនរបស់លោកអ្នកមានសិទ្ធិទទួលបានការអប់រំពិសេស មុនពេលមានអាកប្បកិរិយា ដែលនាំមកនូវវិធានវិន័យកើតឡើងប្រសិនបើ :

1. លោកអ្នកបង្ហាញក្តីកង្វល់ជាលាយលក្ខណ៍អក្សរថា កូនរបស់លោកអ្នកស្ថិតនៅក្នុងភាពចាំបាច់ក្នុងការទទួលបានសេវាអប់រំពិសេស និង សេវាពាក់ព័ន្ធ ផ្សេងទៀត ទៅបុគ្គលិកផ្នែករដ្ឋបាល ឬ ផ្នែកគ្រប់គ្រងរបស់សាលា ឬ ទៅកាន់គ្រូបង្រៀនកូនលោកអ្នក។
2. លោកអ្នកបានសំណូមពរឲ្យធ្វើការវាយតម្លៃដែលទាក់ទងទៅនឹងសិទ្ធិទទួលបានសេវាអប់រំពិសេស និង សេវាពាក់ព័ន្ធ ផ្សេងទៀត ក្រោមផ្នែក ខ របស់ IDEA ឬ
3. គ្រូកូនលោកអ្នក ឬបុគ្គលិកសាលាផ្សេងទៀត បានបង្ហាញក្តីបារម្ភ អំពីអាកប្បកិរិយាដែលកូនលោកអ្នកបញ្ចេញដោយផ្ទាល់ទៅកាន់នាយកសាលារដ្ឋផ្នែកអប់រំពិសេស ឬទៅកាន់ប្រធានផ្នែកបុគ្គលិកដទៃទៀត។

## ករណីលើកលែង

សាលាសហគមន៍ស្រុកមិនត្រូវចាត់ទុកថាបានដឹងប្រសិនបើ :

1. លោកអ្នកមិនអនុញ្ញាតឲ្យមានការវាយតម្លៃលើកូនលោកអ្នក ឬ លោកអ្នកបដិសេធសេវាអប់រំពិសេស ឬ
2. កូនលោកអ្នកត្រូវបានគេវាយតម្លៃ និង រកឃើញថាមានមិនមានសិទ្ធិទទួលបានសេវាអប់រំពិសេស។

## លក្ខខណ្ឌ ដែលយកមកអនុវត្តន៍ បើសិនមិនមានចំណេះដឹងជាមូលដ្ឋាន

បើសិនសាលាសហគមន៍ស្រុកមិនបានដឹងថា កូនរបស់អ្នកមានសិទ្ធិទទួលបានការអប់រំពិសេស មុនពេលចាត់វិធានការខាងវិន័យទៅនឹងកូនលោកអ្នក ដូចដែលមានចែងនៅក្នុងចំណុច **ចំណេះដឹងជាមូលដ្ឋានស្តីពីផ្នែកវិន័យ** និង **ករណីលើកលែង** កូនរបស់អ្នក ត្រូវស្ថិតនៅក្នុងវិធានការផ្នែកវិន័យដែលត្រូវយកមកអនុវត្តលើគ្រប់សិស្សទាំងអស់ដែលមិនមានភាពពិការដែលជាប់ពាក់ព័ន្ធ នៅក្នុងប្រភេទអាកប្បកិរិយាប្រភេទដូចគ្នា។
ទោះជាយ៉ាងនេះ ក្តីបើសិនលោកអ្នកឬសាលាសហគមន៍ស្រុកសំណូមពរឲ្យធ្វើការវាយតម្លៃលើកូនរបស់អ្នកក្នុងអំឡុងពេលដែលកូននោះស្ថិតនៅក្នុងវិធានការខាងវិន័យ នោះការវាយតម្លៃត្រូវធ្វើឡើងជាបន្ទាន់។

លើកលែងតែការវាយតម្លៃត្រូវបានបញ្ចប់ កូនរបស់អ្នកនៅតែមានវត្តមាននៅក្នុងបថ្នាក់សិក្សាអប់រំដែលបានកំណត់ឡើងដោយអាជ្ញាធរសាលាដែលអាចរួមបញ្ចូលទាំងការព្យួរការសិក្សា ឬការលុបឈ្មោះចេញពីសាលាដោយគ្មានសេវាអប់រំ។

បើសិនកូនរបស់អ្នក ត្រូវបានគេរកឃើញថាមានសិទ្ធិទទួលបានសេវាអប់រំពិសេស ដោយធ្វើការពិចារណាលើព័ត៌មានពីការវាយតម្លៃដែលបានធ្វើឡើងដោយសាលាសហគមន៍ស្រុក និង ព័ត៌មានដែលអ្នកផ្តល់ឲ្យសាលារដ្ឋត្រូវតែផ្តល់សេវាអប់រំពិសេស និង សេវាពាក់ព័ន្ធ ផ្សេងទៀតដល់កូនរបស់អ្នក ហើយសាលាអនុវត្តន៍តាមលក្ខខណ្ឌ ផ្នែកវិន័យដូចដែលបានចែងនៅខាងលើ។

## ការផ្ទេរបញ្ជូន និង ការចាត់វិធានការដោយមន្ត្រីអនុវត្តន៍ច្បាប់ និង មន្ត្រីសមត្ថកិច្ចតុលាការ
## ៣៤ ជឍ ៣០០។៥៣៥;ៃផ ៣៩២-១៧២១-០៥១៧៥

ផ្នែក B នៃ IDEA មិន :

1. ហាមឃាត់ដល់សាលាសហគមន៍ស្រុកក្នុងការរាយការណ៍ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តិដោយកូនរបស់អ្នក ដែលមានសិទ្ធិទទួលបានការអប់រំពិសេសទៅដល់អាជ្ញាធរមានសមត្ថកិច្ចទេ **ឬ**
2. រារាំងដល់មន្ត្រីសមត្ថកិច្ចតុលាការ និងមន្ត្រីអនុវត្តន៍ច្បាប់របស់រដ្ឋពីការអនុវត្តន៍ នៃការទទួលខុសត្រូវរបស់ពួកគេក្នុងការអនុវត្តន៍ច្បាប់រដ្ឋ និងច្បាប់សហព័ន្ធទៅនឹងបទឧក្រិដ្ឋដែលបានប្រព្រឹត្តិឡើងដោយកូនរបស់អ្នកដែរ ។

## ការបញ្ជូនរបាយការណ៍

បើសិនសាលាសហគមន៍ស្រុករាយការណ៍ ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តិឡើងដោយកូនរបស់អ្នក នោះសាលាសហគមន៍ស្រុក

1. ត្រូវតែធានាថា រាល់ច្បាប់ថតចម្លងនៃការអប់រំពិសេស និង របាយការណ៍ខាងវិន័យត្រូវបានបញ្ជូនសម្រាប់ធ្វើការពិចារណាដោយអាជ្ញាធរមានសមត្ថកិច្ចដែលដាក់ទ្វេងដែលភ្នាក់ងារផ្តល់របាយការណ៍ ពីបទឧក្រិដ្ឋ **ហើយ**
2. អាចបញ្ជូនច្បាប់ថតចម្លងការអប់រំពិសេសរបស់កូនអ្នក និង របាយការណ៍ផ្នែកវិន័យទៅតាមការអនុញ្ញាតដោយ FERPA។

## លក្ខខណ្ឌសម្រាប់ការប្តូរថ្នាក់រៀនដាឯកតោភាគីដែលសម្រេចឡើងដោយឪពុកម្តាយរបស់សិស្សទៅក្នុងសាលាឯកជនដែលរ៉ាប់រងការចំណាយដោយរដ្ឋ

**ជលរ ៣០០។១៤៨,ៃផ ៣៩២-១៧២។-០៤១១៥**

> **បើអ្នកជឿថា សហគមន៍ស្រុក របស់អ្នកមិនអាចផ្តល់ FAPE ដល់កូនរបស់អ្នកបាន ហើយអ្នកជ្រើសរើសចុះឈ្មោះកូនរបស់អ្នកឲ្យរៀននៅក្នុងសាលាឯកជនដោយមិនមានការយល់ព្រមពីសាលារដ្ឋនោះមាននីតិវិធីមួយចំនួនដែលអ្នកត្រូវធ្វើតាមដើម្បីសុំការបង់ថ្លៃសងវិញពីសាលារដ្ឋមកសាលាឯកជន។**

## ការបងបង់ប្រាក់សងវិញសម្រាប់ការប្តូរថ្នាក់អប់រំមកសាលាឯកជន

ប្រសិនបើកូនរបស់អ្នកពីមុនបានទទួលសេវាអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងទៀតពីសាលាសហគមន៍ស្រុក ហើយអ្នកជ្រើសរើសចុះឈ្មោះកូនរបស់អ្នកឲ្យរៀននៅក្នុងសាលាមតេយ្យ ឬនៅក្នុងសាលាបឋមសិក្សា ឬនៅក្នុងសាលាមធ្យមសិក្សាដោយគ្មានការយល់ព្រម ឬដោយគ្មានការផ្ទេរបញ្ជូនដោយសាលាសហគមន៍ស្រុកទេ នោះតុលាការ ឬ ALJ អាចតម្រូវឲ្យសាលាសហគមន៍ស្រុកបង់លុយសងអ្នកវិញសម្រាប់ការចំណាយលើការចុះឈ្មោះ ប្រសិនបើតុលាការ ឬ ALJ រកឃើញថា សាលាសហគមន៍ស្រុកមិនបានបង្កើតឲ្យមាន FAPE ដល់កូនរបស់អ្នកនៅក្នុងលក្ខណៈទាន់ពេលវេលាមុនពេលចុះឈ្មោះនោះ ហើយថា ថ្នាក់រៀននៅសាលាឯកជននោះគឺមានភាពសមស្រប។ តុលាការ ឬ ALJ អាចស្វែងរកការផ្លាស់ប្តូរថ្នាក់រៀននោះឲ្យមានលក្ខណៈសមស្រប ទោះបីការផ្លាស់ប្តូរថ្នាក់កម្រិតអប់រំនោះមិនត្រូវស្តង់ដាររបស់រដ្ឋ ដែលសាលាសហគមន៍ស្រុកកំពុងអនុវត្តក៏ដោយ។

## ដែនកំណត់លើការបង់ប្រាក់សងវិញ

ការបង់ប្រាក់សងវិញ ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌខាងលើអាចត្រូវបន្ថយ ឬ ធ្វើការបដិសេធ:

1. ប្រសិនបើ : (ក) នៅអង្គប្រជុំ IEP នាពេលថ្មីៗដែលលោកអ្នកបានចូលរួម មុនពេលដកកូនលោកអ្នកចេញពីសាលាសហគមន៍ស្រុក លោកអ្នកមិនបានជូនជាដំណឹងដល់ក្រុម IEP ថាលោកអ្នកបដិសេធលើការដាក់ថ្នាក់ដែលបានស្នើឡើងដោយសាលាសហគមន៍ស្រុក ចំពោះការផ្តល់ FAPE ដល់កូនរបស់លោកអ្នក និង រួមបញ្ចូលទាំងការនិយាយបញ្ជាក់ពី ក្តីកង្វល់ និងចេតនារបស់លោកអ្នកក្នុងការចុះឈ្មោះកូនលោកអ្នកនៅក្នុងសាលាឯកជនដែលចំណាយដោយរដ្ឋ ឬ(ខ) យ៉ាងហោចណាស់រយៈពេលដប់ថ្ងៃនៃ ថ្ងៃធ្វើការ (ឬក៏រួមទាំងថ្ងៃឈប់សម្រាកដែលកើតមាននៅចំថ្ងៃធ្វើការ មុនពេលការដកកូនលោកអ្នកចេញពីសាលាសហគមន៍ស្រុក លោកអ្នកមិនបានផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជូនដល់សាលាសហគមន៍ស្រុកចំពោះព័ត៌មាននេះ។
2. ប្រសិនបើមុនពេលការដកកូនលោកអ្នកចេញពីសាលា សាលាសហគមន៍ស្រុកបានផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនជូនដល់អ្នកនូវបំណងរបស់ខ្លួនដើម្បីធ្វើការវាយតម្លៃកូនរបស់អ្នក (ឬក៏រួមទាំងរបាយការណ៍ស្តីពីគោលបំណងនៃការវាយតម្លៃដែលមានលក្ខណ:សមស្រប និងសមហេតុសមផល) ប៉ុន្តែលោកអ្នកមិនបានយកកូនឲ្យយើងធ្វើការវាយតម្លៃ ឬ
3. ផ្អែកតាមការរកឃើញរបស់តុលាការថា សកម្មរបស់លោកអ្នកមិនសមហេតុសមផល។

ទោះជាយ៉ាងណាក្តីការបង់ប្រាក់សងសងវិញ :

1. មិនត្រូវកាត់បន្ថយ ឬ បដិសេធចំពោះការខកខានក្នុងការផ្តល់នូវសេចក្តីជូនដំណឹងប្រសិនបើ (ក) សាលាបានរារាំងអ្នកក្នុងការផ្តល់នូវសេចក្តីជូនដំណឹង(ខ) លោកអ្នកមិនបានទទួលសេចកីជូនដំណឹងស្តីពីការទទួលខុសត្រូវរបស់លោកអ្នកក្នុងការផ្តល់សេចក្តីជូនដំណឹងដូចបានរៀបរាប់មកខាងលើឬ (គ) ការអនុវត្តន៍តាមលក្ខខណ្ឌ ខាងលើទំនងជាបង្កឲ្យមានភាពគ្រោះថ្នាក់ខាងរាងកាយដល់កូនលោកអ្នក ។
2. ផ្អែកតាមឆន្ទានុសិទ្ធិរបស់តុលាការ ឬ ALJ មិនត្រូវកាត់បន្ថយ ឬធ្វើការបដិសេធចំពោះការខនខានរបស់លោកអ្នកក្នុងការផ្តល់សេចក្តីជូនដំណឹងដែលបានតម្រូវ ប្រសិនបើ (ក) លោកអ្នកមិនមែនអក្ខរជន ឬមិនអាចសរសេរជាភាសាអង់គ្លេសបាន ឬ (គ) ការអនុវត្តន៍តាមលក្ខខណ្ឌ ខាងលើទំនងជានាំមកនូវភាពឈឺចាប់ផ្នែកផ្លូវអារម្មណ៍ធ្ងន់ធ្ងរដល់កូនរបស់អ្នក។

## ធនធាន

បុគ្គល ឬអង្គការដែលជួយគាំទ្រផ្នែកមូលនិធិជាសាធារណ: អាចផ្តល់ព័ត៌មានបន្ថែមស្តីពីសេវាអប់រំពិសេសនៅក្នុងរដ្ឋវ៉ាស៊ីនតោនតាមរយៈ:

**Washington PAVE**
6316 So. 12th St.
Tacoma, WA 98465
(253) 565-2266 (v/tty)
1-800-5-PARENT (v/tty)
ទូរសារ: (253) 566-8052 wapave9@washingtonpave.com

**Disability Rights Washington (DRW)**
315 5th Ave. S. #850
Seattle, WA  98104
(206) 324-1521
(800) 562-2702
TDD: (800) 905-0209
disabilityrightswa.org

**Kristin Hennessey, Ombudsman**
P.O. Box 47200
Olympia, WA  98504
(360) 725-6075
Kristin.Hennessey@k12.wa.us